00377560



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”

## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩**

**សវនាការលើកទី៧០**

ចៅក្រមសាលាដំបូង៖

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

ក្រឡាបញ្ជីសាលាដំបូង៖

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាត្ទូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ

*(Mr.Anees AHMED)*

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr.Vincent DE WILDE D'ESTMAEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.* Heleyn UÑAC*)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ុនណា

លោក គង់ ពិសី

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សីជំនាញ

### លោក រីឆាត ជេ. ហ្គោលស្ទូន


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ២

សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្តើមពី ........ ទំព័រ ៤

សួរដោយលោក តាន់ សេណារ៉ុង ផ្តើមពី ........ ទំព័រ ១២

សួរដោយលោក អានីស អះមេដ ផ្តើមពី ........ ទំព័រ ១៣

សួរដោយលោក អាឡាំង វ៉ែនណឺ ផ្តើមពី ........ ទំព័រ ១៩

សួរដោយលោក គង់ ពិសី ផ្តើមពី ........ ទំព័រ ២១

សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី ........ ទំព័រ ២៣

សួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី ........ ទំព័រ ២៥


### លោក រ៉ាអ៊ុល ម៉ាកចេនណា


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣២

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៣៣

សួរដោយលោក តាន់ សេណារ៉ុង ផ្តើមពី ........ ទំព័រ ៥៨

សួរដោយលោក វាំងសង់ ដឺវាយដ៍ ដេស្មាឯល ផ្តើមពី ........ ទំព័រ ៦១

សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី ........ ទំព័រ ៦៩

សួរដោយលោក គង់ ពិសី ផ្តើមពី ........ ទំព័រ ៧១

សួរដោយលោក អាឡាំង វ៉ែនណឺ ផ្តើមពី ........ ទំព័រ ៧៣

សួរដោយលោក ការ សាវុត្ថ ផ្តើមពី ........ ទំព័រ ៧៨

សួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី ........ ទំព័រ ៨២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក អានីស អះមេដ | អង់គ្លេស |
| លោក រីឆាត ជេ. ហ្គោលស្តូន | អង់គ្លេស |
| លោក វ៉ាអ៊្វូល ម៉ាកចេនណា | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គង់ ពិសី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| កញ្ញា ណាតាចា វីស៊ែល រីស៊ឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនៅព្រឹកនេះតាមកាលវិភាគ ដែលបានគ្រោងទុក គឺអង្គជំនុំជម្រះដំណើរការសវនាការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ រីឆាត ហ្គោលស្តូន ពាក់ព័ន្ធជាមួយនឹងសក្ខីកម្មអំពីអត្តចរឹករបស់ជនជាប់ចោទ ដោយ អង្គជំនុំជម្រះបានរៀបចំការស្តាប់នូវបទបង្ហាញរបស់អ្នកជំនាញពាក់ព័ន្ធទៅនឹងភាពជំនាញរបស់គាត់ដោយការធ្វើពីចម្ងាយ ។ ហើយអំឡុងពេលនៃដំណើរការប្រព្រឹត្តទៅគឺដំណើរការមួយព្រឹកនេះ ។

មុននឹងដំណើរការក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគ និងបុគ្គលដែលត្រូវអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីសវនាការនៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ចំណែកឯអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះមាន លោកចៅក្រម រីឆាត ហ្គោលស្តូន នឹងត្រូវផ្តល់សក្ខីកម្មតាមរយៈការចូលពីចម្ងាយពីសហរដ្ឋអាមេរិក និងអ្នកជំនាញ វ៉ាអ៊្វែល ម៉ាកចេនណា មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ អ្នកជំនាញទាំងពីររូបនេះ នឹងធ្វើ សម្បថតាមរយៈចំពោះមុខអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។ សូមមេធាវីសង្ខេបបានហើយ កុំឲ្យប៉ះពាល់ពេលវេលាដែលត្រូវកំណត់ធ្វើសក្ខីកម្មចំពោះអ្នកជំនាញរូបនេះ ពីព្រោះផែនការអ្នកជំនាញរូបនេះត្រូវធ្វើតែ-- លទ្ធភាពគឺធ្វើតែមួយព្រឹកប៉ុណ្ណោះ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ហើយខ្ញុំនឹងនិយាយដោយសង្ខេបដើម្បីរំឭកវិញថា ពីរសប្តាហ៍ទៅហើយ គឺថ្ងៃទី២១ ខែសីហា ខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះ ជាពិសេសខ្ញុំបានស្នើថាតើខ្ញុំអាចទទួលនូវសេចក្តីសម្រេចថ្ងៃទី២៧ ខែសីហា ពីព្រោះយើងមានការលំបាកក្នុងការពន្យល់កូនក្តីរបស់យើង ។ ក្នុងរយៈពេលពីរសប្តាហ៍មកហើយ យើងមិនមានសេចក្តីសម្រេចនោះទេ ។ ខ្ញុំបាន

ជដែកជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ សូមឲ្យលោកប្រធាន ហើយនិងលោកស្រីចៅក្រមផ្ដល់ឲ្យនូវសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនោះឲ្យបានឆាប់ទាន ។

[០៩:០៩:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនបានធ្វេសប្រហែសទេ នេះជាភារកិច្ចរបស់អង្គជំនុំជម្រះដែលត្រូវធ្វើ ហើយដោយហេតុបន្ទាន់នៃស្ថានភាពនៅក្នុងដំណើរការប្រព្រឹត្តទៅនៃសវនាការ ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះត្រូវសម្រេចជាមុន ហើយនិងសំអាងហេតុជាក្រោយ ។ ហើយប៉ុន្មានថ្ងៃជាប់គ្នានេះ ប្រហែលជាលោកមេធាវី និងភាគីទាំងអស់បានជ្រាបហើយអំពីកិច្ចការមមាញឹកនៃអង្គជំនុំជម្រះដែលត្រូវចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គ ដើម្បីរៀបចំធ្វើវិសោធនកម្មចំពោះវិធានមួយចំនួនតម្រូវទៅតាមស្ថានភាពជាក់ស្ដែងនៃដំណើរការសំណុំរឿងទីពីរ និងសំណុំរឿងក្រោយៗទៀតដែលមាននោះ គឺមានទាំង០៣ ។ ប្រសិនបើមាននោះ គឺដើម្បីឲ្យសមត្ថភាពរបស់ អ.វ.ត.ក របស់យើងប្រព្រឹត្តទៅបានត្រឹមត្រូវ ហើយនិងបានឆាប់រហ័សតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីឆ្លើយតបទៅនឹងតម្លៃនៃយុត្តិធម៌ដែលមានលក្ខណៈជាអន្តរជាតិនេះ ។

ដូច្នេះ បញ្ហានេះក៏ទន្ទឹមនឹងកិច្ចការមមាញឹកនេះ អង្គជំនុំជម្រះមិនបានភ្លេចនូវកិច្ចការរបស់ខ្លួនទេ គ្រាន់តែបានទាមទារពេលវេលាសមស្របមួយ ដើម្បីធ្វើការបកប្រែជាភាសាជាផ្លូវការ។ ឥឡូវនេះ ការបកប្រែបានចប់សព្វគ្រប់កាលពីសប្ដាហ៍មុនហើយ ។ អ៊ីចឹង នៅថ្ងៃនេះ ឬក៏ថ្ងៃស្អែកគ្រាន់តែប្រជុំផ្ទៀងផ្ទាត់នូវភាសាទាំងអស់នៃសេចក្ដីសម្រេចដើម្បីបញ្ចូលទៅក្នុងសំណុំរឿង ដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ ។ នេះជាការងារចាំបាច់បំផុតរបស់តុលាការ កាលណាមានសេចក្ដីសម្រេចដាច់ខាតត្រូវតែមានសំអាងហេតុដ៏ត្រឹមត្រូវ ដែលសមស្របទៅនឹងសេចក្ដីសម្រេចនោះ។

សូមខាងផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធវីដេអូខនហ្វើរិនទៅអ្នកជំនាញ ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្ដីអ្នកជំនាញ តើអ្នកជំនាញអាចប្រាប់អំពីឈ្មោះរបស់លោកពេញលេញជូនដល់អង្គជំនុំជម្រះនៃ អ.វ.ត.ក របស់យើងបានដែរ ឬទេ?

**ឆ៖** លោកប្រធានឈ្មោះខ្ញុំ រីឆាត ជេ. ហ្គោលស្តូន ។

**ស៖** តើលោក រីឆាត ជេ. ហ្គោលស្តូន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ៧០ឆ្នាំ លោកប្រធាន ។

**ស៖** លោកអ្នកជំនាញ តើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** អាសយដ្ឋានអចិន្ត្រៃយ៍របស់ខ្ញុំនៅ ជូហែននេសប៊ឺក (Johannesburg) ហើយខ្ញុំបង្រៀននៅសាលាច្បាប់មួយនៅ ហ្វឺដឌឹម (Fordham)។

**ស៖** លោក រីឆាត ជេ. ហ្គោលស្តូន តើលោកមានអាជីពធ្វើអ្វីដែរ?

**ឆ៖** មុខរបររបស់ខ្ញុំ គឺជាសាស្ត្រាចារ្យ ហើយខ្ញុំជាចៅក្រមនិវត្តន៍ពីសាលាក្តីអន្តរជាតិពីខាងដើម ។

**ស៖** លោក រីឆាត ជេ. ហ្គោលស្តូន តើលោកកាន់សាសនាអ្វីដែរ?

**ឆ៖** ខ្ញុំកាន់សាសនា ហេប្រ៊ូ ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកអ្នកជំនាញមិនមានចំណងញាតិលោហិត ញាតិពន្ធ ឬក៏សហព័ន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ, អ៊ីចឹងពិតមែនលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

កញ្ញា ណាតាចា សូមសម្របសម្រួលដល់លោក រីឆាត ជេ. ហ្គោលស្តូន ដើម្បីឲ្យលោកធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ មុននឹងឲ្យលោកអ្នកជំនាញផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ ។

**កញ្ញាណាតាចា វីស៊ែល វីស៖**

សូមជម្រាបសួរលោកចៅក្រម ហ្គោស្តូន សូមអានតាមខ្ញុំ ។

“ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព” ។

**លោក រីឆាត ជេ. ហ្គោលស្តូន៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងប្រឹងប្រែងអស់ពីសមត្ថភាព ។

[០៩:១៥:៤៤]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ ខ្ញុំសូមប្រគល់ភារៈទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីតាំងសំណួរសួរអំពីជីវប្រវត្តិជំនាញរបស់អ្នកជំនាញ មុននឹងសួរដល់ភាពជំនាញរបស់គាត់ ដែលពាក់ព័ន្ធជាមួយនឹងគាត់ដែលត្រូវធ្វើសេចក្តីថ្លែងការណ៍នៅចំពោះមុខអង្គជំនុំជម្រះនេះ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** សូមជម្រាបសួរលោកចៅក្រម ហ្គោលស្តូន ខ្ញុំនឹងសួរសំណួរលោកមួយចំនួន ដែលពន្យល់ដល់អង្គជំនុំជម្រះ ហើយនិងប្រជាពលរដ្ឋកម្ពុជាអំពីគុណសម្បត្តិរបស់លោកក្នុងការផ្តល់សក្ខីកម្មដល់យើងនៅពេលនេះ ។ តើលោកស្តាប់ខ្ញុំច្បាស់ដែរឬទេ?

**ឆ៖** អរគុណលោកស្រីចៅក្រម សូមជម្រាបសួរ ។

**ស៖** ដូចដែលលោកបានជ្រាបហើយ លោកធ្លាប់បានធ្វើជាចៅក្រមនៅអាហ្វ្រិកខាងត្បូងនៅក្នុងឆ្នាំ១៩៨០ តាមដែលខ្ញុំយល់ លោកត្រូវបានតែងតាំងឲ្យធ្វើជាចៅក្រមនៅ ត្រេនស្វែល ជាចៅក្រមកំពូលហើយនិងធ្វើការនៅក្នុងសាលាឧទ្ធរណ៍ ។ បន្ទាប់មកនៅឆ្នាំ១៩៩៤ ដល់២០០៣ លោកជាចៅក្រមរបស់តុលាការរដ្ឋធម្មនុញ្ញនៃអាហ្វ្រិកខាងត្បូង ។ តើត្រូវទេ?

**ឆ៖** ត្រូវហើយលោកស្រីចៅក្រម ។

**ស៖** ចាប់ពីឆ្នាំ១៩៩៣ រហូតដល់២០០៧ លោកក៏ជាប្រធាននៃសកលវិទ្យាល័យ *វ៉ាត់ធឺស្រែន* (Witwatersrand) នៅ *ជូហែនេសប៊ឺក* ហើយលោកក៏ជាសាស្ត្រាចារ្យនៃសាលាច្បាប់ ហ្វឹដឌឹមឡស្គូល (Fordham Law school) នៅសហរដ្ឋអាមេរិក ។

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**ស៖** លោកជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ហាវឺត ហើយនិងសាលាច្បាប់ ចចថោន តើត្រឹមត្រូវដែរឬទេ?

[០៩:១៧:៥២]

**ឆ៖** ត្រឹមត្រូវហើយលោកស្រីចៅក្រម ។

**ស៖** លោកមានអាជីពផ្លូវច្បាប់ដ៏ខ្ពង់ខ្ពស់ ហើយមានការងារមួយចំនួនដែលមានអត្ថប្រយោជន៍សម្រាប់តុលាការដែលទាក់ទងទៅនឹងបញ្ហាដែលយើងនឹងចង់ស្តាប់សក្ខីកម្មពីលោកនាថ្ងៃនេះ ។ លោកជាសមាជិកនៃក្រុមប្រឹក្សាមួយដែលទាក់ទងទៅនឹងយុត្តិធម៌សិទ្ធិមនុស្ស ហើយនិងការផ្សះផ្សាជាតិ តើអ៊ីចឹងត្រូវឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកស្រីចៅក្រម ដែលរាប់បញ្ចូលជាទាំងប្រធានវិទ្យាស្ថានអំពីយុត្តិធម៌ប្រវត្តិសាស្ត្រ ហើយនិងការផ្សះផ្សាជាតិ ហើយនិងសាកលវិទ្យាល័យប៊្រែនឌីស (Brandeis) ចំពោះយុត្តិធម៌ ហើយនិងគោលការណ៍សីលធម៌ហើយនិងជីវិតសាធារណៈ ។

**ស៖** ហើយលោកក៏ជាសហប្រធាននៃវិទ្យាស្ថានសិទ្ធិមនុស្ស ហើយនិងគណៈមេធាវីអន្តរជាតិ ហើយលោកក៏ជាសមាជិកគណៈកម្មអង្គការសហប្រជាជាតិមួយ ដើម្បីផ្តល់ទាក់ទងទៅនឹងបណ្ណសារហើយនិងមរតកអំពីតុលាការអតីតយូហ្គោស្លាវី ហើយនិងរ៉្វាន់ដា តើអ៊ីចឹងត្រឹមត្រូវឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកស្រីចៅក្រម ។

**ស៖** ហើយថ្មីៗនេះ លោកទទួលការតែងតាំងដ៏ល្អមួយក្នុងការដឹកនាំបេសកម្មស្វែងរកការពិតរបស់យូអ៊ិននៅកាសា ដែលបង្កើតឡើងដោយប្រធាននៃក្រុមប្រឹក្សាសិទ្ធិមនុស្ស តើត្រឹមត្រូវដែរឬទេ?

**ឆ៖** នោះក៏ត្រឹមត្រូវដែរលោកស្រីចៅក្រម ។

**ស៖** ចាប់ពីឆ្នាំ១៩៩៤រហូតដល់ឆ្នាំ១៩៩៦ ខ្ញុំជឿថា លោកបានធ្វើការជាប្រធានសហព្រះរាជអាជ្ញារបស់សាលាក្តីអង្គការសហប្រជាជាតិសម្រាប់អតីតយូហ្គោស្លាវីហើយនិងរ៉្វាន់ដា ។ ដូច្នេះ លោកមានបទពិសោធន៍ដ៏ទូលំទូលាយនៅក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ។ ហើយចាប់ផ្តើមនៅចុងឆ្នាំ១៩៩០ ហើយខ្ញុំកាន់តំណែងជា-- តំណែងនោះគឺដើម្បីជំនុំជម្រះមេដឹកនាំអតីតយូហ្គោស្លាវី ។

**ស៖** អ៊ីចឹង ខ្ញុំសុំសួរថាតើសំឡេងដែលមានរំខាននោះ គឺ--

តើអង្គភាពអាយធីអាចជួយសម្រួលឲ្យសំឡេងឮច្បាស់បន្តិចបានៗទេ?

ជម្រាបលោកវិញថា យើងមានការសំឡេងដាច់ខ្លះ មិនដឹងថាតើលោកបានទទួលពីខាងយើងនេះច្បាស់ដែរឬអត់?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

យើងខ្ញុំគ្រាន់តែផ្អាកបន្តិច ហើយយើងមានការពិភាក្សាបន្តិចទាក់ទងទៅលើប្រព័ន្ធសំឡេង ។

សូមអរគុណ ។ ខ្ញុំបានទទួលដំណឹងថា យើងអាចបន្តខាងបច្ចេកទេសនោះ គឺព្យាយាមកែលម្អប្រព័ន្ធសំឡេង ។

**ស៖** នៅក្នុងឆ្នាំ១៩៩៨ លោកជាប្រធានក្រុមអ្នកជំនាញអន្តរជាតិមួយចំនួនដែលធ្វើការពិសេសមួយចំនួន ដើម្បីរៀបចំសេចក្តីព្រាងទាក់ទងទៅនឹងការទទួលខុសត្រូវនិងភារកិច្ចរបស់យូអ៊ិន គឺនៅក្នុងអង្គការយូណេស្កូ តើត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកចៅក្រម ។

**ស៖** នៅចុងឆ្នាំ១៩៩៩រហូតដល់ខែធ្នូឆ្នាំ២០០១ លោកជាប្រធានអង្គភាពអង្កេតមួយអចិន្ត្រៃយ៍--ឯករាជ្យនៅកូសូវ៉ូ ។ ឆ្នាំ២០០១ លោកជាសហប្រធានអំពីអង្គការភេរវកម្មមួយ គឺបង្កើតឡើងដោយគណៈមេធាវីអន្តរជាតិ ។

**ឆ៖** ត្រឹមត្រូវហើយលោកស្រីចៅក្រម ។

**ស៖** សូមអរគុណ ។ លោកជាប្រធាននៃសមាគមមជ្ឈេទករអាមេរិក ហើយឆ្នាំ១៩៩៩ ដល់២០០៣ ហើយលោកក៏ប្រធានក្រុមទីប្រឹក្សានៃគណៈកម្មាធិការអន្តរជាតិកាកបាទក្រហម ហើយឆ្នាំ១៩៨៥រហូតដល់២០០០ លោកក៏ជាប្រធានអង្គភាពទប់ស្កាត់អំពើឧក្រិដ្ឋ ហើយនិងការស្តារសម្បទារបស់ពិរុទ្ធជន ត្រូវទេ?

[០៩:២៣:១៤]

**ឆ៖** គឺត្រូវហើយលោកស្រីចៅក្រម ។

**ស៖** គឺថាលោកបានទទួលកិត្តិយស ហើយនិងពានរង្វាន់ក្នុងអាជីពរបស់លោកជាច្រើនក្នុងវិស័យច្បាប់សន្ធិមនុស្សនិងតុលាការ ហើយសូមអភ័យទោស ខ្ញុំមិនបានរៀបរាប់ទាំងអស់ពីលទ្ធផលនោះទេ ។ ហើយលោកក៏ជាអ្នកនិពន្ធសៀវភៅដែលជាសៀវភៅមនុស្សធម៌ ដែលរំឭកមកវិញអំពីការអង្កេត អំពីឧក្រិដ្ឋអន្តរជាតិនៅក្នុងសកលវិទ្យាល័យយ៉េល ហើយនិងស្ថាប័នយុត្តិធម៌ ហើយនិងស្ថាបត្យករនៃបទឧក្រិដ្ឋដែលបោះពុម្ពផ្សាយពីរឆ្នាំកន្លងទៅនេះ ។ ហើយខ្ញុំ-- តើចំណុចណាដែលលោកគិតថាមានពាក់ព័ន្ធទៅនឹងសក្ខីភាពដែលនឹងផ្តល់នៅថ្ងៃនេះ គឺនិយាយទាក់ទងទៅនឹងសារសំខាន់នៃការទទួលស្គាល់ពិរុទ្ធភាពនៅក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ ។

**ឆ៖** អ្វីដែលខ្ញុំចង់បន្ថែមនោះគឺ ខ្ញុំបានអង្កេតការបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ហើយនិងអំពើហិង្សានៅក្នុងប្រទេសរបស់ខ្ញុំនៅអាហ្វ្រិកខាងត្បូងពីឆ្នាំ១៩៩១ដល់៩៤ ហើយបង្កើតបានជាមូលនិធិស្វែង

រកការពិត ដែលបង្កើតឡើងឆ្នាំ១៩៩៥ ។

**ស៖** ប៉ុន្តែយើងមានការរំខានហ្នឹង គឺលោកបានរៀបចំមូលនិធិមួយអំពីការស្វែងរកការពិត និងសម្របផ្សះផ្សារជាតិនៅក្នុងឆ្នាំ១៩៩១ ដល់១៩៩៥ ត្រូវទេ?

**ឆ៖** គឺត្រូវហើយ ។

**ស៖** ឥឡូវនេះ ដើម្បីកំណត់ចំណុចមួយចំនួនដើម្បីឲ្យលោកយល់មុននឹងផ្ដល់ឱកាសជូនលោកចៅក្រមនិយាយនោះ ខ្ញុំសូមជម្រាបថា ស្ថានភាពនៅទីនេះ គឺជនជាប់ចោទនៅក្នុងរឿងក្ដីនេះឈ្មោះ កាំង ហ្គេកអ៊ាវ គឺត្រូវបានគេស្គាល់ថា ឌុច ជាឈ្មោះដែលគាត់ប្រើនៅក្នុងមុនសម័យខ្មែរក្រហមផង ហើយក្នុងសម័យខ្មែរក្រហម រហូតមកដល់ថ្ងៃនេះទៀត ដែលអាចនឹងប្រើឈ្មោះកាត់របស់គាត់គឺឈ្មោះ ឌុច ។

ជនជាប់ចោទបានទទួលសារភាពពីពិរុទ្ធភាពរបស់គាត់ទាក់ទងទៅនឹងបទចោទ ដែលចោទប្រឆាំងគាត់ដែលថាជាបទចោទដ៏ធ្ងន់ធ្ងរនោះ ។ គាត់ទទួលស្គាល់ពីពិរុទ្ធភាពដោយទូលំទូលាយនៅក្នុងឱកាសមួយចំនួនក្នុងដំណាក់កាលមួយចំនួនដែលគាត់និយាយទូទៅថា គាត់បដិសេធតែចំណុចតូចៗមួយ ដែលមិនមានភស្ដុតាងប៉ុណ្ណោះ ។ ប៉ុន្តែនៅក្នុងចំណុចមួយទៀត គាត់បានសហការនៅគ្រប់ដំណាក់កាលទាំងអស់នៃការជំនុំជម្រះ ហើយការជំនុំជម្រះនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡដែលដាក់បញ្ចូលទាំងការស៊ើបអង្កេតដ៏ទូលំទូលាយ ដែលបន្ទាប់ពីការស៊ើបអង្កេតមកគឺមានការជំនុំជម្រះដែលរៀបទៅនឹងចប់ហើយ។ ពីពេលមួយទៅពេលមួយគាត់បានជួយដល់តុលាការក្នុងការបំភ្លឺនូវបញ្ហាអង្គហេតុមួយចំនួន ហើយយើងអាចនិយាយបានថា មេធាវីមួយរូបរបស់គាត់លោក ហ្រ្វង់ស្វ័រ រូ និយាយថាប្រសិនបើនៅក្នុងប្រព័ន្ធខំមិនឡូវិញ គាត់បានអាចនឹងបញ្ជាក់អំពីសារភាពពិរុទ្ធភាពរបស់គាត់នៅក្នុងបទល្មើស គឺក្នុងបទចោទជាក់លាក់មួយចំនួនទៅហើយ ។ ខ្ញុំគិតថាលោក រូ អាចនឹងបង្ហាញថែមទៀត ។

ហើយការទទួលស្គាល់ជាលាយលក្ខណ៍អក្សរ ហើយមិនបានជំទាស់ទៅនឹងអង្គហេតុដែលបានចោទឡើងប្រឆាំងគាត់នោះ ។ ដែលបង្ហាញអំពីការចោទប្រកាន់ដោយអង្គហេតុដែលដកចេញពីអង្គហេតុ ហើយនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ។

នេះជាសេចក្ដីសង្ខេបដើម្បីជូនទៅលោក គឺថាមេធាវីការពារអាចនឹងពន្យល់បន្ថែម ដូច្នេះវិធានការនៃការសហការរបស់ ឌុច នៅក្នុងការជំនុំជម្រះនេះ ។ ហើយយើងគប្បីតែបញ្ជាក់ថា ចំណុចមួយដូចជាសហព្រះរាជអាជ្ញានឹងនិយាយ ហើយនៅក្នុងប្រព័ន្ធដែលអនុញ្ញាតឲ្យដើមបណ្ដឹងរដ្ឋប្បវេណីជាជនរងគ្រោះដែលថា ទទួលថាគាត់សហការ ហើយក៏ពួកអ្នកទាំងនោះអះអាងមួយចំណែកទៀតថា គាត់មិន

បានធ្វើដោយសុទ្ធចិត្ត ដោយស្មោះត្រង់ជូនដល់តុលាការនោះទេ ។

ដូច្នេះយើងនឹងថ្លែងអំណរគុណដល់លោកក្នុងការដែលលោកអាចបញ្ជាក់បានពីចំណុចមួយចំនួនដែលទាក់ទងទៅនឹងការទទួលស្គាល់នូវការទទួលខុសត្រូវនៅក្នុងបរិបទយុត្តិធម៌អន្តរជាតិ ។ ថាតើជាចំណុចសំខាន់នោះអាកប្បកិរិយារបស់គាត់ក្នុងកិច្ចសហការនោះ អាចនឹងធ្វើបានដូចម្ដេចជាប្រយោជន៍ដល់ការផ្សះផ្សាជាតិដល់ព្រះរាជាណាចក្រកម្ពុជា? តើមូលដ្ឋានប៉ុណ្ណេះគ្រប់គ្រាន់អាចលោកផ្ដល់មតិយោបល់បានទេ?

អរគុណលោកចៅក្រម ហ្គោលស្តូន ។ ខ្ញុំនឹងផ្ដល់វេទិកាជូនលោកមានប្រសាសន៍ ដូច្នេះយើងចាំស្ដាប់មតិពីលោក ។

[០៩:២៩:១៦]

**ឆ៖** សូមអរគុណ ។ សេចក្ដីថ្លែងការណ៍ទូទៅក្នុងបទពិសោធន៍របស់ខ្ញុំ ខ្ញុំសង្កេតឃើញថានៅក្នុងតុលាការអាហ្វ្រិកខាងត្បូង ហើយនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីនិងរ៉្វាន់ដានោះគឺថា វាមានទិដ្ឋភាពសំខាន់ៗដែលត្រូវពិចារណានៅក្នុងចំណុចនេះ ។

ចំណុចទីមួយ គឺលក្ខណៈនៃបទល្មើសដូចដែលលោកលោកស្រីចៅក្រមជ្រាបហើយ គឺថាបទឧក្រិដ្ឋនៅកន្លែងនេះគឺវាមានៗលក្ខណៈធ្ងន់ធ្ងរ ។

ចំណុចទីពីរ គឺទស្សនៈរបស់-- គឺផលប្រយោជន៍របស់ជនរងគ្រោះដែលត្រូវតែឆ្លុះបញ្ចាំងដោយតុលាការព្រហ្មទណ្ឌ ។

ចំណុចទីបី គឺផលប្រយោជន៍ទូទៅរបស់សាធារណៈរបស់សង្គមតែមួយ គឺទាក់ទងទៅនឹងការកំណត់ផ្ដន្ទាទោសដោយតុលាការ ។ ដោយថាចំណុចទាំងបីនេះ ពេលខ្លះវាមានការខ្វែងគ្នាទៅវិញទៅមក ។ អ៊ីចឹងហើយយើងត្រូវមើលសមមាត្ររវាងចំណុចនីមួយៗ ។

ផលប្រយោជន៍របស់សង្គមនោះ ខ្ញុំគិតថាជាកត្តាកំណត់ត្រូវឲ្យមានការពិចារណាទៅលើសារ-សំខាន់នៃៗការបើកចំហហើយនិងការសារភាពដ៏ស្មោះត្រង់ចំពោះពិរុទ្ធភាព ។ ថាតើការខមាទោសនោះ វាពិតប្រាកដច្បាស់លាស់ដែរឬទេចំពោះជនរងគ្រោះ? ហើយនិងការសម្ដែងវិប្បដិសារី? បើតាមដែលខ្ញុំយល់នោះគឺថា គឺជាចំណុចសំខាន់មួយនូវភស្តុតាងដែលខ្ញុំទទួលបាននោះ គឺផលប៉ះពាល់ ហើយនិងសារសំខាន់នៃការទទួលសារភាពពិរុទ្ធភាពនោះនៅក្នុងបទពិសោធន៍ខំមិនឡ ។ ប៉ុន្តែ ខ្ញុំមិនគិតថាក្នុងន័យនេះវាមានភាពទស្សនៈក្នុងគោលការណ៍នោះទេ អំពីទស្សនៈផ្លូវច្បាប់ទៅតុលាការរវាងប្រព័ន្ធខំមិនឡ

និងស៊ីវិលឡនោះទេ ។

ខ្ញុំអាចទទួលស្គាល់ថា វាមានទិដ្ឋភាពសំខាន់ៗបី អំពីការទទួលស្គាល់ពិរុទ្ធភាពនេះ ហើយនិងការសុំអភ័សទោសនោះ ។ ដូច្នេះ ចំណុចសំខាន់នោះ គឺថាវាផលប្រយោជន៍របស់ជនរងគ្រោះ ហើយជាពិសេសនៅក្នុងអាហ្វ្រិកខាងត្បូង ហើយជនរងគ្រោះដឹងពីអ្វីៗដែលកើតឡើងចំពោះគេ ទោះជានៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលថា រកការពិតឱ្យឃើញចំពោះគេទេ ។ ប៉ុន្តែ យុត្តិធម៌ដែលសំខាន់ថាតើការផ្សះផ្សាជាតិសំខាន់ គឺថាអាចផ្តល់ឲ្យជនរងគ្រោះដូចម្តេច? គឺការទទួលស្គាល់ជាសាធារណៈពីប្រភពផ្លូវការមួយ នេះជាចំណុចសំខាន់ដែលថាតុលាការឲ្យមានការទទួលស្គាល់ជាទូទៅអំពីអ្វីដែលកើតឡើងចំពោះគេ ។ ហើយម្តងទៀតនៅក្នុងបទពិសោធន៍របស់ខ្ញុំគឺថាមានការលំបាក ប៉ុន្តែក្នុងរឿងក្តីមួយចំនួនគឺថា ជនរងគ្រោះពិបាកនិងការបើកចំហហើយនិងការផ្សះផ្សា ការព្យាបាលទៅលើផលវិបាកតាមរយៈការទទួលស្គាល់ជាសាធារណៈអំពីអ្វីដែលកើតឡើងនោះ ។

[០៩:៣២:៣៥]

អ្វីដែលពួកគេបានដឹងចំពោះការកើតឡើងទៅពួកគាត់ គឺចង់ឲ្យបង្ហាញជាសាធារណៈ ។ ពីផ្លូវចិត្តសាស្ត្រ យើងក៏គិតថាវាចំណុចសំខាន់ ហើយវាជាផលប្រយោជន៍ពីការទទួលស្គាល់ និងការសារ-ភាពទោស ។ ហើយប្រសិនបើវាមានសារសំខាន់នោះ គឺវាបានន័យថាជាការបញ្ចប់ទៅលើការបដិសេធទៅលើការរំលោភធ្ងន់ធ្ងរទៅសិទ្ធិមនុស្ស ។

ខ្ញុំសូមផ្តល់ឧទាហរណ៍មួយពីបទពិសោធន៍របស់ខ្ញុំពីតុលាការយូហ្គោស្លាវី ។ ខ្ញុំសង្ឃឹមថា វាជាចំណុចមួយស្របគ្នាទោះបីមិនពាក់ព័ន្ធ ។ ទាក់ទងទៅនឹងបុរសម្នាក់ឈ្មោះ អេដេម៉ូវិច ។ អេដេម៉ូវិច គឺសមាជិករបស់កងយោធាបូស្នៀអែនស៊ីប (Bosnian Serb) គាត់ៗទទួលស្គាល់ដោយតុលាការសាលាដំបូង គឺទាក់ទងទៅនឹងការគាត់ធ្វើការនៅក្នុងការដាក់សម្លាធ ហើយវាបានបង្កឲ្យមានការគ្រោះថ្នាក់ទៅលើបុរសនិងក្មេងៗនៅសាប់ប្រេននីហ្សានៅក្នុងឆ្នាំ១៩៩៥ ។

អេដេម៉ូវិច(Erdemovic) ក្រោមមកបានសម្រេចថា គាត់ចង់ធ្វើការសារភាពពិរុទ្ធភាព ហើយនៅដំបូង គឺគាត់បានបង្ហាញក្នុងលក្ខណៈគួរឲ្យសង្ស័យ ។ ហើយនៅក្នុងក្រុមទូរទស្សន៍គេបានសម្ភាសន៍គាត់ផងដែរ ។ ហើយចុងក្រោយមក អ្វីដែលខ្ញុំភ្ញាក់ផ្អើលនោះ គឺខ្ញុំស្នើសុំឲ្យមានការពិចារណាទៅលើគាត់ ហើយឲ្យបញ្ជូនគាត់មកទីក្រុងឡាអេ ហើយគាត់ត្រូវបានគេចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិធ្ងន់ធ្ងរ ឃាតកម្ម និងបទចោទធ្ងន់ធ្ងរផ្សេងៗទៀតដែលស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ

យូហ្គោស្លាវី។ គាត់សារភាព ហើយគាត់បានសារភាពទាំងស្រុង ហើយសូមទោសទៅដល់ជនរងគ្រោះ។

ហើយគឺគាត់បង្ហាញយ៉ាងស្មោះចំពោះតុលាការ ហើយគឺមានការដាក់ទោសចុងក្រោយនៅក្នុងតុលាការគឺប្រាំពីរឆ្នាំ គឺទាក់ទងទៅនឹងការដែលគាត់បាញ់ និងសម្លាប់ជនរងគ្រោះចិតសិបនាក់ ។

ដូច្នេះ ហើយអ្វីដែលសំខាន់ គឺថាមុនពេលដែលគាត់ផ្តល់ភស្តុតាងនិងមុនពេលដែលគាត់សារភាពទោស រដ្ឋាភិបាលបូស្នៀអែនស៊ើប នៅ *ផាឡេ* ហើយនិងកងទ័ព បូស្នៀអែនស៊ើប គាត់បដិសេធមនុស្សឃាតនៅក្នុង*សាប្រេនីហ្សា* ។ គេថាជាការបង្កើតរបស់ប្រទេសលោកខាងលិច ដើម្បីដាក់ពិរុទ្ធភាពមិនត្រឹមត្រូវទៅលើកងទ័ពបូស្នៀអែនស៊ើប ។ គេបានលើកឡើងថា អេដេម៉ូវិច គឺគាត់បានចង្អុលអំពីផ្នូររួមដែលជនរងគ្រោះត្រូវបានគេកប់នៅទីនោះ ។ អ្នកនាំពាក្យ បូស្នៀអែនស៊ើប បានលើកឡើងថា ប្រសិនបើមានផ្នូរ គឺពួកគេបានបដិសេធ គឺត្រូវតែមានសពដែលត្រូវបានគេរកឃើញ ហើយគេត្រូវគិតថា ពិតជាមានសាកសពនៅក្នុងផ្នូររួមនេះ ហើយពិតជាមានការសម្លាប់នៅក្នុងសមរភូមិទេ នៅក្នុងពេលដែលការបះបោរ និងការតតាំងនៅផ្នែកយោធា ។

ផ្នូររួមត្រូវបានគេជីកគាស់ឡើងដោយអ្នកជំនាញ និងអ្នកធ្វើកោសល្យវិច័យទៅលើសាកសព ហើយគេមានការបង្ហាញយ៉ាងច្បាស់លាស់ថា បុគ្គលទាំងអស់នោះគឺត្រូវគេបាញ់ពីក្រោយ បាញ់លលាដ៍ក្បាលពីក្រោយ ហើយនិងមានការចងដៃទៅក្រោយ មិនមែនជាស្ថានភាពដែលមនុស្សទាំងឡាយត្រូវបានស្លាប់នៅក្នុងសមរភូមិនោះទេ ។

ដូច្នេះហើយគេបានបង្ហាញថា អ្នកទាំងអស់នោះគឺបានត្រូវគេសម្លាប់នៅក្នុងពេលសម្លាប់រង្គាលនៅ *ស្រេប្រេនីកា* (Srebrenica)។ នៅពេលដែលមានការជីកគាស់ទៅលើផ្នូរសាកសព និងភស្តុតាងគឺវាបានបញ្ចប់ទៅការបដិសេធរបស់ជួរយោធា បូស្នៀអែនស៊ើប នៅលើអ្វីដែលបានកើតឡើង ។ ដូច្នេះគឺវាបានបញ្ជាក់អំពីការកើតឡើងនៅទីនោះ ហើយវាបានធ្វើឲ្យគេយល់ឃើញថា ការដែលគេប្រឌិតនោះគឺជាការ-- មិនមែនជាការប្រឌិតទេ ហើយមានការសម្លាប់ទៅលើជនជាតិមួយចំនួននៅក្នុងតំបន់នោះ ហើយនិងសម្លាប់ទៅលើអ្នកជាប់ឃុំមួយចំនួននៅអតីតយូហ្គោស្លាវី ។ ដូច្នេះ វាមានសារសំខាន់ទាក់ទងទៅនឹងការសារភាព និងការទទួលស្គាល់ ហើយនិងការបញ្ឈប់ទៅលើការបដិសេធទាំងអស់នោះ ។

នៅក្នុងរឿងក្តី អេដេម៉ូវិច ការសារភាពនោះ គឺប្រព័ន្ធរបស់តុលាការ ហើយវាពាក់ព័ន្ធ ហើយលោក អេដេម៉ូវិច គឺគាត់បានផ្តល់ភស្តុតាងទៅលើចុងចោទមួយចំនួនផ្សេងទៀត រួមទាំង មីឡូសីវីច ហើយនិងជនជាប់ចោទមួយចំនួនដែលត្រូវបានគេកាត់ទោស ហើយនិងមានទោសដែលតុលាការបាន

កំណត់ ។

ខ្ញុំសូមសន្និដ្ឋានបញ្ចប់--

[០៩:៣៨:២៧]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

ខ្ញុំសូមកាត់លោកនៅទីនេះ លោកសង្ឃឹមថា លោកបានឮយើង ។ យើងហាក់ដូចជាផ្តាច់ទំនាក់ទំនងហើយ យើងសម្រាកបន្តិច ដើម្បីឲ្យលោកបានដឹង និងស្តាប់ឮដែរឬទេ? ដូច្នេះ ខ្ញុំចង់សួរទៅខាងលោក ថាតើលោកបានឮសំឡេងខ្ញុំដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមជម្រាបដល់ភាគី និងសាធារណជនថា ដោយសារមានបញ្ហារអាក់រអួលផ្នែកខាងបច្ចេក ។ អ៊ីចឹង អង្គជំនុំជម្រះផ្អាកបន្តិច ដើម្បីឲ្យខាងអ្នកបច្ចេកទោសរៀបចំកែលម្អបច្ចេកទេសហ្នឹងឲ្យបានល្អឡើងវិញ ហើយប្រហែលជាមួយនាទីតែប៉ុណ្ណោះ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

**ស៖** សូមអភ័យទោស លោកចៅក្រម ហ្គោលស្តូន តើលោកស្តាប់ឮដែរឬទេនៅពេលនេះ?

**ឆ៖** បាទ, ខ្ញុំឮ ។

**ស៖** គឺការភ្ជាប់ទំនាក់ទំនងនេះ គឺបានផ្តាច់នៅពេលដែលលោកនិយាយអំពីការសន្និដ្ឋានរបស់លោក នៅចំណុចទីមួយ ។ លោកត្រឹមតែ-- ទើបតែបាននិយាយបញ្ចប់លើចំណុចដែលថា អេដេម៉ូរីក គឺបានផ្តល់ភស្តុតាងទៅលើ-- ប្រឆាំងទៅលើជនជាប់ចោទដទៃៗទៀត នៅ *អាយស៊ីធីវ៉ាយ* ហើយលោកហៀបនឹងផ្តល់យោបល់ទៅចំណុចនេះ ។ តើលោកអាចតទៅលើចំណុចនេះបានដែរឬទេ?

**ឆ៖** ខ្ញុំ ចំណុចទីពីរដែលខ្ញុំលើកឡើង ហើយនិងចំណុចទីបី គឺខ្លីទេ គឺវាទាក់ទងទៅនឹងការទទួលស្គាល់ពិរុទ្ធភាព និងការឆ្លើយសារភាព ហើយនិងការផ្តល់ជំនួយទៅដល់តុលាការ ។ វាមានឥទ្ធិពលចំពោះអ្នកដទៃដែលគាត់មកចូលរួមនៅក្នុងតុលាការនៅពេលក្រោយ ។ វាបង្ហាញអំពីការទទួលខុសត្រូវនិងការទទួលស្គាល់ វាបង្ហាញជាឧទាហរណ៍ចំពោះបុគ្គលផ្សេងទៀត ដែលគេនឹងអនុវត្តតាម ។ ចំណុចទាំងអស់នេះហើយ គឺជាចំណុចដែលខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រមជ្រាប ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកច្រើន លោកចៅក្រម ហ្គោលស្តូន ។ ខ្ញុំសូមផ្តល់វេទិកាទៅដល់លោកប្រធាន សាជាថ្មី ហើយប្រហែលជាមានសំណួរមួយចំនួនពីក្រុមប្រឹក្សាជំនុំជម្រះ ហើយបន្ទាប់មកគឺនឹងមាន ការតាំងសំណួរពីខាងសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងចុងក្រោយពីមេធាវីការពារ ក្តី ។ សូមអរគុណ ។

[០៩:៤១:៥៥]

**ប្រធានអង្គជំនុំ៖**

តើអស់លោកចៅក្រមមានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញរូបនេះទេ?

ប្រសិនបើមានសូមអញ្ជើញ ។

ដោយខាងអង្គជំនុំជម្រះមិនមានសំណួរទេ អ៊ីចឹង អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាង សហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញរូបនេះប្រសិនបើមាន។ សូម អញ្ជើញ ហើយតំណាងសហព្រះរាជអាជ្ញា គឺមានពេលវេលាម្ភៃនាទីក្នុងការសួរនេះ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ ។ ដោយតំណាងសហព្រះរាជអាជ្ញាជាតិ មានសំណួរតែ មួយសម្រាប់សួរទៅ *ផ្លាសស៊ីស* ហ្គោលស្តូន ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីខ្ញុំសូម និយាយភាសាអង់គ្លេសតែមួយសំណួរជូនទៅ *ផ្លាសស៊ីស* ហ្គោលស្តូន បាទ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ។

**អ្នកបកប្រែ៖**

សូមអភ័យទោសលោកប្រធាន ខ្ញុំស្តាប់សំឡេងពីខាងសហព្រះរាជអាជ្ញាអត់បាន ។

**លោក តាន់ សេណារ៉ុង៖**

អរុណសួស្តីលោកចៅក្រម ហ្គោលស្តូន ។

**លោក រីឆាត ជេ.ហ្គោលស្តូន៖**

អរុណសួស្តី ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** នៅពេលនេះ ខ្ញុំមានសំណួរសម្រាប់លោក ដែលវាជាប់ពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់លោកនាថ្ងៃនេះ ។

សំណួរបឋម ថាតើលោក-- ថាតើសាលាក្តីអន្តរជាតិមានការជឿជាក់ និងផ្តល់ការជឿជាក់ត្រឹមកម្រិតណាដែរទៅលើច្បាប់ជាតិរបស់ប្រទេសដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង? ដូចនៅអតីតយូហ្គោស្លាវី និងរ៉្វាន់ដា ។

[០៩:៤៥:១៩]

**ឆ៖** លោកសហព្រះរាជអាជ្ញា! តុលាការពិសេសយូហ្គោស្លាវីនិងរ៉្វាន់ដា គឺបានចែងថា អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចត្រូវការពិចារណាទៅលើច្បាប់ជាតិរបស់អតីតយូហ្គោលស្លាវី និងដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងនៅក្នុងរ៉្វាន់ដា ។ ជាពិសេសទាក់ទងទៅនឹងការដាក់ទោស ជាពិសេសទៅលើការដាក់ទោសនោះហើយ ដែលវាជាចំណុចយោងរបស់តុលាការដែលគេត្រូវប្រើប្រាស់ច្បាប់ជាតិរបស់គេយកមកអនុវត្ត ។

**ស៖** សូមអរគុណលោកចៅក្រម ហ្គោលស្ទូន ។ ខ្ញុំនៅពេលនេះ គឺផ្តល់វេទិកា-- សូមការអនុញ្ញាតផ្តល់វេទិកាជូនសហសេវិករបស់ខ្ញុំអន្តរជាតិ ។

**សួរដោយលោក អានីស អះមេដ៖**

**ស៖** លោកចៅក្រម ហ្គោលស្ទូន ឈ្មោះរបស់ខ្ញុំគឺ អានីស អះមេដ គឺជាសហព្រះរាជអាជ្ញារងអន្តរជាតិ ។ ខ្ញុំសូមលើកសួរលោក យោបល់និងការសង្កេតរបស់លោក ដើម្បីឲ្យតុលាការនេះអាចសម្រេចតាមផ្លូវច្បាប់ ទាក់ទងទៅនឹងបញ្ហាដាក់ទោសទៅលើជនជាប់ចោទ ។

ខ្ញុំសូមលើកយោបល់ដំបូង ខ្ញុំធ្វើការនៅសហព្រះរាជអាជ្ញានៅ *អាយស៊ីធីវ៉ាយ* ផងដែរ ហើយវាជាការសង្កេត និងខ្ញុំមានកិត្តិយសណាស់ដែលបានលើកឡើងនិងសួរសំណួរទៅដល់លោក ។ បន្តទៅលើសំណួររបស់សហសេវិកជាតិរបស់ខ្ញុំ ។ ខ្ញុំសូមស្នើសុំសួរយោបល់លោក ទាក់ទងទៅនឹងសេចក្តីសម្រេច ដែលតុលាការត្រូវធ្វើឡើង នៅពេលដែលការអនុវត្តនៅក្នុងប្រទេស គឺវាមានលក្ខណៈខុសគ្នាទាក់ទងទៅនឹងការដាក់ទោសលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងឡាយ ។ ខ្ញុំសូមផ្តល់ជាឧទាហរណ៍ទៅលើចំណុចនេះ ។

[០៩:៤៧:១៣]

ការអនុញ្ញាតទទួលស្គាល់ចំពោះឃាតកម្មនៅក្នុងប្រទេសកម្ពុជា គឺការដាក់ទោសនោះមានរយៈពេលប្រាំឆ្នាំទៅមួយជីវិត ។ ការកាត់ទោសនៅក្នុងប្រទេសនេះ មានលក្ខណៈខ្ពស់ណាស់ ហើយលោកបានអានសារព័ត៌មានហើយ ឃាតកម្មដែលមានលក្ខណៈព្យាបាទ មានចេតនាព្យាបាទ គឺត្រូវបានគេកាត់ទោសឲ្យជាប់ទោសម្ភៃឆ្នាំទៅមួយជីវិត ។ ហើយគឺជាប់ទោសមួយជីវិតនេះ គឺបានន័យថា ជាប់រហូតលើកលែងតែមានការលើកលែងទោសពីព្រះមហាក្សត្រ ។ ខ្ញុំឮពីការលើកឡើងរបស់លោក ដែលលោកអេដេម៉ូវិច ត្រូវបានគេកាត់ទោសឲ្យជាប់តែប្រាំពីរឆ្នាំ ។ ថាតើជនរងគ្រោះគាត់មានប្រតិកម្មយ៉ាងម៉េច? ហើយថា គេយល់ឃើញទៅលើច្បាប់នោះយ៉ាងម៉េច? ចំពោះតុលាការដែលបានបង្កើតថាជា តុលាការពិសេស ហើយបែរជាផ្តល់ការដាក់ទោសសមរម្យទៅលើឧក្រិដ្ឋជនដែលគាត់បានធ្វើការសម្លាប់ទៅជនរងគ្រោះជាមួយម៉ឺនបួនពាន់នាក់ ។ ហើយការដែលដាក់ទោសរបស់គាត់នោះ គឺវាហាក់ដូចជាមានលក្ខណៈស្រាលជាងទោសដែលត្រូវបានកាត់ឲ្យជាប់ទោសនៅក្នុងប្រទេសកម្ពុជា ដែលវាអាចជាប់រហូតទៅដល់មួយជីវិត ។ ថាតើលោកយល់យ៉ាងម៉េច?

**ឆ៖** ជាការពិត គឺវាទាក់ទងទៅនឹងបញ្ហាសំខាន់នៃការដាក់ទោសនៅត្រង់ចំណុចនេះ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះ ។ ដោយសារតែវាមិនមានលក្ខណៈអាចធ្វើទៅបានទេ ដោយយើងប្រៀបធៀបទៅលើចំនួនជនរងគ្រោះ ដែលត្រូវបានគេសម្លាប់ និងរយៈពេលនៃការដាក់ទោស ហើយមនុស្សមិនមែនគាត់អាចរស់រហូត ឬក៏យើងអាចធ្វើការសងទៅលើជីវិតគាត់ ដែលស្លាប់នោះទេ ។ ដូច្នេះហើយតុលាការ ដែលគាត់សម្រេចទៅលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ត្រូវតែព្យួរការដាក់ទោសមួយជីវិតនេះជាដំណាក់កាលចុងក្រោយ ដោយសារតែវាជាការដាក់ទោសមួយធ្ងន់ធ្ងរចំពោះជនជាប់ចោទដែលប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ដូច្នេះហើយវាជាចំណុចដែលគេអនុវត្តចំពោះអ្នកដែលត្រូវបានគេរកឃើញពិរុទ្ធភាពទៅលើបទល្មើសទាំងអស់នេះ ។

[០៩:៥០:00]

ខ្ញុំមិនមែនស្នើឡើងថា លោក អេដេម៉ូវិច នោះ គឺវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម ហើយវាដូចទៅនឹងឧក្រិដ្ឋកម្មនៅក្នុងតុលាការរបស់លោកនោះទេ ។ ប៉ុន្តែ ខ្ញុំលើកឧទាហរណ៍ គឺវាចំណុចដែលខ្ញុំចង់លើកឡើងដែលពីដំបូងគេបដិសេធថា ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះជាការប្រឌិតឡើង ហើយការដាក់ទោសក្នុងលក្ខណៈសមស្របនិងទាបដូច្នេះ គឺវាគេគិតទៅលើការដែលគាត់អនុវត្តការងារនៅក្នុងការកសង្កត់របស់គេ ។ ការកៀបសង្កត់ទៅលើរូបគាត់ ដែលគាត់បានលើកឡើងនោះ គឺគាត់លើកឡើងថា

គឺគេឲ្យគាត់ហ្នឹងតម្រង់ជួរដូចតែគ្នា ហើយគេឲ្យគាត់ហ្នឹងសម្លាប់ខ្លួនគាត់ផងដែរ ។ ដូច្នេះហើយ គឺគេបានលើកឡើងថា គាត់ក៏បានធ្វើការងារនៅក្នុងលក្ខណៈកៀបសង្កត់និងបង្ខិតបង្ខំពីមេរបស់គាត់។ ដូច្នេះ គេប្រើប្រាស់វិធីការពារបង្ខិតបង្ខំនេះ ដើម្បីធ្វើការបន្ថយទោសទៅលើករណីលោក អេដេម៉ូវិច ។

នៅពេលដែលខ្ញុំលើកឡើងចំណុចនេះ មិនមែនវាជាការលំបាកក្នុងការជឿនិងការទទួលស្គាល់ថា ជនរងគ្រោះទាំងឡាយ គឺក៏គេមានការមិនសប្បាយចិត្តទាក់ទងទៅនឹងពួកគាត់ ដោយសារតែគេលើកឡើងថាវាគឺជាការដាក់ទោសកម្រិតមួយទាបចំពោះបុគ្គលដែលបានប្រព្រឹត្តធ្វើឃាតកម្មទៅលើអ្នកដែលគេស្រឡាញ់។ ដូច្នេះហើយវាមានការពិបាកដែរសម្រាប់តុលាការក្នុងការពិចារណាទៅលើស្ថានភាពនេះ។

នៅពេលនេះ គឺខ្ញុំសូមលើកឡើងថា យើងត្រូវតែពិចារណានិងបំភ្លេចចោលទៅលើអ្វីដែលវាជាអារម្មណ៍របស់ជនរងគ្រោះ ដោយសារតែយើងជាតុលាការអន្តរជាតិត្រូវការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះផងដែរ ។

[០៩:៥២:២១]

**ស៖** សូមអរគុណសម្រាប់ការសង្កេតរបស់លោក លោកចៅក្រម ហ្គោលស្ទូន ។ យោបល់របស់ខ្ញុំបន្ថែមទៀត ទាក់ទងទៅនឹងពាក្យពីរមាត់ដែលលោកបានលើកឡើងនៅក្នុងការផ្តល់សក្ខីកម្មរបស់លោក ។ ពាក្យពីរមាត់នោះគឺ "វិប្បដិសារី" និង "ការសារភាពពិរុទ្ធភាព" ។ អ្វីដែលលោកសង្កេតឃើញថា ការសារភាពពិរុទ្ធភាព គឺវាទាក់ទងទៅនឹងវិប្បដិសារីចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើង ។ ដូច្នេះ ខ្ញុំសូមឲ្យលោកផ្តល់យោបល់ និងការសង្កេតទាក់ទងទៅនឹងវិប្បដិសារីដែលសម្តែងដោយស្មោះត្រង់ដែលធ្វើឡើងចំពោះជនរងគ្រោះដោយផ្ទាល់ ។ វិប្បដិសារីដែលប្រាប់ជនរងគ្រោះថា ខ្ញុំជាអ្នកទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មដែលទាក់ទងទៅនឹងលោក ឬក៏ទៅលើលោក ។ ទាក់ទងទៅនឹងវិប្បដិសារីទូទៅដែលវាទាក់ទងទៅនឹងឧក្រិដ្ឋកម្មខ្មែរក្រហម វាកើតឡើងនៅក្នុងរបបហ្នឹង ។ ថាតើវិប្បដិសារីហ្នឹងវាមានសារៈសំខាន់យ៉ាងម៉េចទៅលើជនរងគ្រោះ? ហើយយើងអាចទទួលស្គាល់នៅក្នុងបរិបទនៃការសារភាពពិរុទ្ធភាពយ៉ាងម៉េច? នេះជាសំណួរទីមួយរបស់ខ្ញុំ ។

សំណួរទីពីរ ថាតើពិរុទ្ធភាពដែលយើងសារភាព គឺវាមិនមានគុណសម្បត្តិចំពោះឧក្រិដ្ឋកម្មដាក់បន្ទុកមកលើខ្លួន និងឧក្រិដ្ឋកម្មដែលមានចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏យ៉ាងម៉េច? ហើយចំពោះការដែលលើកឡើងអំពីពិរុទ្ធភាពក្នុងលក្ខណៈទូទៅថា ខ្ញុំអាចទទួលខុសត្រូវទៅលើបទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ប៉ុន្តែ មិនមែនសារភាពជាក់លាក់ទៅលើឧក្រិដ្ឋកម្មដែលបានចោទ

ប្រកាន់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ ។ ថាតើតុលាការនឹងពិចារណាយ៉ាងម៉េចទៅលើចំណុចទាំងអស់នេះ?

**ឆ៖** វាពិបាកណាស់ចំពោះខ្ញុំ ដោយសារតែខ្ញុំមិនអាចពិចារណាទៅលើចំណុចនេះ ហើយដោយសារតែខ្ញុំមិនមានភស្តុតាងនិងពិនិត្យជាក់លាក់ទាក់ទងទៅនឹងការដែលលើកឡើង និងសារភាពដោយឌុច ។ ខ្ញុំមិនអាចផ្តល់ជាយោបល់ ថាតើចម្លើយសារភាពរបស់គាត់ឆ្លើយយ៉ាងម៉េចទៅនឹងឧក្រិដ្ឋកម្មដែលដាក់បន្ទុកទៅលើគាត់ ។

ដូច្នេះហើយវាជាការងាររបស់តុលាការរបស់លោកដែលត្រូវសម្រេច ។ ប៉ុន្តែ ខ្ញុំយល់ស្របទាក់ទងទៅនឹងវិធីសាស្ត្រដែលលោកបានលើកឡើងអម្បាញ់មិញក្នុងលក្ខណៈទូទៅ ។ គឺថាប្រសិនបើជាការទទួលផលប្រយោជន៍ពីការសារភាពពិរុទ្ធភាពនោះ គឺការសារភាពនោះគួរតែវាពាក់ព័ន្ធទៅនឹងការឆ្លើយសារភាពដោយស្មោះត្រង់ទៅលើចំណុចហ្នឹង ហើយការសារភាពស្មោះត្រង់នោះ គឺវាជាចំណុចសំខាន់ដែលយើងត្រូវយកមកពិចារណា ។

[០៩:៥៥:៤១]

**ស៖** សូមអរគុណច្រើន ហើយខ្ញុំប្រហែលជាអស់ម៉ោងហើយ ប៉ុន្តែនេះជាសំណួរចុងក្រោយដែលខ្ញុំសូមការអនុញ្ញាតសួរបន្ត ។ ខ្ញុំសូមបន្ថែមទៅលើចំណុចដែលលើកឡើងដោយលោកស្រីចៅក្រមខាតវ៉ាយថ៍ ។ ជនជាប់ចោទរូបនេះ បានលើកឡើងអំពីការបង្ខិតបង្ខំ និងបញ្ជាចេញពីមេរបស់គាត់ ដែលគាត់អះអាងមិនទទួលខុសត្រូវទាំងស្រុងទៅលើឧក្រិដ្ឋកម្មដែលគាត់បានចោទប្រកាន់ ។ ដូច្នេះហើយវាជាចំណុចដែលសហព្រះរាជអាជ្ញាមួយមិនយល់ស្រប មានការតវ៉ាគ្នាទៅលើចំណុចនេះ ។ ទាក់ទងទៅនឹងចំណុចនេះ ខ្ញុំសូមសួរយោបល់របស់លោកលើការសារភាពពិរុទ្ធភាព ។ ប៉ុន្តែ គេសម្តែងចេញឡើងប៉ុន្តែនៅតុលាការយូហ្គោស្លាវីនិងរ៉្វាន់ដា គេមិនទទួលស្គាល់ក្នុងករណីមួយចំនួន ។ ហើយខ្ញុំលើកឡើងអំពី ចេឡូសិច (Jelosic) ករណីហ្នឹងដែលគាត់ជាមេបញ្ជាការ គាត់បានសារភាពពិរុទ្ធភាព ប៉ុន្តែគាត់ត្រូវបានគេកាត់ទោសឲ្យជាប់គុកសែបសិបឆ្នាំ ។ រឿងក្តី ខំប៉ាន់ដា (Kambanda) នៅរ៉្វាន់ដា ដែលគាត់មានតួនាទីខ្ពស់នៅក្នុងរដ្ឋាភិបាល គាត់សារភាពពិរុទ្ធភាព ប៉ុន្តែតុលាការបានដាក់ទោសមួយជីវិតឲ្យគាត់ជាប់ពន្ធនាគារទៅលើរូបគាត់ ។ ហើយខ្ញុំសូមសួរសំណួរទាក់ទងទៅនឹងអង្គហេតុទាំងអស់នេះដែលកើតឡើង ថាតើវាអាចមានស្ថានភាពដែលថា ស្ថានទម្ងន់ទោសនោះវាធ្ងន់ធ្ងរពេក ហើយការបន្ធូរបន្ថយចំពោះការសារភាពទោស និងការសោកស្តាយ គឺវាមិនមានឥទ្ធិពលឡើយ ឬក៏មិនមានអានុភាពឡើយ

នៅក្នុងករណីដាក់ទោសនេះ ដូចដែលខ្ញុំបានលើកឡើងរឿងក្តីពីរមុនអម្បាញ់មិញ ។

[០៩:៥៧:០០]

**ឆ៖** ដូចដែលខ្ញុំបានបញ្ជាក់ វាជាការងាររបស់តុលាការនៅក្នុងរឿងក្តីទាំងពីរនោះ ។ ចំពោះខ្ញុំ យើងត្រូវតែពិចារណាទៅលើរឿងក្តីនីមួយៗតាមអង្គសេចក្តីរបស់វា វាពិបាកក្នុងការទាញឲ្យមានការប្រៀបធៀបគ្នារវាងស្ថានភាពមួយទៅស្ថានភាពមួយ ។ យើងត្រូវតែពិចារណាទៅលើអង្គហេតុ និងអង្គសេចក្តីនៃរឿងនីមួយៗ និងមូលដ្ឋានដែលឧក្រិដ្ឋកម្ម ការចោទប្រកាន់បទចោទផ្សេងៗ ហើយនិងការសារភាពទោសដែលបានធ្វើឡើង ហើយនិងពាក្យដែលគេសារភាពនោះ ថាតើវាជាការសោកស្តាយស្មោះត្រង់ ឬក៏យ៉ាងម៉េច?

ដូច្នេះហើយចំពោះខ្ញុំ តុលាការដែលដាក់ទោសនោះត្រូវតែពិចារណាទៅលើធាតុផ្សំទាំងអស់នេះ។ ហើយចំពោះយោបល់ ដែលខ្ញុំបានលើកឡើងពីដើម ការសម្រាលទោស ស្ថានសម្រាលទោសនោះ គឺវាជាយន្តការបន្ទាប់បន្សំទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ហើយវាជាផលប្រយោជន៍របស់ជនរងគ្រោះ ។

**ស៖** សូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំសូមសួរសំណួរចុងក្រោយ ។ ខ្ញុំសង្ឃឹមថា លោកប្រធានអនុញ្ញាត ។ លោកចៅក្រម ហ្គោលស្ទូន នៅពេលដែលខ្ញុំពិចារណាទៅលើច្បាប់សាលាក្តីអន្តរជាតិ ដែលវាជាបងប្អូននឹងតុលាការនេះ ការដែលគេពឹងផ្អែកចម្បងរបស់តុលាការទាំងអស់នោះទាក់ទងទៅនឹងការដាក់ទោស គឺទាក់ទងទៅនឹងការដែលរាងចាល ហើយទាក់ទងទៅនឹងការពិចារណារបស់តុលាការក្តីទាំងអស់នោះ គឺវាទាក់ទងទៅនឹងវិសាលភាពនៃឧក្រិដ្ឋកម្ម និងលក្ខណៈពិសេសរបស់តុលាការ ។ ដូច្នេះហើយពេលខ្លះទៅវាមានផលប៉ះពាល់ទៅលើសង្គមទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដោយសារតែគេត្រូវពិចារណាកុំឲ្យឧក្រិដ្ឋកម្មនោះប្រព្រឹត្តឡើងសាជាថ្មី ។ ប៉ុន្តែ នាពេលថ្មីៗនេះ មានការពិភាក្សាអំពីឥទ្ធិពល និងអានុភាពទៅលើការផ្សះផ្សាជាតិ ទាក់ទងទៅនឹងការសម្តែងវិប្បដិសារី និងការសារភាពពិរុទ្ធភាព ។

ខ្ញុំសូមស្នើយោបល់ សួរយោបល់របស់លោក ថាតើលក្ខណៈវិនិច្ឆ័យអត្តនោម័តិយ៉ាងម៉េចក្នុងការពិចារណាទៅលើអានុភាពនៃការសារភាពពិរុទ្ធភាពទៅលើការផ្សះផ្សាជាតិ និងក្នុងសង្គមក្រោយការមានជម្លោះកើតឡើង? ហើយជាពិសេសនោះ ថាតើអ្វីទៅដែលអង្គជំនុំជម្រះត្រូវតែធ្វើការពិចារណា ហើយស្វែងយល់អំពីការផ្សះផ្សាជាតិ ទៅលើអ្វីដែលបានពិភាក្សានៅទីនេះ?

[១០:០០:៥០]

ខ្ញុំសូមលើកឡើងថា វាត្រូវតែមានការទទួលស្គាល់ទៅលើការសោកស្តាយពីជនរងគ្រោះ ដែលជនរងគ្រោះ គឺគាត់មានវត្តមាននៅក្នុងតុលាការនេះ ។ ចំពោះលោកតើមានលក្ខណៈវិនិច្ឆ័យយ៉ាងម៉េចទៀត ក្រៅពីការសង្កេតរបស់ជនរងគ្រោះ ទាក់ទងទៅនឹងការទទួលស្គាល់នូវវិប្បដិសារីរបស់ជនជាប់ចោទនៅក្នុងការវិភាគពិចារណាទៅលើការផ្សះផ្សាជាតិ? ខ្ញុំសង្ឃឹមថា សំណួរនេះមិនស្មុគស្មាញទេ ។

**ឆ៖** បាទ, សូមអរគុណ ។ ខ្ញុំនឹងព្យាយាមឆ្លើយទៅនឹងសំណួររបស់លោកឲ្យបានច្បាស់ ។ ការផ្សះផ្សាជាតិ គឺកើតឡើង គឺមិនតែក្នុងបរិបទថាវាសំខាន់ទេ ប៉ុន្តែវាត្រូវពឹងផ្អែកទៅលើការទទួលស្គាល់ជាក់លាក់អំពីការសារភាពនិងវិប្បសារីរបស់ជនម្នាក់ ប៉ុន្តែ នៅក្នុងសង្គមសម្រាប់សង្គមទាំងមូល ។ អ៊ីចឹងយើងត្រលប់ទៅរកបទពិសោធអាហ្វ្រិកខាងត្បូង គឺមានជនរងគ្រោះជាច្រើនដែលឃើញថាខ្លួនមិនអាចមានដំណោះស្រាយអ្វី ដែលថាចារីមួយចំនួនត្រូវបានគេលើកលែងទោស ។ ហើយជាអកុសលនោះក្នុងស្ថានភាពអាហ្វ្រិកនោះ គឺថាការអភ័យទោសនោះ គឺមិនតម្រូវឲ្យមានទេ គឺមិនមានលក្ខខណ្ឌតម្រូវអំពីតម្រូវការនោះទេ ។ អ៊ីចឹងវាអាចនោះ គឺថាមានការសង្ស័យចំពោះគំនិតខ្ញុំ គឺថាតើធ្វើដូចម្តេចចំពោះជនរងគ្រោះនោះ ការទទួលស្គាល់ ឬក៏សារភាពដោយចារី ដោយជនល្មើសអំពីអំពើរបស់គាត់នោះ តើផលប៉ះពាល់ទៅលើសង្គមទាំងស្រុងហ្នឹងយ៉ាងដូចម្តេចនៅអាហ្វ្រិកខាងត្បូងហ្នឹង គឺត្រូវបានជួយដល់ការផ្សះផ្សាជាតិមួយចំនួននោះមែន ។ គឺថាបញ្ហាជាក់ស្តែងមួយចំនួននោះ គឺថាអាចនឹងដោះស្រាយបានជំនាន់មួយ ឬពីរបន្ទាប់មកក្រោយទៀតនេះ ។ អ៊ីចឹងនៅពេលដែលយើងពិនិត្យឃើញថាមានអំពើភ័យខ្លាច ការសោកស្តាយនៅក្នុងរបបអាប៉ាថេត ជាដើមនោះ ។ ប៉ុន្តែការបង្កើតនូវការពិត ហេតុការណ៍ដែលថាយើងមានប្រវត្តិតែមួយ ដែលបង្កើតជាប្រព័ន្ធអាប៉ាថេតនោះ ។ ប៉ុន្តែ ខ្ញុំពិនិត្យឃើញនូវស្ថាប័នមួយជាគណៈកម្មាធិការស្វែងរកការពិត គឺអាចយើងចេញពីកិច្ចប្រឹងប្រែងបែបនោះ ។ ហើយដើម្បីឆ្លើយតបទៅនឹង ថាតើផលប៉ះពាល់នៃការសារភាព ឬក៏វិប្បដិសារីហ្នឹងមានផលម៉េចទៅលើការផ្សះផ្សាជាតិនោះ គឺជាស្ថានភាពដ៏ស្មុគស្មាញមួយ ។ ប៉ុន្តែ ក្នុងន័យទូលំទូលាយនោះ ខ្ញុំអាចពន្យល់ថាតាមដែលខ្ញុំយល់នោះ គឺយើងត្រូវយល់ពីសារសំខាន់ អំពីការទទួលស្គាល់អំពីទស្សនៈ ហើយនិងការយល់ឃើញរបស់ជនរងគ្រោះ ផលប៉ះពាល់ទៅលើសង្គមនោះ គឺថាជាបរិបទមួយទូលំទូលាយ ។

[១០:០៤:០៨]

**លោក អាន់ីស អះមេដ៖**

សូមអរគុណ លោកចៅក្រម ហ្គោលស្ទូន ។ ហើយសូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

បាទ, ជាកិច្ចបន្តអង្គជំនុំជម្រះ ផ្តល់វេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ដែលសរុបមានពេលវេលាម្ភៃនាទីក្នុងការសួរសំណួរដល់អ្នកជំនាញរូបនេះ ប្រសិនបើមាន ។ ហើយមិនដឹងថាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង រៀបចំការតាំងសំណួរចំពោះអ្នកជំនាញតាមវិធីណាទេ ។

សូមអញ្ជើញ តើទទួលរួមគ្នា ឬក៏យ៉ាងម៉េច?

[១០:០៥:00]

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** សូមគោរពលោកប្រធាន។ មេធាវីផ្សេងទៀតអាចនឹងសួរសំណួរ ហើយខ្ញុំនឹងប្រើពេលទាំងអស់គ្នាមិនឲ្យលើសពីម្ភៃនាទីទេ ។ លោកប្រធាន អ៊ីចឹងខ្ញុំសូមអនុញ្ញាតបន្ត ។

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោកចៅក្រម ហ្គោលស្ទូន ។

**ឆ៖** សូមជម្រាបសួរ ។

**ស៖** ខ្ញុំឈ្មោះអាឡាំង វ៉ែនណឺ ខ្ញុំតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីមួយនេះ ។ ខ្ញុំសូមអនុញ្ញាតសួរដោយសង្ខេបហើយនិងខ្ញុំផ្តល់នូវជម្រាបជូនពីបរិបទសង្ខេបមួយពីទស្សនវិស័យរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងបន្តិច ហើយពីលោកស្រីចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ។

លោកស្រីចៅក្រមនោះបាននិយាយថាគឺជាការស្នើសុំរបស់យើងដែលថាជនជាប់ចោទ ឌុច មិនបានទទួលស្គាល់នូវអង្គហេតុមួយចំនួនជាក់លាក់នោះទេ អ៊ីចឹងហើយយើងត្រូវមានការសម្រេចជាចុងក្រោយគឺអង្គហេតុមួយចំនួននោះ គឺសំខាន់ណាស់ ។ ហើយជាបញ្ហាសំខាន់មែនទែនសម្រាប់កូនក្តីរបស់ខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយនៅក្នុងខែសីហា ដើមបណ្តឹងរដ្ឋប្បវេណីដប់ប្រាំនាក់ដែលបានមកតុលាការនេះ បានលើកឡើងជម្រាបជូនអង្គជំនុំជម្រះលើកលែង ពួកគាត់ទាំងអស់មានមួយចំនួនតូចទេដែលថាលើកលែងទោស ។ ប៉ុន្តែ គាត់មិនទទួលស្គាល់អំពីការសារភាពរបស់ជនជាប់ចោទនោះទេ ។

ខ្ញុំសូមអនុញ្ញាតអានអំពីផ្នែកពីរនៅក្នុងអត្ថបទរបស់លោក នៅក្នុងការពិនិត្យឡើងវិញនូវការសម្ភាសន៍នោះថាតើលោកនិយាយថាអ្វីៗបានកើតរួចមកហើយ តើលោកមានអ្វីចង់បន្ថែមទៀតទេចំណុចទីមួយនោះ គឺដែលអត្ថបទនៅក្នុងបោះពុម្ពផ្សាយនៅឆ្នាំ២០០១ នៅក្នុងសាកលវិទ្យាល័យច្បាប់ហើយនិងនយោបាយ ទំព័រ១២១ ហើយចំណងជើងអត្ថបទរបស់លោកនៅពេលនោះ គឺ "តួនាទីអង្គការសហប្រជាជាតិនៅក្នុងស្ថាប័នជំនុំជម្រះបទឧក្រិដ្ឋសង្គ្រាមអន្តរជាតិ"ជាពិសេសលោកនិយាយអំពីទស្សនៈរបស់លោក។ ខ្ញុំដកស្រង់សម្ដីរបស់លោក ។ នៅក្នុងថ្នាក់អន្តរជាតិនោះ ទំនាក់ទំនងដ៏សំខាន់រវាងការចោទប្រកាន់ព្រហ្មទណ្ឌអន្តរជាតិ ហើយនិងការថ្លឹងថ្លែងអំពីសន្តិភាព និងស្ថិរភាពគឺថាត្រូវតែពិនិត្យឲ្យបានច្បាស់អំពីសញ្ញាណនៃគោលការណ៍នីតិរដ្ឋដែលបង្កើតនូវការពិត ដើម្បីទប់ស្កាត់ការបដិសេធហើយនិងការសងសឹក ។ ដូច្នេះ ត្រូវដាក់នូវចារីទៅក្នុងបទឧក្រិដ្ឋអន្តរជាតិ ហើយផ្ដល់ប្រជាជនដែលទទួលរងគ្រោះឲ្យបាននូវគុណប្រយោជន៍មួយជាតួនាទីដ៏សំខាន់ក្នុងហ្នឹង ។ តើលោកអាចបញ្ជាក់បានអ្វីបន្ថែមទេនៅក្នុងនេះ?

[១០:០៨:៣៥]

**ឆ៖** ប៉ុន្តែ...

**ស៖** ចំណុចទីពីរដែលខ្ញុំចង់សួរនោះគឺថា អត្ថបទមួយដែលលោកបានផ្ដល់មតិយោបល់ទៅលើការសរសេរនូវសាស្ត្រាចារ្យ ត្រាំប៊ិលនោះ ហើយយើងអាចឃើញនៅក្នុងសារព័ត៌មានអន្តរជាតិ និយាយពីយុត្តិធម៌អន្តរជាតិនោះទំព័រ៤៥៧ដល់៤៥៨ ដែលលោកនិយាយអំពីការពិនិត្យសៀវភៅលើសាស្ត្រាចារ្យ ត្រាំប៊ិល នោះ ។ លោកនិយាយថា បញ្ហាដែលពាក់ព័ន្ធទៅនឹងការសារភាពទោសកំហុសហើយនិងការចរចារឿងទោសកំហុសនេះ គឺថាខ្ញុំធ្លាប់បានធ្វើជាសហព្រះរាជអាជ្ញារបស់តុលាការយូហ្គោស្លាវីវ៉ាន់ដា អន្តរជាតិ ខ្ញុំមិនស្វែងរកនីតិវិធីទទួលស្គាល់ ប៉ុន្តែអំពើឃោរឃៅនោះវាមានលក្ខណៈធំធេងណាស់មិនអាចទទួលស្គាល់អំពីចំណុចនោះទេ តើលោកអាចបំភ្លឺបន្ថែមអំពីចំណុចនោះបានទេ?

**ឆ៖** ខ្ញុំមិនបានឮច្បាស់ មិនឃើញថាភាពខុសគ្នារវាងវិធីដោះស្រាយដែលខ្ញុំបានកំណត់យកថាតើអ្វីដែលខ្ញុំត្រូវគោរពតាមនៅពេលនោះ ។ ប៉ុន្តែ អ្នកបន្តតំណែងក្រោយពីខ្ញុំជាប្រធាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី នោះគឺថានៅក្នុងរឿង អាប្ទូស៊ីស ហ្នឹងគឺថា បន្ទាប់មកទៀតនៅក្នុងរឿងក្ដី វ៉ាដូវ៉ាន់ ខារូស៊ិក ដែលជាប្រធានប្រមុខនៃរដ្ឋាភិបាលបូស្នៀ នោះហើយជននោះត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ហើយនិងបទឧក្រិដ្ឋផ្សេងទៀត ហើយគាត់ក៏បានសារភាពពិរុទ្ធ

ភាព។ ប៉ុន្តែ ព្រះរាជអាជ្ញាបានបញ្ជាក់អំពីការចោទប្រកាន់ធ្ងន់ៗដែលថា មនុស្សភាគច្រើនការកាត់ទោស ការផ្តន្ទាទោសនោះវាមានស្ថានស្រាលពេក ។ អ៊ីចឹងហើយដូចដែលខ្ញុំបញ្ជាក់ខាងដើមគឺថាបុគ្គលម្នាក់ មិនអាចនឹងសារភាពបានឲ្យគេទទួលស្គាល់ទេ កាលណាបទឧក្រិដ្ឋនោះវាមានលក្ខណៈធំធេងធ្ងន់ធ្ងរ ។ ប៉ុន្តែ ខ្ញុំមើលឃើញថាមិនអាចទទួលស្គាល់ មិនអាចទទួលថាជាភាគីអាចទទួលនោះទេ ដោយថាបើសិន ជាជនជាប់ចោទបានត្រៀមខ្លួនដើម្បីសារភាពទោសកំហុសហើយបានជួយក្នុងការស្វែងរកការពិតដូចជា ក្នុងដំណាក់កាលស៊ើបអង្កេត ដូចជាការជំនុំជម្រះប្រឆាំងនឹងគាត់ ឬក៏វិធីណាផ្សេងដែលនេះក្តី ជាចំណុច មួយដែលព្រះរាជអាជ្ញាត្រូវតែលើកឡើងជម្រាបដល់អង្គជំនុំជម្រះ ហើយផ្តល់សំណើដ៏សមស្របប្រសិន បើពិនិត្យទៅឃើញថា វាជាការចេញឡើងសុទ្ធចិត្ត ដោយស្មោះត្រង់មែននោះ ។ នេះហើយជាចំណុច មួយដែលថា ទាក់ទងទៅនឹងចំណុចដែលវាខុសគ្នាពីការចរចាបន្ធូរបន្ថយពិរុទ្ធភាពនោះ ។ ប៉ុន្តែព្រឹកមិញ នេះ ខ្ញុំបាននិយាយថា យើងត្រូវពិចារណាទៅលើចំណុចបីយ៉ាងដោយផ្អែកលើកត្តាមួយចំនួន ។ ប៉ុន្តែ ខ្ញុំ មិនស្នើជាគំនិតថាត្រូវធ្វើដូចម្តេចនោះទេ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកចៅក្រម ។ លោក រីឆាត ហ្គោលស្ទូន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបាទ អញ្ជើញមេធាវីក្រុមផ្សេងទៀត សូមអញ្ជើញ ។

[១០:១២:២៨]

**សួរដោយលោក គង់ ពិសី៖**

ជាបឋមខ្ញុំបាទសូមអរគុណលោកប្រធាន ។ ហើយសូមគោរពលោក លោកស្រីចៅក្រម ជាតិ និងអន្តរជាតិទាំងអស់ ។ ហើយក៏សូមជម្រាបសួរលោក រីឆាត ហ្គោលស្ទូន ។ ខ្ញុំបាទឈ្មោះ គង់ ពិសី ជាមេធាវីជាតិតំណាងឲ្យខាងក្រុមពីរផង ហើយនិងខាងក្រុមបួនផង ។ ខ្ញុំសូមសួរសំណួរតែពីរសំណួរ ទេ ។ ទាក់ទងទៅនឹងសំណួរទាំងនេះ ខ្ញុំសូមជូនដូចតទៅ៖

**ស៖** ទីមួយគឺលើកឡើងអំពីការ ពាក្យថា “ខមាទោស” ហើយនិងការទទួលសារភាព ។ អ៊ីចឹង ខមាទោស ហើយនិងទទួលសារភាពហ្នឹងវាខុសគ្នា ។ ការទទួលសារភាពទាល់តែព្រះរាជអាជ្ញា ឬក៏ អង្គជំនុំជម្រះហ្នឹងដាក់បន្ទុកទៅលើគាត់សឹងថា កៅសិបប្រាំ ទៅកៅសិបប្រាំបួន ឬក៏មួយរយភាគរយ ដើម្បីឲ្យឃើញថា លើសពីវិមតិសង្ស័យទើបគាត់ទទួលទោស ទទួលសារភាព ។ និយាយតែពីការទទួល

សារភាពអ៊ីចឹង គាត់មិនបានទទួលសារភាពចេញពីដួងចិត្តគាត់ដោយស្មោះទេ មកពីយើងដាក់បន្ទុកគាត់ ដោយគាត់គេច មិនរួចទើបគាត់ទទួលសារភាព ។ នេះគឺជាការទទួលសារភាព ។

រីឯខមាទោសៗហ្នឹងគឺថា ជាការចេញពីដួងចិត្តរបស់គាត់ ហើយយើងបានប្រៀបធៀបទៅទៀតថា យើងយល់ហើយនៅក្នុងន័យច្បាប់។ ប៉ុន្តែ នៅសម្មតិកម្មដែលលោកបានលើកឡើងថា ជនជាប់ចោទមួយបាញ់គេដល់ចិតសិបនាក់ស្លាប់ ហើយខ្លួនឯងទទួលទោសទៅពីប្អូនទៅប្រាំពីរឆ្នាំប៉ុណ្ណោះ ។ នេះគឺថាវាមិនមានតុល្យភាពគ្នាទាល់តែសោះ ។

អ៊ីចឹងសួរថា នៅក្នុងប្រទេសនោះដែលគាត់ទទួលខមាទោសហ្នឹង តើធ្វើយ៉ាងម៉េច? របៀបម៉េចដើម្បីឲ្យញាតិសន្តានជនរងគ្រោះដែលគាត់នៅរស់ហ្នឹងគាត់ស្ងប់ចិត្តៗទៅបាន? នេះគឺជាសំណួរទីមួយ។ សំណួរទីពីរខ្ញុំសូមសួរពីសំណងរដ្ឋប្បវេណីថា តើមានសំណងរដ្ឋប្បវេណីដែរឬទេ?ហ្នឹងទីមួយ ។

បើមាន តើគេធ្វើយ៉ាងដូចម្តេច? តែបើគ្មានវិញហេតុអ្វីបានជាគ្មានសំណងរដ្ឋប្បវេណី? ខ្ញុំមានពីរចំណុចតែប៉ុណ្ណឹងទេ សូមអរគុណ ។

[១០:១៥:០៥]

**ឆ៖** សូមអរគុណ ។ ប៉ុន្តែចំណុចទីមួយនោះ ខ្ញុំអាចហ្នឹងគិតឃើញថាមិនទាក់ទងទៅនឹងបញ្ហាដែលពាក់ព័ន្ធទៅនឹងអ្វីដែលយើងនិយាយ ។ ប៉ុន្តែ វាមានការងាយស្រួលដើម្បីឲ្យជនម្នាក់ដែលថា ទទួលសារភាពអំពីពិរុទ្ធភាព ហើយធ្វើខមាទោស ។ ប៉ុន្តែ ពេលខ្លះមានការលំបាកក្នុងការវិនិច្ឆ័យ ឬក៏ពិចារណាថាតើការហ្នឹងវាពិតស្មោះពីចិត្តរបស់គាត់ដែរឬទេ? ប៉ុន្តែ ចំណុចសំខាន់មួយគឺយើងមើលទៅលើខ្លឹមសារនៃការសារភាពនោះ និងការថ្លែងរបស់គាត់ហ្នឹង ។ អាហ្នឹងហើយជាចំណុចសំខាន់ដល់ជនរងគ្រោះ ហើយនិងការទទួលស្គាល់អំពីអ្វីដែលបានកើតឡើងទៅអ្នកដែលបាត់បង់ជីវិតដែលជាសាច់ញាតិរបស់គេនោះ ។ នេះហើយជាកត្តាសំខាន់ដើម្បីឲ្យការទទួលស្គាល់អំពីហេតុការណ៍នោះ ។ ហើយអំពីការរងគ្រោះ ហើយនិងអំពើអកុសលដែលកើតចំពោះពួកអ្នកទាំងនោះ ។

អ៊ីចឹងអ្វីជាខមាទោសដែលថានៅក្នុងចំណុចម្ខាងនៃកត្តាដែលយើងត្រូវពិចារណាដែលថាអាចស្ពានសម្រាលក្នុងការផ្តន្ទាទោសនោះ។ ប៉ុន្តែចំណុចនៃការសំណងជំងឺចិត្តគឺជាកត្តាសំខាន់មួយគឺមិនមែនសម្រាប់តែជនរងគ្រោះទេ ប៉ុន្តែសម្រាប់ការផ្សះផ្សាជាតិនោះផងដែរ ។ ប៉ុន្តែ ជាទូទៅគឺយើងនិយាយពីការសំណងនោះវាទាក់ទងទៅនឹងហិរញ្ញវត្ថុ សម្រាប់ការទូទាត់ចេញសំណងជាដើមហ្នឹង ។ នេះជាបញ្ហានៅក្នុងទ្វីបអាហ្វ្រិកខាងត្បូងហ្នឹងដែលថាអតីតរដ្ឋាភិបាលអាប៉ាថេត នោះគឺជាដំបូងនោះគឺទាក់ទងទៅ

នឹង-- បន្ទាប់មកគឺមានប្រធានាធិបតី និលស៊ុន ម៉ាន់ដឺឡា ដែលបន្ត ។ ប៉ុន្តែគេពិនិត្យមើលស្ថានភាពជនរងគ្រោះនោះ ភាគច្រើននៃជនជាតិអាហ្វ្រិកខាងត្បូងដែលថារងគ្រោះដោយរបបអាប៉ាថេត នោះប៉ុន្តែគេជាជនរងគ្រោះដោយខ្លួនគេផ្ទាល់នៅក្នុងរបបនោះ ។ ប៉ុន្តែ បញ្ហានោះគឺរដ្ឋាភិបាលរបស់គេជាអ្នកត្រូវចេញសំណងចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តប្រឆាំងទៅលើពួកគេនោះ ដោយរដ្ឋាភិបាលអាប៉ាថេតហ្នឹង ។ ហើយវាជំរុញឲ្យមានការមិនចូលចិត្ត ឬក៏ការប្រឆាំងខាងនយោបាយជាច្រើនទាក់ទងទៅនឹងការចេញសំណងនោះ កាលណាជនរងគ្រោះមិនបាន បង្ហាញត្រឹមត្រូវទេ ។

ប៉ុន្តែក្រោយមកគឺគេរកឃើញថា ជនរងគ្រោះមិនបានបង្ហាញអ្វីឲ្យគ្រប់គ្រាន់នោះទេ ។ ប៉ុន្តែ ការសំណងដើម្បីថាតើជួយដល់អ្នករស់រានមានជីវិតនៅក្នុងការអប់រំ ឬក៏ធ្វើដូចម្ដេច? នេះគឺជាកត្តាសំខាន់មួយ ។ ប៉ុន្តែ ដោយជាក់ស្ដែងនោះ វាអាស្រ័យទៅលើស្ថានភាពរបស់ប្រទេសនីមួយៗ ប្រទេសដែលពាក់ព័ន្ធដូចដែលខ្ញុំបានលើកឡើងអ៊ីចឹងគឺថា ធនធានហិរញ្ញវត្ថុដែលមាន ។ ប៉ុន្តែ ទាក់ទងទៅនឹងសំណងដែលអាចធ្វើទៅបានគឺថា បើអាចធ្វើទៅបានជាកត្តាសំខាន់ណាស់វាមានប្រយោជន៍ដើម្បីជួសជុលសង្គមដែលបែកបាក់ហ្នឹងឡើងវិញបានខ្លះ ។

[១០:១៨:៤៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ក្រុមបន្តទៀត ក្រុមបី បើមានសូមអញ្ជើញ ។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** សូមជម្រាបលោកចៅក្រម ហ្គោលស្តូន! ខ្ញុំនឹងនិយាយសង្ខេបបន្តិច ។ លោកមានបទពិសោធន៍នៅក្នុងសាលាក្ដីពិសេស ហើយយើងឯកភាពថាការសារភាព ហើយនិងការទទួលសារភាពពិរុទ្ធភាពជាចំណុចសំខាន់ចំពោះជនរងគ្រោះ ។ តើលោកអាចជម្រាបបានទេ តើវាមានផលប៉ះពាល់អ្វីទៅលើការផ្សះផ្សាជាតិដែលយើងឃើញនៅក្នុងស៊ីឌី ដែលបានចែកជូនឲ្យមកយើងខ្ញុំនឹង ទៅឲ្យដល់ពួកស៊ីប ទៅម៉ូស្លីមស៊ីប ហើយនិងបូស្នៀហ្នឹង តើគេអាចហូបតែ កាហ្វេ ជាមួយគ្នាបានទេ? តើហេតុ-ការណ៍ដែលកើតនៅក្នុងអតីតកាលនៅក្នុងអារូហ្សា នោះតើវាអាចមានការផ្សះផ្សាជាតិទេក្រោយពីមានសំណងនោះ?

[១០:២០:០០]

**ឆ៖** តើសំណួរនោះ ទាក់ទងទៅនឹងវ៉ាន់ដា ឬដូចម្ដេច?

**ស៖** ទេ, សំណួរនោះគឺទាក់ទងទៅនឹងផលប៉ះពាល់នៅក្នុងប្រទេស ដែលមានសាលាក្តី ដូចជាសាលាក្តីពិសេសត្រូវបានបង្កើតឡើងដើម្បីជម្រះក្តីអតីតយូហ្គោស្លាវីហើយនិងនៅរ៉្វាន់ដាផងដែរ ពីព្រោះថាតុលាការនោះ វានៅក្នុងអារូហ្សា តើផលប៉ះពាល់អ្វីទៅលើរ៉្វាន់ដា? សេចក្តីសម្រេចនោះ ត្រូវបានធ្វើតើមានការសារភាពពីពិរុទ្ធភាព ថាតើការធ្វើបែបនោះ អាចនឹងមានអត្ថប្រយោជន៍ដល់ការផ្សះផ្សាជាតិឬទេ?

**ឆ៖** ខ្ញុំជឿ ។ ដូចដែលខ្ញុំនិយាយខាងដើម ។ ប៉ុន្តែ ចំណុចសំខាន់បំផុតនោះគឺការបញ្ចប់នូវការបដិសេធដែលប្រឌិតឡើង ដែរថានៅពេលដែលមានវិវាទនោះ ក្រុមៗធំបីមាន ក្រូអាត, មានប៊ូស្នៀ ហើយនិងមានពួកស៊ើប ។ អ្នកទាំងបីហ្នឹងគឺអះអាងថាគេជាជនរងគ្រោះ ហើយសុំសំណងពីភាគីម្ខាងៗទៀត ។ ហើយខ្ញុំពិនិត្យឃើញថាការងាររបស់តុលាការអតីតយូហ្គោស្លាវីនោះ គឺបានទទួលស្គាល់ថាគឺពួកគេជាជនរងគ្រោះផង ជាចារីផងនៅក្នុងចំណោមពួកគេហ្នឹង ។ ដូច្នេះ ខ្ញុំយើងអាចឃើញថា យើងត្រូវពិនិត្យមើលចំណុចមួយសំខាន់ដែលថាសំណងនោះ វាជាកត្តាដែលអាចនឹង-- ការសារភាពនោះ វាជាកត្តាមានប្រយោជន៍ដល់ការផ្សះផ្សាជាតិ ប៉ុន្តែនៅក្នុងដំណាក់កាលដែលមានសន្តិភាព ។ ក្នុងករណីរ៉្វាន់ដាដែលមានសាលាក្តីសម្រាប់រ៉្វាន់ដានោះ មានមនុស្សជាច្រើន អ្នកខ្លះនៅរ៉្វាន់ដា ហើយអ្នកខ្លះនៅក្នុងប្រទេសអឺរ៉ុបដែលបដិសេធថាមិនមានប្រល័យពូជសាសន៍ទេ ។ ប៉ុន្តែ មនុស្សភាគច្រើនបាននិយាយថាគឺថាជាការប្រយុទ្ធគ្នាទៅវិញទៅមក ដែលមនុស្សមួយចំនួនច្រើនដែរថាហេតុការណ៍ហ្នឹងវាកើតឡើងជាហេតុការណ៍ជម្លោះ ។ អ៊ីចឹងគឺជាការដែលថាប៉ះពាល់ ប៉ះទង្គិចគ្នាតាមពាក្យសម្តីដែលចាប់ផ្តើមពីដំបូងនោះ ។ ប៉ុន្តែ ខ្ញុំគិតថាការងាររបស់សាលាក្តីព្រហ្មទណ្ឌសម្រាប់រ៉្វាន់ដានោះ គឺថាអាចនឹងអាចបញ្ចប់នូវការបដិសេធបែបនោះ ។ ហើយថ្ងៃនេះនិយាយអំពីការទទួលស្គាល់នោះ គឺគ្រប់ភាគីទាំងអស់នៅរ៉្វាន់ដានិងនៅក្នុងក្រៅរ៉្វាន់ដានៅក្នុងឆ្នាំ១៩៩៤ វិញ គឺយើងមានការរៀបចំដោយប្រុងប្រយ័ត្ន ហើយនិងពិនិត្យមើលអំពីករណីដែលថាមានប្រល័យពូជសាសន៍ដែលកើតឡើងតែក្នុងរយៈពេលមួយរយថ្ងៃ ហើយវាមានជនរងគ្រោះច្រើនអ៊ីចឹងការងាររបស់សាលាក្តីក្នុងរឿងក្តីទាំងពីរនោះ គឺវាមានផលវិជ្ជមានច្រើន ។

នៅក្នុងរ៉្វាន់ដា គេបានបង្កើតលទ្ធភាពនូវការប្រើនូវប្រព័ន្ធត្រួតពិនិត្យ ដើម្បីនីតិវិធីតាមទំលាប់នៅក្នុងរ៉្វាន់ដាដើម្បីពន្លឿននីតិវិធីយុត្តិធម៌សម្រាប់មនុស្សរាប់ម៉ឺននាក់ដែលត្រូវបានគេដាក់ឃុំឃាំងនោះ ។ អ៊ីចឹងហើយ ហើយវាអាចជួយទៅតាមរបៀបមួយដែលប្រព័ន្ធនោះ វាធ្វើទៅបាននោះដែរ ។

[១០:២៤:១១]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ប្រសិនបើមាន?

សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោកចៅក្រម ហ្គោលស្ទូន។

**ស៖** សូមអរគុណដែលលោកបានផ្តល់សក្ខីភាព សក្ខីកម្មព្រឹកនេះដើម្បីថានេះជាចំណុចដ៏សំខាន់ ហើយសំណួរដែលខ្ញុំនឹងសួរទៅលោកនុ៎ង គឺថាអាចមានលក្ខណៈប៉ះពាល់ផ្លូវចិត្ត ឬក៏ថាមានកលល្ខណៈរសើបបន្តិច ។ យើងខ្ញុំនឹងព្យាយាមទាញឲ្យជិតទៅនឹងស្ថានភាពពិតនៃរឿងក្តី ដែលយើងកំពុងដំណើរការនៅទីនេះ ទាក់ទងទៅនឹងតុលាការ ហើយនិងធាតុផ្សំផ្សេងៗដែលលោកមិនមានឯកសារ ឬក៏អង្គហេតុជាក់ស្តែងនៅក្នុងដៃ ។ ប៉ុន្តែ ដើម្បីបំភ្លឺអ្វីដែលយើងបានពិភាក្សា ហើយដើម្បីកំណត់នូវសំណួរទូទៅមួយចំនួនដែលខ្ញុំនឹងសួរទៅលោកនោះ ។

ខ្ញុំសូមជម្រាបលោក ជូនលោកឲ្យបានច្បាស់ជាមុនសិនថា តាមពិតជារឿងក្តីចំណុចមួយដែលចៅក្រម ខាត់វ៉ាយថ៍ បានលើកឡើងហើយថា ឌុច បានទទួលស្គាល់ពីការទទួលខុសត្រូវរបស់គាត់ចំពោះអង្គហេតុទាំងស្រុងដែលបានចោទឡើងប្រឆាំងគាត់ ទោះបីជាព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីនៅតែចាត់ទុកថាគាត់មិនបាននិយាយឲ្យបានគ្រប់គ្រាន់នោះក៏ដោយ ។ ប៉ុន្តែ ដើម្បីឲ្យអ្វីៗវាមានភាពច្បាស់លាស់ សូមជម្រាបសួរទៅលោកថា យើងខ្ញុំសូមបញ្ជាក់ថាចៅក្រមស៊ើបអង្កេតដែលបានស្តាប់ ឌុច ហ្នឹង គឺច្រើនជាងមួយឆ្នាំមកហើយ ដោយមានវត្តមានរបស់សហព្រះរាជអាជ្ញានោះផងដែរ។ សហចៅក្រមស៊ើបអង្កេតទាំងអស់នេះ ដែលបានរៀបចំនូវការសម្តែងឡើងវិញ នៅទីតាំងមួយចំនួនជាកន្លែងដែលប្រព្រឹត្តបទល្មើស ។ នៅក្នុងវត្តមាន នៅទីនោះ ដែលមានវត្តមានជនជាប់ចោទ វត្តមានរបស់សហព្រះរាជអាជ្ញា ហើយនិងវត្តមានរបស់អ្នករួចរស់រានមានជីវិតមួយចំនួន ។

សហចៅក្រមស៊ើបអង្កេតទាំងនោះបានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនដោយមានចេញដីកាដំណោះស្រាយមួយនៅតាមប្រព័ន្ធស៊ីវិលឡូ ដែលចែងដូចតទៅនៅក្នុងកថាខណ្ឌ១៦៧៖

ឌុច តែងតែទទួលស្គាល់ពីការទទួលខុសត្រូវរបស់គាត់ ថាគាត់ជាប្រធានស-២១ ចំពោះបទឧក្រិដ្ឋ

ដែលបានកើតឡើងនៅក្នុងទីនោះ ។ គាត់បានពន្យល់ថា ថាគាត់បានទម្លាយការពិតនោះក្នុងឆ្នាំ១៩៩៩ ដើម្បីជូនជាព័ត៌មានដល់លោកមុនពេលដែលគេចាប់ខ្លួនគាត់នោះ ដោយសារមានហេតុការណ៍ថាគាត់មានអារម្មណ៍ថា ខ្លួនគាត់មិនអាចលាក់កំបាំងពីការពិតដែលកើតឡើងនៅស-២១ បាននោះតទៅទៀតទេ ។ បន្ទាប់បានឮសេចក្ដីថ្លែងការណ៍ធ្វើឡើងដោយ ប៉ុល ពត ដែលបដិសេធអំពីថាមិនមានស-២១ ទេនោះ ។ ហើយគាត់នោះ អះអាងថានោះគឺជាការប្រឌិតឡើងរបស់វៀតណាមនោះទេ ។ ហើយចៅក្រមបានបន្ថែមទៀតថា តាមធម្មតា ឌុច បានសម្ដែងនូវការសោកស្ដាយវិប្បដិសារីចំពោះក្រុមគ្រួសារ ហើយនិងជនរងគ្រោះ ហើយនិងអតីតបុគ្គលិកស-២១ ដែលធ្លាប់នៅក្រោមបង្គាប់របស់គាត់ផងដែរ ។ នៅក្នុងកថាខណ្ឌដូចតទៅនេះ៖

ចៅក្រមបានបញ្ជាក់បន្ថែមទៀតថា ឌុច បានសហការណ៍ដោយស្ម័គ្រចិត្តនៅក្នុងដំណាក់កាលស៊ើបអង្កេត និងបដិសេធមិនឆ្លើយដាក់ទៅអ្នកណាម្នាក់ដែលជាកូនចៅនៅក្នុងក្រោមបង្គាប់របស់គាត់ទេ ហើយដាក់ការទទួលខុសត្រូវមួយចំនួនដែលថាជាថ្នាក់លើរបស់គាត់ជាអ្នកបញ្ជាឲ្យគាត់ធ្វើការងារនោះ។ ហើយខ្ញុំក៏សូមបន្ថែមទៀតថា ការបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះនេះនៅក្នុងដំណើរការនីតិវិធីដូចចៅក្រម ខាតវ៉ាយថ៍ បានមានប្រសាសន៍ គឺគាត់បានបន្តកិច្ចសហការណ៍របស់គាត់ជានិច្ច ។

ឌុច ទទួលស្គាល់ប៉ែតសិបប្រាំភាគរយនៃអង្គហេតុដែលបានចោទឡើងប្រឆាំងគាត់ ដោយសហព្រះរាជអាជ្ញា ។ ហើយនៅទីបំផុតអ្នកជំនាញខាងចិត្តសាស្ត្រនិងអ្នកចិត្តសាស្ត្រផ្លូវចិត្ត បានបង្ហាញនៅក្នុងតុលាការថា ឌុច គឺជាមនុស្សដែលបញ្ជាក់ពីគំនិតថា គាត់មានការបដិសេធពីមុន ប៉ុន្តែឥឡូវនេះ គាត់នៅក្នុងដំណាក់កាលផ្លូវចិត្តរបស់គាត់ ក្នុងការទទួលស្គាល់ការពិត ។

[១០:៣១:២៧]

នេះគឺជាព័ត៌មានសាមញ្ញ ដើម្បីជម្រាបជូននូវព័ត៌មានសង្ខេបដើម្បីឲ្យលោកបានជ្រាបគ្រួសៗ ។ ហើយហេតុអ្វីបានចង់បានសក្ខីកម្មពីលោកនោះ គឺថាយើងមានទទួលអារម្មណ៍ថា គឺថាយើងអាចនឹងបានមតិយោបល់ ថាតើជនម្នាក់ដែលបានសម្ដែងខមាទោសដោយសុទ្ធចិត្ត ហើយបានស្វែងរកការអភ័យទោសអំពីជនរងគ្រោះ ។ ប៉ុន្តែការិយាល័យសហព្រះរាជអាជ្ញានៅភ្នំពេញ មិនទាន់បានយល់ច្បាស់អំពីការសារភាពពីពិរុទ្ធភាព ហើយជនរងគ្រោះមិនឮអំពីសំណើដើម្បីសុំអភ័យទោសនោះទេ ។

ចំណុចទាំងអស់នេះហើយទើបខ្ញុំចង់សួរលោកនូវសំណួរសាមញ្ញមួយចំនួនទាក់ទងទៅនឹងយុត្តាធិការរបស់តុលាការដែលមានសហព្រះរាជអាជ្ញាចូលរួមនៅក្នុងទីនេះ ។ លោកចៅក្រមបាននឹកឃើញ

បានរំឭកអំពីរឿងក្ដី អេដេម៉ូវិច ហើយលោកចៅក្រមបានលើកឡើងថា អេដេម៉ូវិច បានសារភាពទោស នៅក្នុង សាប្រេនីហ្សា ហើយគាត់ត្រូវបានគេចោទអំពីការសម្លាប់ជនរងគ្រោះចិតសិបរូប ។ ហើយខ្ញុំក៏មានបំណងនិយាយអំពីរឿងក្ដី អុប្រ៊ែណូវិច (Obrenovic) ។ អុប្រ៊ែណូវិច គឺទទួលរងការចោទប្រកាន់ទៅលើបុគ្គលប្រាំពីរពាន់នាក់ក្នុងមួយសប្ដាហ៍តែប៉ុណ្ណោះ ហើយគាត់បានសារភាពពិរុទ្ធភាពតាំងតែពីដំបូង ។

អង្គជំនុំជម្រះបានលើកឡើងនៅក្នុងសាលក្រមរបស់ខ្លួនដូចតទៅ ឧទាហរណ៍នៅក្នុងកថាខណ្ឌ ១១៥៖

អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ដោយសារការទទួលខុសត្រូវទៅលើពិរុទ្ធភាព និងការអ្វីដែលគាត់បានធ្វើ លោក អុប្រ៊ែណូវិច មិនដែលមានការយកលេសទៅលើខ្លួនគាត់ ហើយគាត់ក៏មិនដែលចៀសវាងនិងគេច ចេញពីការទទួលខុសត្រូវរបស់គាត់ទៅលើបុគ្គលទាំងឡាយនោះឡើយ។ ដោយពិចារណាទៅលើចំណុចទាំងអស់នេះហើយ អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ការសារភាពអំពីពិរុទ្ធភាពរបស់លោក ត្រាហ្កាន អុប្រ៊ែណូវិច គឺវាជាតំណាងស្ថានសម្រាលទោស ដោយសារតែការសារភាពពិរុទ្ធភាព វាជួយទៅដល់ការលាតត្រដាងនិងការបង្ហាញនូវការពិត ការផ្សះផ្សាជាតិ។ ហើយដោយសារតែ ត្រាហ្កាន អុប្រ៊ែណូវិច បានធ្វើការសារភាព និងទទួលស្គាល់ដោយមិនមានការស្ទាក់ស្ទើរទៅលើការទទួសខុសត្រូវផ្ទាល់របស់គាត់ចំពោះតួនាទីរបស់គាត់ នៅក្នុងពេលដែលមានការចោទប្រកាន់។

លោកចៅក្រម ហ្គោលស្ទូន ពីខាងមេធាវីការពារយើងពិចារណាថា ត្រាហ្កាន អុប្រ៊ែណូវិច ហើយនិង ឌុច ហ្នឹង គឺវាករណីដូចគ្នា ។

ដូច្នេះ ចំពោះខ្ញុំ សំណួរដំបូងរបស់ខ្ញុំ លោកចៅក្រម យុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិគេត្រូវពិចារណាទៅលើលក្ខណៈពិតប្រាដកនៃការសោកស្ដាយ វិប្បដិសារី ដែលបានសម្ដែងឡើង ហើយនៅក្នុងករណីជាច្រើន គាត់បានបង្ហាញអំពីវិប្បដិសាររបស់គាត់ថា តើវាជាកម្រិតនៃការសហការ ឬក៏យ៉ាងណា? ដែលបានផ្ដល់ជូនទៅដល់ខាងករិយាល័យសហព្រះរាជអាជ្ញានិងចៅក្រម ។ តើលោកចៅក្រមអាចបញ្ជាក់បានដែរឬទេ ថាកម្រិតនៃការសារភាពនោះ គឺវាការដែលយើងអាចបញ្ជាក់បានអំពីកម្រិត និងវិប្បដិសារីទាំងឡាយដែលគាត់បានបញ្ជាក់ ។

**ឆ៖** ជាការពិត គឺខ្ញុំយល់ស្របទៅនឹងបុព្វបទ ឬចំណុចដំបូងដែលលោកបានលើកឡើងទៅនឹងសំណួររបស់លោក ហើយខ្ញុំក៏យល់ស្របទាក់ទងទៅនឹងការសារភាព និងវិសាលភាពនៃការសារភាព

នោះផងដែរ ដែលបានពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង ។

**ស៖** ចំពោះខ្ញុំផ្ទាល់ ទាក់ទងទៅនឹងការយល់ព្រមគ្នាទៅលើការសារភាពពិរុទ្ធភាពនៅប្រទេសមួយ ដែលគេបានពិចារណាទៅលើខ្សែភាពយន្តរៀបចំឡើងដោយសាលាក្តី អារូហ្សា ដែលវាទាក់ទងទៅនឹងការផ្សះផ្សាជាតិនៅទីនោះផងដែរ គឺវាទាក់ទងទៅនឹងវិសាលភាពនៅប្រទេសរ្វ៉ាន់ដា ដែលការសារភាព ពិរុទ្ធភាពនៅ អារូហ្សា គឺវាអាចជួយទៅដល់ការផ្សះផ្សាជាតិនៅរ្វ៉ាន់ដា ។ នៅពេលដែលខ្ញុំធ្វើការចរចាទៅលើការសារភាពពិរុទ្ធភាពជាមួយនឹងសហសេវិករបស់លោកនៅការិយាល័យអយ្យការនៅពេលនោះ យើងបានយល់ស្របគ្នាថា ព្រះរាជអាជ្ញានឹងធ្វើការបោះបង់ចោលទៅលើបទចោទមួយចំនួនដែលការបង្ហាញភស្តុតាងនោះ វាមិនមានលក្ខណៈច្បាស់លាស់ ហើយចំណុចនោះធ្វើឡើងក្នុងគោលការណ៍ដែលវាមានភាពចាំបាច់ទាក់ទងទៅនឹងការសារភាពពិរុទ្ធភាពចំពោះបទចោទធំៗទាំងឡាយ ហើយនៅក្នុងការសារភាពពិរុទ្ធភាពចំនួនពីរនៅពេលដែលយើងចរចានិងយល់ស្របគ្នា យើងខ្ញុំបានធ្វើការយល់ស្របជាមួយ នឹងអយ្យកានៅពេល-- នៅទីនោះដើម្បីបោះបង់ចោលបទចោទមួយចំនួន ហើយពិចារណា និងផ្តោតទៅលើបទចោទទាំងឡាយធំៗដែលបានទាក់ទងទៅនឹងការសារភាពអំពីពិរុទ្ធភាព ។ ហើយតើលោកអាចយល់ឃើញទេថា ការសារភាពនៅទីនេះមិនមែនជាអ្វីដែលពន្លើសនោះទេ ហើយវាអាចឲ្យជនជាប់ចោទក្នុងការទទួលស្គាល់ទៅលើអង្គហេតុទាំងឡាយដែលគាត់បានបង្ហាញអំពីពិរុទ្ធភាពរបស់គាត់ ហើយដើម្បី ឲ្យខាងសហព្រះរាជអាជ្ញាអាចយល់អំពីលក្ខណៈនៃការភាពទោសដែលបានជំទាស់ទៅលើជនជាប់ចោទ ឬក៏អ្វីដែលវាទាក់ទងទៅនឹងអង្គហេតុមិនមានភស្តុតាងគ្រប់គ្រងក្នុងការដែលយើងស្វែងរកការពិត ។

[១០:៤០:៣១]

**ឆ៖** ការយល់ឃើញរវាងការចរចាទោសមួយផ្នែក និងការសហការគ្នាទៅលើការសារភាពទោស និងការសោកស្តាយ ។ ខ្ញុំហាក់ដូចជាមិនយល់ឃើញថា វាស្របគ្នានោះទេ ។ ខ្ញុំទទួលស្គាល់ថាការចរចាពិរុទ្ធភាពអាចជាប្រយោជន៍ ហើយការសារភាពទោស ក៏វាជាប្រយោជន៍ផងដែរ ។

នៅក្នុងករណីមួយចំនួនដែលវាប៉ះពាល់ទៅនឹងការចរចាពិរុទ្ធភាព ហើយជាបញ្ហាបច្ចេកទេស ហើយនិងគេនៅក្នុងការចរចាទោស គឺគេបានបោះចោលទៅលើបទចោទមួយចំនួនដែលវាមានផលអវិជ្ជមានចំពោះជនជាប់ចោទ ។ ហើយនៅក្នុងអង្គជំនុំជម្រះសាលាដំបូងដែលគេពិចារណាទៅលើអង្គហេតុ និងការសម្តែងភាពស្មោះត្រង់ទៅលើការសោកស្តាយនោះ គឺវាអាស្រ័យទៅលើករណីទាំងអស់ហ្នឹង ។

**ស៖** សូមអរគុណលោកចៅក្រម ដែលលោកបានលើកឡើងទៅលើចំណុចទាំងអស់នេះ ដែលថាការចរចាពិរុទ្ធភាព គឺគេដាក់ជូនអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះត្រូវតែសម្រេចទៅលើការចរចាពិរុទ្ធភាពទាំងអស់នោះ ថាតើការយល់ស្របគ្នាទៅលើការសារភាពនោះ វាស៊ីគ្នាហើយនិងត្រូវគ្នាទៅនឹងគោលបំណងនៃការស្វែងរកយុត្តិធម៌ដែរឬទេ? តាំងពីព្រឹកមិញ គឺមានសំណួរជាច្រើនបានដាក់ជូនលោកចៅក្រម ហើយលោកចៅក្រមបានលើកឡើងទៅលើករណីជនរងគ្រោះផងដែរ ។

តាមបទពិសោធន៍របស់លោក ក្នុងមានជាចៅក្រម និងព្រះរាជអាជ្ញា តើយើងអាចនិយាយបានទេថា ជាទូទៅជនរងគ្រោះគាត់តែងតែមានការពេញចិត្តទៅនឹងសេចក្ដីសម្រេចដែលចេញដោយអង្គជំនុំជម្រះ ប្រសិនបើការឈឺចាប់របស់ពួកគាត់មិនមានភាពធំធេង ។ ប៉ុន្តែ នៅក្នុងករណីទាំងឡាយជនរងគ្រោះមិនអាចទទួលយកការដាក់ទោសដែលបានកំណត់នោះទេ គឺស្ថានភាពនេះហើយដែលយើងជួបប្រទះនៅពេលបច្ចុប្បន្ននេះ ។

**ឆ៖** ខ្ញុំពិបាកស្ដាប់ទៅនឹងសំណួរ ដោយសារវាជាការរអាក់រអួលទៅលើប្រព័ន្ធ ។

**ស៖** ខ្ញុំសូមសួរសំណួររបស់ខ្ញុំសាជាថ្មីម្ដងទៀត ។ តាមបទពិសោធន៍របស់លោកដែលបំពេញការងារនៅក្នុងសាលាក្ដីទាំងឡាយ គឺបទពិសោធន៍ដែលខ្ញុំសូមបង្ហាញអំពីការទទួលស្គាល់ផងដែរ គឺទាក់ទងទៅនឹងការឈឺចាប់ដែលជនរងគ្រោះបានទទួលរង គឺពេលខ្លះទៅជនរងគ្រោះគាត់មិនទទួលស្គាល់ ឬក៏គាត់មិនពេញចិត្តទៅនឹងការកំណត់ទោសដោយសារតែជនរងគ្រោះយល់ឃើញថា សេចក្ដីសម្រេច ឬសាលក្រមទាំងនោះមិនគ្រប់គ្រាន់ តើលោកយល់ឃើញដូច្នេះទេ ចំពោះការយល់ឃើញនិងការមិនពេញចិត្តរបស់ជនរងគ្រោះ?

[១០:៤៤:៤៥]

**ឆ៖** ខ្ញុំគិតថា វាជាការទាញសន្និដ្ឋានជាលក្ខណៈទូទៅ ។ យើងអាចទាញការសន្និដ្ឋានជាទូទៅអ៊ីចឹងបាន ជនរងគ្រោះមួយចំនួនគាត់ប្រតិកម្មជាក់លាក់ មួយចំនួនទៀតគាត់មិនប្រតិកម្មទេ ។ ដូច្នេះហើយវាមានប្រតិកម្មជាច្រើននៅក្នុងចំណោមជនរងគ្រោះ ហើយបទពិសោធន៍របស់ខ្ញុំនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង រ្វាន់ដា និងយូហ្គោស្លាវី ជនរងគ្រោះមួយចំនួន គឺគាត់មិនពេញចិត្តទៅនឹងការស្វែងយុត្តិធម៌ដែលគាត់បានឃើញ និងរកដោយអង្គជំនុំជម្រះនោះទេ ។ ហើយវាជាប្រតិកម្មមួយដែលវិជ្ជមាន ហើយវាអាចជួយទៅលើការព្យាបាល ទៅលើការផ្សះផ្សាជាតិផងដែរ ទៅលើចំណុចនេះ ។

**ស៖** ដូចដែលលោកចៅក្រមបានជ្រាបហើយ សំណួររបស់ខ្ញុំ គឺវាពាក់ព័ន្ធទៅនឹងអ្វីដែលយើងកំពុងតែឆ្លងកាត់នៅតុលាការនេះ ។ ការសោកស្ដាយ ឬក៏វិប្បដិសារី ដែលជនជាប់ចោទ គាត់បានបង្ហាញជនរងគ្រោះគឺហាក់ដូចជាមិនសម្ដែង មិនបានឮនូវអ្វី ឬក៏មិនទទួលយកនូវអ្វីដែលគាត់បានសារភាព និងសម្ដែងការសោកស្ដាយទាំងអស់នេះ ដោយសារតែការឈឺចាប់របស់ជនរងគ្រោះទាំងអស់នោះ វាមានលក្ខណៈធ្ងន់ធ្ងរ ហើយធំធេង ។

**ឆ៖** ខ្ញុំមិនមានអង្គហេតុនិងធាតុផ្សំគ្រប់គ្រាន់ដើម្បីធ្វើការបកស្រាយទៅលើចំណុចទាំងអស់នេះទេ ។

**ស៖** សូមអរគុណលោកចៅក្រម ហ្គោលស្ទូន ខ្ញុំនៅសល់សំណួរចុងក្រោយមួយទៀត។ លោកចៅក្រមបានលើកឡើងនៅចំណុចមួយ ហើយខ្ញុំបានស្ដាប់ទាន់ទៅលើចំណុចហ្នឹងនៅពេលដែលលោកបាននិយាយថា ភាពចាំបាច់និងសារសំខាន់នៃការទទួលស្គាល់ទៅលើពិរុទ្ធភាព គឺវាបានបញ្ចប់ទៅលើការបដិសេធទាំងឡាយ ។ ដូច្នេះតើលោកគិតដែរឬទេថា បុគ្គលមួយរូបដែលគាត់បានសារភាពពិរុទ្ធភាពរបស់គាត់ជាលើកដំបូងទាក់ទងទៅនឹងរបបខ្មែរក្រហម ថាតើលោកគិតទេនៅពេលដែលសមាជិកអតីតខ្មែរក្រហមមួយរូបគាត់សារភាពជាលើកដំបូង ។ ការសារភាពនេះគឺវាអាចជាគំរូផ្សេងទៀតចំពោះជនជាប់ចោទដទៃៗទៀត ហើយវាក៏អាចនាំមកនូវសន្តិភាពជូនសង្គមផងដែរ ។

**ឆ៖** ជាការពិតនោះដូច្នោះមែន។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងរកឃើញថាការសារភាពទោស ឬក៏ការស្ដាយ និងវិប្បដិសារីដែលលោកបានលើកឡើង ដូចដែលខ្ញុំបានលើកឡើងពីដំបូងអ៊ីចឹង គឺវាជាកត្តាមួយដែលមានភាពចាំបាច់ ហើយវាមានលក្ខណៈវិជ្ជមាន ។ ខ្ញុំគិតថាវាជាគំរូនិងឧទាហរណ៍មួយដែលមានសារសំខាន់ ហើយវាអាចអូសទាញអ្នកដទៃផ្សេងទៀតឲ្យឆ្លើយនិងសារភាព ។ ដូច្នេះហើយនេះ គឺជាការសារភាពលោកទីមួយ ដូចដែលលោកបានលើកឡើងតាំងពីទសវត្សរ៍ខ្មែរក្រហម ។ ដូច្នេះហើយវាជាចំណុចសំខាន់ដែលថាយុត្តិធម៌វាមិនយឺតយ៉ាវសម្រាប់ជនរងគ្រោះដែលគាត់រស់រានមានជីវិតនោះទេ ។ ដូច្នេះហើយខ្ញុំគោរពនិងស្នើលើកឡើងថា វាជាកត្តាមួយដែលសំខាន់ ដែលយើងត្រូវពិចារណានៅក្នុងស្ថានសម្រាលទោស ។

**លោក ហ្វ្រេង់ស្វ័រ រ៉ូ៖**

លោកប្រធានជាទីគោរព! ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ សួរទៅកាន់លោកចៅក្រម ហ្គោលស្ទូន ។ សូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យខ្ញុំចូលរួមនៅក្នុងសវនាការស្ដាប់សាក្សីមួយនេះ ។

បើយើងពិចារណាទៅលើពេលវេលា និងទីកន្លែងខុសគ្នាដែលមានការពិបាកក៏ដោយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះអ្នកជំនាញ រីឆាត ហ្គោលស្តូន ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃឆ្លើយតបទៅនឹងសំណូមពររបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានកោះអញ្ជើញលោកមកផ្តល់សក្ខីកម្មក្នុងមានអ្នកជំនាញ ហើយខ្លឹមសារនៃការផ្តល់សក្ខីកម្មរបស់លោកអង្គជំនុំជម្រះនឹងយកទៅពិនិត្យពិចារណា ថ្លឹងថ្លែងក្នុងការពិចារណាសម្រេចរឿងក្តីនេះប្រកបដោយភាពយុត្តិធម៌ ។ ខ្លឹមសារនៃភាពជំនាញរបស់លោកដែលបានធ្វើសក្ខីកម្មនេះ គឺមានអត្ថន័យធំធេងណាស់ដល់ដំណើរការនៃការប្រព្រឹត្តទៅដើម្បីមូលហេតុ ហើយយុត្តិធម៌នៅតុលាការនេះ ក៏ដូចជាសង្គមកម្ពុជាយើងខ្ញុំដែរ ។ ហើយដំណើរការស្តាប់សក្ខីកម្មចំពោះលោកឃើញថា ដល់ទីបញ្ចប់ហើយ ។

**លោក រីឆាត ជេ. ហ្គោលស្តូន៖**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ហើយជាបន្តទៅនេះអង្គជំនុំជម្រះ ប្រកាសសម្រាកម្ភៃនាទី គឺចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយនិងដប់នាទីសូមអញ្ជើញចូលវិញ ។ ហើយអង្គជំនុំជម្រះសូមជម្រាបដល់ភាគី និងសាធារណជនដែលបានចូលរួមឲ្យបានជ្រាបផងដែរ ថាបន្ទាប់ទៅនេះ គឺពេលដែលចូលមកវិញ អង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញ វ៉ាអ៊ូល ម៉ាកចេនណា ជាបន្ត ដោយសារហេតុផលពេលវេលាដែលយើងធ្វើសវនាការនេះបានលឿងជាងពេលវេលាដែលយើងបានគ្រោងទុក ។ តាមពិត គឺយើងរៀបចំកាលវិភាគធ្វើស្តាប់សវនាការ អ្នកជំនាញ វ៉ាអ៊ូល ម៉ាកចេនណា នៅពេលរសៀលទេ ប៉ុន្តែដោយសារល្បឿននៃការដំណើរការសវនាការព្រឹកនេះបានល្អ អ៊ីចឹងគឺអង្គជំនុំជម្រះសម្រេចកិលនៃការស្តាប់សក្ខីកម្មរបស់សាក្សីឬរបស់អ្នកជំនាញ វ៉ាអ៊ូល ម៉ាកចេនណា នៅព្រឹកនេះ ។ ហើយបើសិនជាមិនចប់ទេ គឺយើងលើកទៅបន្តនៅពេលរសៀល ។

អ៊ីចឹងសូមប្រកាសសម្រាកម្ភៃនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១០:៥២នាទីដល់ម៉ោង១១:១៤នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយពេលវេលាដែលនៅសេសសល់នៅព្រឹកនេះ គឺអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មអ្នកជំនាញ វ៉ាអ៊្វូល ម៉ាកចេនណា ។ មន្ត្រីតុលាការអញ្ជើញអ្នកជំនាញ វ៉ាអ៊្វូល ម៉ាកចេនណា ចូលមកកាន់បន្ទប់សវនាការ ។

*(សាក្សីជំនាញចូលមកក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីអ្នកជំនាញ តើអ្នកជំនាញអាចប្រាប់ឈ្មោះពេញលេញរបស់អ្នកជំនាញជូនដល់អង្គសវនាការបានដែរឬទេ?

**ឆ៖** ខ្ញុំឈ្មោះ វ៉ាអ៊្វូល ម៉ាកចេនណា ។

**ស៖** លោក វ៉ាអ៊្វូល ម៉ាកចេនណា តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ៦៣ឆ្នាំ លោកប្រធាន ។

**ស៖** តើលោកមានទីកន្លែងរស់នៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** ខ្ញុំរស់នៅក្នុប្រទេសបារាំង ។

**ស៖** តើសព្វថ្ងៃនេះលោកប្រកបមុខរបស់អ្វីដែរ?

**ឆ៖** លោកប្រធាន ខ្ញុំជាអ្នកជំនាញការនៅក្នុងទំនាក់ទំនងអន្តរជាតិ លោកប្រធាន ។

**ស៖** លោក វ៉ាអ៊្វូល ម៉ាកចេនណា តើលោកកាន់សាសនាអ្វីដែរ?

**ឆ៖** ខ្ញុំមិនកាន់សាសនាអ្វីទេ លោកប្រធាន ។

**ស៖** លោក វ៉ាអ៊្វូល ម៉ាកចេនណា! តាមរបាយការណ៍របស់ក្រឡាបញ្ជីថា លោកមិនមានចំណងលោហិត ញាតិពន្ធ ឬក៏ជាសហព័ន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ។ តើជាការពិតមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកប្រធាន ។

**ស៖** ក្នុងនាមជាអ្នកជំនាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តាមវិធាន៣១.២ នៃវិធានផ្ទៃក្នុងតម្រូវឲ្យអ្នកជំនាញធ្វើសម្បថ ឬក៏ធ្វើសច្ចាប្រណិធានតាមសាសនា ឬក៏តាមជំនឿរបស់ខ្លួនជាមុន មុននឹងផ្តល់សក្ខីកម្មជូនដល់អង្គជំនុំជម្រះ។ តើលោកយល់ព្រមធ្វើសច្ចាប្រណិធាននៅចំពោះមុខអង្គជំនុំចម្រះដែរឬទេ?

**ឆ៖** បាទ, លោកប្រធាន ។

[១១:១៩:១៥]

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការ កញ្ញា ណាតាចា សូមសម្របសម្រួលរៀបចំដល់លោក រ៉ាអ៊ូល ម៉ាកចេនណា ដើម្បីឲ្យលោកធ្វើសច្ចាប្រណិធានតាមជំនឿរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ។

**កញ្ញា ណាតាចា វីស៊ែល វីស៖**

ជម្រាបសួរលោកអ្នកជំនាញ សូមលោកថាតាមខ្ញុំ ។ ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងជួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ។

**លោក រ៉ាអ៊ូល ម៉ាកចេនណា៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

តទៅនេះអង្គជំនុំជម្រះសូមប្រគល់ភារជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរជាក់លាក់ចំពោះអ្នកជំនាញរូបនេះ ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក់ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៖**

សូមជម្រាបសួរលោក ចេនណា! ខ្ញុំចៅក្រម ឡាវ៉ែន៍ ខ្ញុំនឹងសួរសំណួរមួយចំនួន ជាធម្មតាអង្គជំនុំជម្រះមុននឹងប្រគល់សំណួរ-- មុននឹងវេទិកាឲ្យលោកនិយាយ គឺយើងត្រូវសួរសំណួរមួយចំនួនដើម្បីឲ្យដឹងអំពីគុណពុទ្ធិសមត្ថភាពរបស់លោក គឺទាក់ទងទៅនឹងជីវប្រវត្តិរបស់លោក ។

**ស៖** លោកមានសញ្ញាបត្របណ្ឌិតនៅក្នុងវិទ្យាសាស្ត្រនយោបាយនៅក្នុងប្រទេសបារាំង ហើយលោកក៏ជាបណ្ឌិតនៅក្នុងវិទ្យាសាស្ត្រខ្មែរនិងការសិក្សាខ្មែរដែលទទួលនៅ*អេឌីណាកូ* (INALCO) តើត្រូវដែរឬទេ? ហើយលោកបានធ្វើការងារអាជីពជាច្រើនជាសាស្ត្រាចារ្យ ជាអ្នកកាសែត ជាទីប្រឹក្សាឲ្យរដ្ឋាភិបាល ប៊ែលហ្ស៊ិក សភា ហើយនិងប្រធាន ឬក៏អ្នកពិគ្រោះយោបល់ឲ្យវេទិកាសផ្សេងៗនៅកម្ពុជា គឺអ្នកជំនាញអំពីអាជ្ញាធរបណ្ដោះអាសន្ននៅកម្ពុជា អ៊ុនតាក់ ។ ហើយ យូណេស្កូ ហើយសភាពអឺរ៉ុបក៏លោកធ្លាប់ជាជំនាញដែរលើកិច្ចការនយោបាយកម្ពុជា ហើយលោកក៏ជាអ្នកអង្កេតការអន្តរជាតិនៅក្នុងពេលការដកនៅអំពីបេសកម្មមួយនៅកម្ពុជានៅឆ្នាំ១៩៨៩ របស់វៀតណាម ហើយនិងឆ្នាំ១៩៨០ ហើយនិងឆ្នាំ២០០០ ហើយនិងឆ្នាំ៩៨និង២០០០ លោកក៏ធ្វើជាអ្នកអង្កេតការបោះឆ្នោត ។ មជ្ឈមណ្ឌល

ឯកសារកម្ពុជា ក៏លោកបានធ្វើជាអ្នកជំនាញពិគ្រោះយោបល់ដែរ ។ គណៈកម្មការវិទ្យាសាស្ត្រអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ តើលោកនៅមានការងារហ្នឹងបែបហ្នឹងដែរឬទេ?

[១១:២៣:១៥]

**ឆ៖** តាមពិតក្រុមប្រឹក្សាវិទ្យាសាស្ត្រនេះ គឺធ្វើឡើងតាមសាកលវិទ្យាល័យយ៉េល ដើម្បីបង្កើតតើអ្វីជាដែលត្រូវបង្កើតជាអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាមកដល់ពេលនេះ ។ ហ្នឹងហើយជាគំនិតផ្តួចផ្តើមរបស់ក្រុមប្រឹក្សានោះ ។

**ស៖** លោកក៏បានជាអ្នកស្រាវជ្រាវរបស់ *អ៊ុកស្វាម* (oxfam) ដែលទាក់ទងទៅនឹងកិច្ចការពាណិជ្ជកម្មពិភពលោក ហើយក៏បានធ្វើជាទីប្រឹក្សារបស់ក្រុមអ្នកសភាជាច្រើននៃបញ្ហាសាកលភាវូបនីយកម្ម តើលោកចង់បញ្ជាក់អ្វីបន្ថែមទៀតទេ តាមអ្វីដែលខ្ញុំសួរបញ្ជាក់អំពីប្រវត្តិការងារសង្ខេបរបស់លោក ដែលលោកបានសរសេរសៀវភៅមួយចំនួនអំពីកម្ពុជាមួយដែលនិយាយអំពីការជំងឺរ៉ាំរ៉ៃ ឬក៏ជម្លោះបន្តនៅកម្ពុជា ហើយមួយទៀតហៅថា គឺកម្ពុជាស្ថិតនៅក្នុងរបបកៀបសង្កត់មួយ ថាតើលោកមានអ្វីចង់បន្ថែមទៅនឹងប្រវត្តិរូប ឬក៏ការងាររបស់លោក ឬក៏អាចលោកប្រាប់យើង ។ តើលោកធ្លាប់បានធ្វើជាទីប្រឹក្សាឲ្យរាជរដ្ឋាភិបាលកម្ពុជាដែរឬទេ?

**ឆ៖** ខ្ញុំមិនមានអ្វីបន្ថែមទៅនឹងប្រវត្តិរូប ហើយនិងប្រវត្តិការងាររបស់ខ្ញុំទេ ហើយខ្ញុំសូមបញ្ជាក់ថា ខ្ញុំជាអ្នកជំនាញការទីប្រឹក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជាទៅលើបញ្ហាពិសេសមួយ គឺទំនាក់ទំនងការបរទេស បញ្ហាព្រំដែន ហើយតាមពិតខ្ញុំឯកសារតែរបស់ខ្ញុំអំពីព្រំដែនកម្ពុជារហូតមកដល់ពេលថ្មីនេះផងដែរ ។

**ស៖** អ៊ីចឹងយើងមាននៅក្នុងឯកសារគឺមានឯកសារមួយគឺការពិគ្រោះយោបល់នោះ ដែលមេធាវីការពារជនជាប់ចោទក៏បានស្នើ គឺឯកសារ D82 នៃឯកសារស៊ើបអង្កេត ។ នៅក្នុងការពិគ្រោះយោបល់នោះ មេធាវីការពារបានស្វែងរក ចង់បានព័ត៌មានមួយចំនួនទាក់ទងទៅនឹងៗមនោគមវិជ្ជានៃកម្ពុជាប្រជាធិបតេយ្យ គឺលក្ខណៈពិសេសនៃលទ្ធិកុម្មុយនីស្តកម្ពុជា ហើយនិងការអនុវត្តរបបអង្គការ ដែលហៅថា ការសម្លាប់របស់កម្ពុជាប្រជាធិបតេយ្យខ្សែសង្វាក់នៃការបញ្ជា ហើយម៉ាស៊ីននៃសន្តិសុខ ហើយនិងការអនុវត្តទៅតាមកុម្មុយនីស្តចិន ហើយនិងគំរូនៃកម្ពុជាប្រជាធិបតេយ្យ ហើយនិងតួនាទីរបស់ សុន សេន ។

[១១:២៦:៤០]

 

អ៊ីចឹងហើយគឺជាចំណុចមួយចំនួនដែលមេធាវីការពារស្នើសុំឲ្យលោកផ្តល់ការសេចក្តីលម្អិត ។ អ៊ីចឹងខ្ញុំជូនវេទិកាឲ្យលោកមានប្រសាសន៍ បន្ទាប់មកយើងនឹងសួរសំណួរទៅលោក ។

**ឆ៖** អរគុណលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ ខ្ញុំមានការរំញោចអារម្មណ៍មួយចំនួន ដូចខ្ញុំបានដឹងថាលក្ខណៈប្រវត្តិសាស្ត្រនៃការជំនុំជម្រះនេះ ខ្ញុំមានអារម្មណ៍ក្តុកក្តួលពីព្រោះថាយើងពិនិត្យមើលអង្គហេតុនៃរឿងដែលកើតឡើង គឺយើងទាក់ទងទៅនឹងជីវិត ហើយនិងមនុស្សស្លាប់ ហើយនិងការឈឺចាប់ជាពិសេសនៅក្នុងៗបច្ចុប្បន្ននេះ ។

ជាថ្មីម្តងទៀតហ្នឹងគឺជារបបឃោរឃៅដែលថា អ្នកដែលនៅក្នុងជំនាន់ខ្ញុំនេះគឺមាន-- បញ្ជាក់ថាកុំឲ្យកើតឡើងជាថ្មីម្តងទៀត ដែលបញ្ជាក់ឡើងនៅក្នុងព្រះរាជអាជ្ញានៅក្នុងសាលាក្តីនូរ៉ឹមប៊ឺក ដោយលោក ហាលី សក្រូស (ឮមិនច្បាស់) នោះ ។ ប៉ុន្តែនឹង-- យើងសូមគោរពចំពោះជនរងគ្រោះរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងមេត្តាធម៌ ហើយនិងសេចក្តីអាណិតអាសូរដល់អ្នករងគ្រោះ ។

របបផ្តាច់ការស្តាំនិយមត្រូវបានកាត់ទោសនៅសាលាក្តីនូរ៉ឹមប៊ឺក និង តូក្យូ ប៉ុន្តែនៅរបបផ្តាច់ការឆ្វេងនិយមមិនត្រូវបានកាត់ទោសនោះទេ ។ គឺជាការជំនុំជម្រះដែលថា ត្រូវកាត់ទោស ត្រូវបានធ្វើឡើងនៅក្នុងនាមប្រជាជន ។ ប៉ុន្តែ ខ្ញុំមិនមែន មិនធ្វើឲ្យមានការភាន់ច្រឡំនៅក្នុងមនោគមវិជ្ជានោះទេ គឺថាផ្លូវកុម្មុយនីស្តគឺមិនមានដំណើរថាត្រូវតែផ្តាច់ការនិយមនោះទេ ។ ប៉ុន្តែ មនោគមវិជ្ជាដែលបានជ្រើសរើសយកមកប្រើ ហើយនិងបង្ខំ ប៉ុន្តែមិនបានធ្វើឲ្យគេជឿជាក់ ។ ប៉ុន្តែ គេនៅទីបំផុតនោះ ហើយក៏អាចនឹងចូលទៅដល់សម្ពាប់របស់ជីវិតបុគ្គលម្នាក់ៗ ហើយនិងបំផ្លាញកិតិស័ព្ទរបស់មនុស្សជាតិ ។ ប៉ុន្តែអ្វីដែលយើងធ្វើនៅទីនេះ ដែលយើងគ្រាន់ថាលទ្ធិប៉ុលពតនិយមនោះ គឺដើម្បីបញ្ជាក់ថា តើចំណុចណាគឺកុម្មុយនីស្តកម្ពុជា គឺវាអាចខុសអំពីលទ្ធិកុម្មុយនីស្តរបស់ប្រទេសផ្សេងៗទៀតដែលថាអាចនឹងអនុវត្តនូវគោលការណ៍បំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬក៏អនុសញ្ញាក្រុងហ្សឺណែវ ។

ដើម្បីពិចារណានោះ គឺថាមិនមែនត្រូវតែយល់និងពន្យល់នោះទេ ។ មិនមែនជាគំនិតដំបូងដើម្បីពន្យល់ពីអាកប្បិកិរិយា ដើម្បីផ្តល់ហេតុផលទៅដល់សង្គមថាកុំឲ្យវាកើតឡើងវិញ ។ ប៉ុន្តែ មិនដែលមានឱកាសវដ៏ល្អដូចថ្ងៃនេះនោះទេ ដើម្បីពិនិត្យមើលសំណើមួយចំនួនអំពីការកាត់ទោស ព្រីម៉ូឡឺវី (Primo Levi) ដែលគាត់ជាអ្នករស់រាននៅក្នុង អូស្វិច (Auschwitz) ដែលយើងថា ការបំភ្លេចពីអតីតកាល គឺថាអាចនឹងធ្វើបទពិសោធន៍នោះកើតឡើងមកវិញ ហើយ ហ្វ្រង់ស្វ័រ ប៊ីហ្សូ គាត់បាននិយាយ គឺយើងត្រូវតែយល់ ព្យាយាមយល់ ។ ប៉ុន្តែការព្យាយាមយល់នោះក៏មិនមែនមានន័យថា ការអភ័យទោស

នោះទេ ។

លោកប្រធាន! ខ្ញុំៗត្រូវបានស្នើដើម្បីផ្តល់សក្ខីកម្មជាអ្នកជំនាញពីមេធាវីការពារ ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមកទីនេះដើម្បីគាំទ្រអ្នកការពារក្តីនោះទេ ប៉ុន្តែនេះខ្ញុំដើម្បីបញ្ជាក់ការពិតអំពីរបបដ៏ភ័យខ្លាច ។ អ្វីដែលខ្ញុំធ្វើនៅទីនេះ គឺមានគោលបំណងស្វែងពន្យល់អំពីប្រព័ន្ធមួយដែលនាំឲ្យមានរបបឃោរឃៅជាប្រព័ន្ធ ដែលខ្ញុំត្រូវពន្យល់ទាក់ទងទៅនឹងពាក្យពេចន៍នៅក្នុងការកោះអញ្ជើញអំពីទ្រឹស្តី អំពីការអនុវត្តនៃរបបហ្នឹង ។ ការបង្កើតឡើងដោយកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ជាក់អំពីវិធានការដែលរបបនោះប្រើ វិធីដើម្បីបង្ហាញពីមនោគមវិជ្ជារបស់គេ ។

ខ្ញុំយល់ស្របតាមសំណើរបស់មេធាវីការពារក្តី ក្នុងការមកផ្តល់សក្ខីកម្មនៅក្នុងលក្ខខណ្ឌពីរ ។ ប៉ុន្តែ ខ្ញុំនឹងនិយាយនូវអ្វីដែលខ្ញុំនឹងលើកឡើង ហើយខ្ញុំចង់ជួបជនជាប់ចោទ ។ ហើយខ្ញុំនិយាយថា ខ្ញុំសម្តែងដោយក្នុងការសម្តែងដោយសេរី ហើយខ្ញុំដឹងថាជនជាប់ចោទ គាត់មានការសហការយ៉ាងពេញលេញនៅពេលដែលខ្ញុំបានធ្វើការសម្ភាសន៍ជាមួយគាត់ក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ។ ៦ខែនេះ ។ ខ្ញុំសង្ឃឹមថាការពន្យល់របស់ខ្ញុំ នឹងជួយឲ្យមានការស្វែងយល់ថា វ៉ាន់ ណាត ដែលជាជនរងគ្រោះរបស់ ឌុច មួយនោះ គាត់សម្តែងទទួលស្គាល់នៅចំពោះមុខលោក លោកស្រីចៅក្រម ចំពោះអ្នកដែលជាពេជ្ឈឃាដ ក៏អាចជាជនរងគ្រោះនៅពេលនោះផងដែរ ដែលគាត់បានបម្រើទៅលើប្រព័ន្ធនេះ ។

[១១:៣២:១៩]

ដោយសារតែលោក លោកស្រីចៅក្រមយល់ហើយថា យើងត្រូវធ្វើការវិនិច្ឆ័យទៅលើប្រព័ន្ធនិងអ្នកអនុវត្ត ។ ដូច្នេះហើយវាមិនអាចក្នុងការស្វែងយល់នៅក្នុងប្រទេសកម្ពុជា ដែលយើងជួបប្រទះប្រឈមទៅលើការផ្សំគំនិតពិរុទ្ធភាពរវាងស្ត្រី និងបុរស ដែលត្រូវបានគេដាក់ជាទាសភាព ហើយនៅក្នុងប្រព័ន្ធមួយដែលដាក់ទៅលើប្រជាជននិងមនុស្សជាតិដែលមិនធ្លាប់មាន ។ ការផ្សំគំនិត ការឃុបឃិតទាំងអស់នោះ វាកើតចេញពីក្រុមតូចនេះ ដែលគាត់ជាមេដឹកនាំនៅក្នុងប្រទេសកម្ពុជានាសម័យនោះ ។ ដូច្នេះហើយ គឺជាប្រជាជនដែលបានធ្វើឲ្យមានការបង្កើតនូវទាសភាព ។

[១១:៣៣:១៦]

ទាក់ទងទៅនឹងមនោគមវិជ្ជា នេះជាចំណុចមួយដែលខ្ញុំចង់លើកឡើង ។ ទាក់ទងទៅនឹងប្រវត្តិមនោគមវិជ្ជាដែលជំរុញទៅដល់អង្គការ ចំណុចយោងសំខាន់នៅពេលនោះ ដល់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៧៦ និងព្រឹត្តិការណ៍កើតឡើងផ្សេងទៀតគឺវាទាក់ទងទៅនឹងអត្ថបទនៅក្នុងឆ្នាំ១៩៥២ ដែល

ទាក់ទងទៅនឹងការបោះពុម្ពផ្សាយសៀវភៅវាជានិយម ឬក៏ប្រជាធិបតេយ្យ ហើយគាត់បានធ្វើការចុះហត្ថលេខាជាភាសាខ្មែរ គឺខ្មែរដើម ។ ហើយក៏យោងទៅលើបដិវត្តន៍វៀតណាមនៅក្នុងឆ្នាំ១៩៤៥ និងបដិវត្តន៍ចិនឆ្នាំ១៩៤៩ ។ ខ្ញុំយល់ស្របជាមួយនឹង ស្ទីវហេដឌ័រ ដែលថាការប្ដេជ្ញានៅក្នុងឧក្រិដ្ឋកម្មកុម្មុយនីស្តខ្មែរក្រហម គឺ ប៉ុលពត ហើយខ្ញុំមិននិយាយថា វៀតណាមគាត់ចូលរួមនៅក្នុងការបណ្ដុះបណ្ដាលហ្វឹកហាត់យោធានៅក្នុងប្រព័ន្ធកុម្មុយនីស្តនេះទេ ។ ប៉ុន្តែ ខ្ញុំក៏មិនចង់បន្ថយទៅលើសារសំខាន់នៃគំរូចិនទាក់ទងទៅនឹងកសិកម្មនិយម ហើយវាជាចំណុចមួយដែលគេមិនទទួលបាននៅក្នុងប្រទេសចិន ។

យើងមិនអាចនិយាយទេថា ទាក់ទងទៅនឹងបញ្ហានយោបាយនិងការរៀបចំរបស់បក្សកុម្មុយនីស្តកម្ពុជា គឺទាក់ទងទៅនឹងការអនុវត្តផ្សេងៗ គឺនៅក្នុងដូចករណី បុលសេវិក (Bolshevik) ។ ក្រុមនេះ គឺមានមេដឹកនាំនៅក្នុងកុម្មុយនីស្ត ហើយក៏យើងឃើញថានៅក្នុងសម័យខ្មែរក្រហម មុនខ្មែរក្រហមក៏មានក្រុមនិស្សិតដែលជាក្រុមបង្កើតឡើង ។ អ្នកទាំងអស់នោះមួយចំនួន គឺជាសមាជិករបស់បក្សកុម្មុយនីស្តបារាំង ហើយយើងដឹងជារួមហើយអំពីបក្សកុម្មុយនីស្ត ដែលត្រូវបានមានសកម្មភាពនៅក្នុងប្រទេសជាច្រើនដូចជា *ភីស៊ីអេហ្វ* (PCF) ដែលមានលក្ខណៈស្ម័គ្រចិត្ត មានលក្ខណៈស្មោះត្រង់ទៅនឹងបក្សកុម្មុយនីស្ត ។ ហើយនៅពេលនោះមួយភាគបីនៃអ្នកមួយចំនួនក៏មានការជឿជាក់ផងដែរ ។

នៅក្នុងថ្នាក់ ឬក៏មហាវិទ្យាល័យមួយចំនួននៃភីស៊ីអេហ្វ យើងឃើញមានការកើតឡើងទៅលើបញ្ហាទាំងអស់នេះ ហើយវាជាយន្តការរបស់ *ប៉េសេអេហ្វ* (PCF) នៅពេលនោះផងដែរ ។ មានផ្ទះប៉េសេអេហ្វ ដែលមាននៅក្នុងប្រទេស ហើយសិស្សរស់នៅនៅទីនោះ ។ មានសិស្ស និស្សិត៩នាក់ គឺមេហ្សុង ឌុយ កាំបូដស៍ (maison du Cambodge) ហើយគេមានការរៀបចំ ហើយនិស្សិតខ្មែរដែលរស់នៅ នៅក្នុងក្រុងនោះរួមទាំង ប៉ុល ពត គាត់ជាក្រុមរបស់ក្រុមកុម្មុយនីស្តផងដែរ ។ ហើយនៅក្នុងនោះ គឺមានការរៀបចំប្រព័ន្ធ ហើយនិងការបង្កើតបក្ស ដែលចេញមកពីយន្តការមួយចំនួនទាក់ទងទៅនឹង កួក មិញតាំង ។

សមាជិកភាពគឺតម្រូវឱ្យគោរពទៅលើលក្ខខណ្ឌ២១ ដែលកំណត់ដោយ លេនីន ហើយលក្ខខណ្ឌទាំង២១ នោះ គឺជាកាតព្វកិច្ចក្នុងការអនុវត្តនៅក្នុងបក្ស គឺលក្ខខណ្ឌដែក តឹងរ៉ឹង ដែលវាមានលក្ខណៈនិងការអនុវត្តទៅលើបក្សមជ្ឈិមផងដែរ ដែលទាក់ទងទៅនឹងការកែទម្រង់ នៅក្នុងនោះក៏មានការរៀបចំក្លាញដេស្តាញ (clandestine) និងការរៀបចំអំពីភាពសម្ងាត់ដែលត្រូវរក្សាផងដែរ ។ បក្សកុម្មុយនីស្តកម្ពុជា គឺមិនអាចអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាននោះទេ ប្រសិនបើមិនរៀបចំឱ្យបានស្រួលបួល ហើយ

វិន័យទាំងអស់នោះគឺត្រូវរៀបចំឡើង ហើយទទួលស្គាល់នៅក្នុងគណៈមជ្ឈិម ។ ហើយយើងដឹងហើយ វាជាការដែលមិនអាចជំទាស់ទៅលើអំណាចផ្សេងៗរបស់ជួរឃោធា ។...

**អ្នកបកប្រែ៖**

សូមអនុញ្ញាតលោកប្រធាន! ឱ្យអ្នកនិយាយបន្ថយល្បឿននូវការនិយាយដើម្បីឱ្យកត់ត្រាចូលទៅក្នុងកំណត់ហេតុ ។

**លោក រីឆាត ជេ ហ្គោលស្តុន(និយាយបន្ត)៖**

...ដើម្បីឱ្យសារធាតុ ភីធីស្វរហ្ស៊ូរ (ឮមិនច្បាស់) គឺអាចដកចេញបាន ។ ដូច្នេះហើយយើងត្រូវដឹងថា និស្សិតកម្ពុជាដែលចូលរួមបក្សកុម្មុយនីស្តបារាំង គឺត្រូវបានគេបណ្តុះបណ្តាលដើម្បីឱ្យមានភាពជឿជាក់ថា បក្សកុម្មុយនីស្តកម្ពុជា គឺមានវិន័យតឹងរ៉ឹង ហើយលុបចោលនូវអ្នកតតាំងប្រឆាំងទាំងឡាយ ។ ហើយបុគ្គលទាំងឡាយដែលមានភាពគួរសមត្រូវបានទទួលយក ។ ដូច្នេះហើយយើងឃើញថា វាមានសមាជិកកើតឡើងនៅក្នុងចំណោមនិស្សិតនោះនៅទីក្រុងប៉ារីស ។

ព័ត៌មានទាំងឡាយទៅនឹងសំណួរដែលយើងមាននៅចំពោះយើង យើងបានដឹងថា សៀវភៅដែលសរសេរដោយ ម៉ាក្ស លេនីន ស្តាលីន និងម៉ៅ សៀវភៅចំនួនពីរត្រូវបានគេសិក្សាស្វែងយល់ ហើយជាកម្មវត្ថុនៃការដេញដោលពិភាក្សាគ្នា ។ លើសៀវភៅ លេនីន គឺរដ្ឋបដិវត្តន៍ ហើយនិងសៀវភៅរបស់ស្តាលីន គឺគោលការណ៍ លេនីន និយម ។ ដូច្នេះហើយនៅក្នុងសៀវភៅនោះគេបានលើកឡើងថា គេអាចអនុវត្តបដិវត្តន៍បាន ទោះបីជាពុំមានការផ្តាច់ការនិយមក៏ដោយ ។ ប្រសិនបើប្រជាជនទាំងឡាយទទួលរងនូវការបាក់ទឹកចិត្ត ឬក៏ការកៀបសង្កត់ ហើយមានការកម្ទេចទៅលើសង្គមផ្សេងៗ ហើយគេចង់ឱ្យមានសង្គមមួយដែលល្អ ។

យើងឃើញថានៅក្នុង ប៉ុល ពត និយមគឺមានគំនិតដែលទាញចេញពី ម៉ៅ ហើយយើងឃើញថាវាមានលក្ខណៈតឹងរ៉ឹង ។ ដូច្នេះហើយការទទួលជោគជ័យរបស់កងកម្លាំងប្រជាពលរដ្ឋនោះ មិនមែនថាពួកគហបតីមិនមានអនុភាពនោះទេ ។ សៀវភៅទីពីរ ក៏បានលើកឡើងនិយាយអំពីចំណុចទាំងឡាយដែលជនជាប់ចោទ តាំងពីឆ្នាំ១៩៧០ សមាជិកថ្មីរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវតែធ្វើការពិនិត្យ និងអានទៅលើសៀវភៅបោះពុម្ពលើកទីពីរនេះ ។

[១១:៤០:០៣]

នៅក្នុងជំពូកទី៧ ដែលនិយាយអំពីបក្ស គឺលក្ខខណ្ឌដែលមានចែងរបស់ លេនីន ហើយនិងទំនាក់

ទំនងទៅនឹងសហភាពសូវៀតមិនមានការផ្លាស់ប្តូរ ហើយក៏មានការនិយាយអំពីតួនាទីរបស់បក្ស ហើយ និងការលើកឡើងនូវចំណុចមួយចំនួនដើម្បីឲ្យយើងយល់នៅក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា ។

បក្សនៅក្នុងនោះៗ គេមានលើកឡើងអំពីចំណុចដែលទាក់ទងទៅនឹងបក្ស ហើយកិច្ចការនោះ គឺដើម្បីគាំទ្រ និងរៀបចំទៅលើវណ្ណៈអធននិយម ។ ដូច្នេះ បក្សត្រូវតែជាចំណុចមូលដ្ឋាន ហើយត្រូវតែមានការគោរពវិន័យឲ្យបានតឹងរ៉ឹង ហើយវិន័យនោះគឺវាស្រដៀងទៅនឹងវិន័យយោធា ។

ស្តាលីន គឺបានលើកឡើងថា ចំណុចសំខាន់នៃបក្សនោះ គឺជាការរៀបចំរបស់អង្គការមួយដែលមានអំណាចខ្ពស់ ហើយមានដែនកំណត់ ហើយក៏បានលើកឡើងទៅលើមនោគមវិជ្ជារបស់ស្តាលីន ផងដែរ ។ នៅចំណុចមួយចំនួនគឺគេលើកឡើងអំពីចំណុចទាក់ទងទៅនឹងបក្ស ដែលខកខានមិនបានគោរពធ្វើតាម និងចំណុចធាតុផ្សំមួយចំនួនទៀត ។ នៅក្នុងនោះក៏មានចែងយ៉ាងច្បាស់លាស់ថា មនោគមវិជ្ជាគឺមិនអាចដោះស្រាយបានទេ ដូច្នេះហើយត្រូវមានការកាប់សម្លាប់ ឬក៏មានការបោសសម្អាត ហើយក៏មានការបញ្ចូលទៅនឹងមនោគមវិជ្ជាផ្សេងៗ ។

ចំណុចទាំងអស់នេះហើយគឺជាគំរូរបស់កុម្មុយនីស្តនិយម ដែលបានបង្រៀនដោយ ភីស៊ីអេហ្វ ហើយដែលជាសមាជិកនៅក្នុងនោះជានិស្សិតខ្មែរផងដែរ ។ ក្រុមទាំងអស់នោះ មិនត្រឹមតែមាន ប៉ុល ពត ប៉ុណ្ណោះទេ គឺមាន អៀង សារី, អៀង ធីរិទ្ធ, ហ៊ូ យន់, ខៀវ សំផន, ម៉ី ម៉ាន់, ឈឿន ម៉ុម ។ ប៉ុន្តែដើម្បីគោលបំណងនៃការជំនុំជម្រះនេះ យើងឃើញមាន សុន សេន ផងដែរ ។ នៅក្នុងឆ្នាំ១៩៥៤ សុន សេន គឺជាសមាជិករបស់ភីស៊ីអេហ្វ នៅ មេហ្សុង ឌុយ កាំបូដស៍ ។ គាត់បានក្លាយទៅជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមដែលជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការពារកម្ពុជាប្រជាធិបតេយ្យ គាត់ជាអគ្គសេនាធិការ ហើយជាមេបញ្ជាការនៅកងកម្លាំងនិងសន្តិបាលផងដែរ ។ សុន សេន ដែលគាត់ជាសមាជិករបស់ឧត្តមក្រុមប្រឹក្សាជាតិ ដែលបានបង្កើត ហើយនៅក្នុងនោះក៏មានការនិយាយអំពីសន្តិភាពនៅក្នុងដំណាក់កាលសម័យបោះឆ្នោតផងដែរ ។ សុន សេន ដែលជាគ្រូរបស់ជនជាប់ចោទ គាត់ជាមេរបស់ជនជាប់ចោទ ហើយគាត់បំពេញការងារនៅក្នុងឆ្នាំ១៩៧៥-១៩៧៨ ។ ហើយនៅក្នុងអំឡុង១៩៧៥-១៩៧៨ នោះហើយ ដែលជនជាប់ចោទត្រូវបានយកមកជំនុំជម្រះនៅទីនេះ ។

នៅក្នុងឆ្នាំ១៩៥០ដល់១៩៥៦ សុន សេន បានចូលរួមជាមួយនឹងនិស្សិតខ្មែរដូចដែលខ្ញុំបានជម្រាប គាត់គឺជាសមាជិករបស់បក្សកុម្មុយនីស្តបារាំង ដូចដែលកម្មាភិបាលរបស់គាត់ គាត់បានពាក់ព័ន្ធនៅក្នុងការពិភាក្សាអនុវត្តការងាររបស់បក្សកុម្មុយនីស្ត ។ ហើយវាមានសារសំខាន់ណាស់សម្រាប់អង្គជំនុំ

ជម្រះនេះត្រូវចាំថា តើមានអ្វីកើតឡើងនៅក្នុងកំឡុងឆ្នាំ១៩៥០ និងឆ្នាំ១៩៥៦ នៅក្នុងសង្គមកុម្មុយនីស្ត។

នៅក្នុងសម័យនេះ យើងឃើញមានការជំនុំជម្រះនៅម៉ូស្គូ ដែលនៅពេលនោះ គឺមានការកាត់ទោសប្រហារជីវិតចំពោះអ្នកដែលស្ថាបនារបបបដិវត្តន៍ឆ្នាំទសវត្សរ៍៥០ហើយនៅពេលដែល សុន សេន និងកម្មាភិបាលដទៃទៀតដែលត្រូវបានគេលើកឡើងអំពីយន្តការនោះ នៅក្នុងអឺរ៉ុបខាងកើត គឺគេមានការចាក់ផ្សាយទៅលើការជំនុំជម្រះផ្សេងៗ ហើយនៅក្នុងនោះ គឺវាពាក់ព័ន្ធទៅនឹងអ្នកបដិវត្តន៍មួយចំនួន ។

[១១:៤៥:២៩]

នៅក្នុងចុងឆ្នាំ១៩៧៩ មានការកាត់ទោសនៅ ប៊ូដាហ្វេស និង សូហ្វៃរ នៅពេលនោះហើយ គឺមេកុម្មុយនីស្តត្រូវបានគេកាត់ទោស ហើយប្រហារជីវិត ។ នៅក្នុងឆ្នាំ១៩៥២ គឺមានការជំនុំជម្រះនៅប្រាក គឺ *ប៊ុលដូស ស្លាំងស្គី* ដែលគាត់ធ្វើការនៅក្នុងបក្ស ហើយនៅមានការជំនុំជម្រះរដ្ឋ សមាជិករដ្ឋាភិបាលផ្សេងៗ ដែលលោក មានលោក *ឡាំងខិន* ដែលគាត់បានសរសេរសៀវភៅទាក់ទងទៅនឹងការសារភាពផ្សេងៗផងដែរ ។

វីរជនដែលបានចូលរួមនៅក្នុងចលនាកុម្មុយនីស្ត យើងឃើញមានកើតឡើងជាច្រើនដំណាក់ ហើយក៏មានការជំនុំជម្រះម្រះទៅលើករណីទាំងអស់នេះ ដោយសារតែមានការកាត់ទោសទៅលើបុគ្គលមួយចំនួន ហើយក៏យើងឃើញអំពីអំណាចរបស់សូវៀតដែលចង់លុកលុយ ។ គោលគំនិតដែលលើកឡើងនៅក្នុងសង្គ្រាមត្រជាក់នោះ វិន័យដ៏តឹងរ៉ឹង គឺតម្រូវឲ្យអនុវត្តនៅក្នុងបក្ស ហើយមិនមានបុគ្គលនរណាម្នាក់ មិនថាគាត់ជាសមាជិកបក្ស ឬក៏គាត់ធ្លាប់បម្រើការងារគឺគាត់មានសេរីភាព ហើយមានសុវត្ថិភាព ។ ដូច្នេះហើយគឺជាសារមួយដែលផ្ញើជូនទៅដល់សង្គមទូទៅនៅក្នុងពិភពលោក ដែលគាត់អនុវត្តនៅក្នុងជួរបក្សសូវៀតផងដែរ។ នៅក្នុងសារព័ត៌មានមានការរាយការណ៍អំពីការជំនុំជម្រះ ហើយក៏មានការកោះហៅឲ្យមានការប្រុងប្រយ័ត្នចំពោះបដិវត្តន៍ ។

នៅក្នុងប៉ារីស បក្សកុម្មុយនីស្តបារាំងក៏គេមិនទុកចោលផងដែរ ទាក់ទងទៅនឹងគំរូសូវៀត ហើយពីខែកញ្ញា ទៅដល់ខែធ្នូ ឆ្នាំ១៩៥២ គឺមានការរៀបចំការជំនុំជម្រះរបស់ខ្លួនផងដែរ គឺមានការជំនុំជម្រះពីររូប គឺ សោតធីយ៉ុង និង ម៉ាទី ហើយក៏មិនមានការទោសប្រហារជីវិតនោះទេ ។ ប៉ុន្តែ គឺគេមានការដាក់ទោសមួយចំនួន ហើយការជំនុំជម្រះនោះគឺគេអនុវត្តនៅក្នុងអឺរ៉ុបខាងកើត ។

យើងឃើញថា នៅពេលនោះមានយន្តការរាយការណ៍អំពីកម្មាភិបាលទាំងឡាយ ហើយអ្នកដែលគាត់មានពិរុទ្ធភាព គឺគាត់មានការចោទប្រកាន់ទៅលើចារកម្ម ហើយអ្នកដែលជាប់ពាក់ព័ន្ធនោះ គឺ

មានការឃុំឃាំង ជាប់ឃុំផ្សេងៗ ។ ដូច្នេះ ជនជាប់ចោទ គឺគាត់បានសារភាពក៏ដោយ គាត់ក៏មានការបដិសេធមួយចំនួនផងដែរ ។ ជនជាប់ចោទគាត់បានបដិសេធថាគាត់មិនបានបម្រើនៅក្នុងវណ្ណៈខ្លាំងផងដែរ ។ ដូច្នេះចំណុចទាំងអស់នេះ គឺវាជាយន្តការទាំងឡាយក៏បានអនុវត្តនៅក្នុងស-២១ ។ យើងបានដឹងនៅបារាំងអ្នកដែលជាមេចម្បងនៃបក្សកុម្មុយនីស្តកម្ពុជា គឺពួកគេបានទទួលការអប់រំនយោបាយ ហើយនៅក្នុងការអប់រំនោះ គឺផ្អែកទៅលើគំរូសូវៀត ហើយនិងការអនុវត្តស្តាលីន ។ ដូចដែលខ្ញុំបានបញ្ជាក់ហើយ សិស្សម្នាក់នៅក្នុងនុំងគឺជាបុគ្គលដែលក្លាយទៅជាគ្រូ ហើយនិងជាមេផ្ទាល់របស់ជនជាប់ចោទ។ នៅពេលដែលគំរូសូវៀតបានបង្កើតទៅជាមនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យ យើងក៏គួរចាំអំពីការចូលរួមចំណែក នៃកុម្មុយនីស្តវៀតណាមផងដែរ ។

[១១:៤៨:២៥]

ការងារ-- ស្នាដៃរបស់ ហូ ជីមិញ ក៏វាទាក់ទងទៅនឹងស្តាលីន និងលេនីស្តហ្សឹម ហើយយើងដឹងៗហើយ គឺមានសន្និសីទ្ធជាច្រើនរៀបចំឡើង ហើយនៅក្នុងនោះក៏គេមានការពិនិត្យទៅលើលក្ខខណ្ឌទាំង២១ ។ គំរូមនោគមវិជ្ជារបស់វៀតណាម មានលក្ខណៈខុសពីសូវៀត ប៉ុន្តែយ៉ាងណាក៏ដោយ វាក៏មិនមែនដកដើមទាំងស្រុងនោះដែរ ប៉ុន្តែយើងត្រូវពិចារណាទៅលើប្រភពនៃមនោគមវិជ្ជាទាំងអស់នេះ។

នៅក្នុង១៩៥០ នួន ជា ត្រូវបានបណ្តុះបណ្តាល ។ ពីខែកញ្ញា ១៩៧៧ គឺជាមេផ្ទាល់របស់ជនជាប់ចោទ ។ ពីឆ្នាំ១៩៥២ ទៅដល់ឆ្នាំ១៩៥៥ នួន ជា គឺចំណាយពេលរយៈពេលបីឆ្នាំនៅវៀតណាមខាងជើង នៅក្នុងការងារនយោបាយ ។ នៅពេលនេះខ្ញុំសូមលើកឡើងនូវចំណុចចំនួនបី ទាក់ទងទៅនឹងវិធីសាស្ត្រនៃការ-- វិធីសាស្ត្រហិង្សា វប្បធម៌ហិង្សា ។

វិធីសាស្ត្រទីមួយ គឺវិធីសាស្ត្រវិប្បធម៌ហិង្សា គឺចំណុចនេះគឺមានការលើកឡើងមុនហើយ ខ្ញុំជាប្រធានកម្មវិធីយូណេស្កូ ហើយខ្ញុំត្រូវបានសិក្សាទៅលើហិង្សានៅក្នុងសង្គមកម្ពុជា ប៉ុន្តែយើងត្រូវតែដឹងថា អំពើហិង្សាទាំងអស់នេះមិនមែនថ្មីនោះទេ ។ អង្គហេតុប្រវត្តិសាស្ត្រ ហិង្សានយោបាយ គឺជាការបង្កើតនៅក្នុងសង្គមខ្មែរ ទោះបីជាវាមានលក្ខណៈកម្រិតទៅលើរយៈពេលដែលមាននៅក្នុងប្រទេសកម្ពុជាពេលឯករាជ្យក៏ដោយ នៅក្នុងឆ្នាំ១៩៥៣ យើងដឹងថា បក្សកុម្មុយនីស្តកម្ពុជានិងបក្សប្រជាធិបតេយ្យគឺជាអ្នកកៀបសង្កត់ និងមានការបះបោរនៅក្នុងសម័យសង្គមរាស្ត្រនិយម ហើយមានការបាញ់បោះ និងការសម្លាប់ផ្សេងៗ ហើយយើងឃើញមានរូបភាពមួយចំនួនដែលបង្ហាញអំពីអំពើហិង្សាទាំងអស់នោះកើតឡើង ។

នៅដើមឆ្នាំ១៩៥០ ជនជាប់ចោទ គឺនៅក្មេង ដែលគាត់មិនសូវយល់អំពីហេតុការណ៍ទាំងអស់នេះ ។ ការសម្លាប់ ណុប បូផាន់ នោះ គឺជាអ្នកនិពន្ធនាយកនៃកាសែតប្រជាជនឆ្វេងនិយមនោះគឺ ដូចជាការវាយប្រហារទៅលើ ខៀវ សំផន ដែលជាអ្នកនិពន្ធនាយកនៃកាសែត*ឡប់សេរ៉ាទ័រ* (ឮមិនច្បាស់) នៅឆ្នាំ១៩៦០ ហើយត្រូវបានចាប់ខ្លួនក្រោយមក ។ ពេលនោះអ្នកនិពន្ធរបស់សារព័ត៌មានឆ្វេងនិយមត្រូវបានទទួលទារុណកម្ម ហើយក្រោយមកត្រូវបានគេដោះលែងវិញ ហើយក៏បិទកាសែតហ្នឹង ហើយនិងការទទួលក្នុងឆ្នាំ១៩៦២ នូវលេខាបក្សរបស់គេ អ៊ីចឹងគឺថា ជាគំនិតមួយនៅក្នុងឆ្នាំ១៩៦៣ និយាយអំពីការសម្លាប់នៅ ព្រាប អ៊ិន ហើយនៅឆ្នាំ១៩៦៣ អំពើហិង្សា គឺកំណត់ពីអំពើហិង្សានៅក្នុងនោះ ។

[១១:៥២:០៦]

នៅពេលដែលជនជាប់ចោទអាយុ២០ឆ្នាំនោះ គឺវាមានអង្គហេតុមួយចំនួនដែលគ្រប់គ្រាន់ដែលថាអាចធ្វើឲ្យប្រជាជនកុំឲ្យធ្វើអំពើហិង្សាលើជនដែលជាប់ក្នុងមន្ទីរឃុំឃាំង ។ នៅក្នុងសម័យសង្គ្រាមវៀតណាមដោយអាមេរិកាំង គឺថាអំពើហិង្សាចេះតែរាលដាល គឺចេញទៅខាងក្រៅ ហើយក៏វាមាននៅក្នុងស្រុកនោះដែរ ។ ភូមិនានានៅកម្ពុជានៅជាប់ព្រំដែនវៀតណាមត្រូវបានវាយប្រហារដោយទ័ពវៀតណាមខាងត្បូងដែលដឹកនាំដោយមេដឹកនាំអាមេរិកាំង ដែលធ្វើឲ្យមនុស្សស្លាប់ជាច្រើន ហើយមានប្រតិបត្តិការសឹកមួយ គឺគ្រាប់បែក B52 ក៏បានទម្លាក់ ក៏បានបណ្តាលឲ្យជនស៊ីវិលបាត់បង់ជីវិតរាប់ពាន់នាក់ ហើយអំពើហិង្សាពីអាជ្ញាធរកម្ពុជាក៏មិនបានចុះថយដែរនៅពេលនោះ ។

អ្នកណាជាអ្នកតទល់ដូចថានៅក្នុងឆ្នាំ១៩៦៧និង៦៨ នោះ គឺមូលហេតុនយោបាយគឺបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានទទួលស្គាល់ គឺជារបបមួយដែលថា គេមិនអាចតស៊ូបាន គឺថាមានការទម្លាក់គ្រាប់បែកស្លាប់ជនស៊ីវិល ហើយក៏វាមានការសម្លាប់ជាច្រើនដោយឃោរឃៅ ។ ដូច្នេះ អំពើហិង្សាចេះតែកើនឡើង ដែលថាអាចចេះតែមានតទៅ ដោយមានការជំរុញប្រទេសឲ្យទៅជាសង្គ្រាម នៅក្នុងឆ្នាំ១៩៧០ ដែលថាមានរដ្ឋប្រហារគាំទ្រអាមេរិកាំង ដែលមានរដ្ឋាភិបាលមួយ ដែលមានការបង្ក្រាបដូចថាមានមនុស្សស្លាប់ច្រើន ដែលថាអ្នកភូមិជាច្រើននៅក្នុងនោះផង ។

ជនស៊ីវិលត្រូវបានគេសម្លាប់ ដោយសារមូលហេតុថាគេមានជនជាតិដើម អ៊ីចឹងហើយអាចជាអ្នកកាន់សាសនាអ្វីមួយ ឬក៏ជាជនជាតិវៀតណាម ដែលជំរុញឲ្យវាមានការចាប់អារម្មណ៍ដល់អន្តរជាតិនូវចំណុចមួយ ។ ប៉ុន្តែការទម្លាក់គ្រាប់បែកឃោរឃៅដោយអាមេរិកនោះមិនបានមើលច្បាស់លាស់នោះ គឺធ្វើឲ្យមានកំហឹងទូទាំងប្រទេស ។

ដូច្នេះយើងត្រូវរំឭកឡើងវិញថា យើងដឹងដូចប្រធានាធិបតី គ្លីនតុន បានប្រកាសថា ឯកសារដែលទាក់ទងទម្លាក់គ្រាប់បែកនៅកម្ពុជានោះ លែងជាការសម្ងាត់នោះ វាជាងពីរលានតោនដែលទម្លាក់នៅកម្ពុជា ចាប់ពី តុលាកា ឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣ ។ គឺថាតំបន់ជាងពីរពាន់ គឺថាគ្រាប់បែកពីរពាន់បានទម្លាក់ឆ្នាំ១៩៤២ ដល់៤៣ ហើយមានមួយលានបីសែនតោនត្រូវបានទម្លាក់នៅប្រទេសអាល្លឺម៉ង់ ឆ្នាំ១៩៤៣ ដល់៤៥ ។ អ៊ីចឹងនឹងនិយាយពីបរិបទមនុស្សធម៌វិញ មិនមានប្រទេសណាមួយ មិនមានប្រទេសណាត្រូវបានរងគ្រាប់បែកច្រើនដូចកម្ពុជានោះទេ ។ ដូច មេមត់ និងស្នួល ដែលជាកន្លែងមួយ តាកែវ, កំពត ក៏ត្រូវបានជាកន្លែងទៅជនបះបោរ ហើយគេមានប្រឡាយ ទំនប់ ស្រែ ត្រូវបានបំផ្លាញ ។ ភូមិជនស៊ីវិលក៏ត្រូវបានទម្លាក់ ហើយក៏ធ្វើឲ្យបំផ្លាញព្រៃឈើច្រើនរយហិចតា នៅក្នុងឆ្នាំ១៩៧០ ដល់ ៧៣ ហ្នឹង ការវាយប្រហារហ្នឹងគឺថាមានអំពើហិង្សាច្រើននៅក្នុងទីតាំងនានា ។

[១១:៥៦:០៩]

មានទារុណកម្មជាប្រព័ន្ធ មានអំពើកាត់ក្បាលមនុស្ស ហើយចាប់ពីពេលនោះតទៅអ្វីៗនោះគឺដូចជាគ្មានការហាមឃាត់ ឬក៏មិនមានការទទួលស្គាល់ពីមនុស្សធម៌ទេ គឺកម្ពុជាបានធ្លាក់ចូលទៅក្នុងអំពើហិង្សាហើយទទួលនូវអណ្ដាតភ្លើងសង្គ្រាម ហើយអ្វីៗហ្នឹងគឺថាគេអាចទទួលស្គាល់ថា គេរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ។ អំពើហិង្សាគឺផុសចេញពីជម្លោះវិវាទ ហើយក្លាយទៅជាវិធាន ហើយជាកត្តាផុយស្រួយ ដែលគឺថាជាដំណោះស្រាយប្រើដើម្បីដោះស្រាយជម្លោះទៅវិញ ។

ប្រភពទីពីរនោះ គឺថាអំពើហិង្សានយោបាយមួយចំនួន គឺថាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដូចខ្ញុំនិយាយគឺថាមេដឹកនាំភាគច្រើនរបស់កម្ពុជាប្រជាធិបតេយ្យ គឺបានទទួលការបណ្ដុះបណ្ដាលនៅប្រទេសបារាំង ហើយក៏អនុវត្តនូវនយោបាយកុម្មុយនីស្ដ ។ ប៉ុន្ដែ គោលការណ៍លេនីន គឺទាក់ទងដំណើរការបក្សគឺថាអាចនឹងជាកត្តាមិនច្បាស់លាស់ គឺគេអាចស្វែងរកអ្នកដែលនៅក្នុងបក្សរបស់គេ ដែលមិនគោរពវិន័យ ឬក៏គេថាជាខ្មាំង ។

នៅឆ្នាំ១៩៤៩ តមកនោះ មានសេចក្ដីណែនាំនិងសរសេរដោយ *រេចខូហ្ស៊ីល(*Rākosi*)* គឺគេបក្សកុម្មុយនីស្ដហុងគ្រី គឺបាន ក្រោយមកក៏ត្រូវបានគេកាត់ទោសនៅអឺរ៉ុប គឺគេបកប្រែថា ទ្រឹស្ដីរបស់គាត់ជារូបមន្ដ ។ អ៊ីចឹងហើយគឺថាអាចនឹងចាប់ជន-- សុខចិត្តចាប់អ្នកខុស ប៉ុន្ដែកុំឲ្យលែងអ្នកដែលសង្ស័យថាខុស ។ នេះហើយគឺជាទស្សនៈមួយ ។ អ៊ីចឹងហើយការកំណត់នេះ គឺគំនិតនេះមាននៅក្នុងបក្សកុម្មុយនីស្ដកម្ពុជា គឺត្រូវល្អ គឺចាប់មនុស្សខុសដប់នាក់ ជាជាងលែងខ្មាំងម្នាក់ដែលយើងយល់ថាជាខ្មាំង ។

អ៊ីចឹងហើយយើងកត់សម្គាល់ថា គឺថានេះជាចំណុចមួយដែលធ្វើឲ្យយើងអាចនឹងការបំបាត់សិទ្ធិ ហើយនិងការបំបាត់នូវអាយុជីវិតនោះ ប៉ុន្តែតាមពិតយើង នៅក្នុងសៀវភៅរបស់គាត់ដែលនិយាយអំពីក្តីគ្មានមេត្តានោះ គឺថាគាត់គឺជាសមាជិកបក្សកុម្មុយនីស្តអាល្លឺម៉ង់នោះ ហើយគាត់និយាយថា ដើម្បីនិយាយអំពីគំនិតមួយគឺថា ដើម្បីឲ្យឈ្នះបានត្រូវតែសម្លាប់ ។ អ៊ីចឹងមេដឹកនាំកម្ពុជាប្រជាធិបតេយ្យវិញ គឺប្រើទស្សនទានរបស់សូវៀត ជាបក្សកុម្មុយនីស្ត គឺថាដែលសមាជិកភាគច្រើន ដែលត្រូវបានរៀនសូត្រនៅប៉ារីស ។

[១១:៥៨:៥៨]

នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាស្ថិតនៅក្រោមមជ្ឈិមបក្ស ឬក៏អចិន្ត្រៃយ៍នោះ គឺថាគេមានអំណាចពេញដៃ គឺថាមានមនុស្ស៧នាក់ ហើយនិងមានសមាជិកត្រៀមពីរ ហើយក្រុមនេះគឺ ជាអ្នកកាន់អំណាច ហើយ សុន សេន គឺជាសមាជិកមួយនៅក្នុងគណៈមជ្ឈិម ដើម្បីអនុវត្តការងារ ដោយប្រើនូវពាក្យដូចថា មន្ទីរ៨៧០ គឺថាជាអ្នកប្រើអំណាចក្នុងនាមបក្ស តាមរយៈមជ្ឈិមបក្ស ហើយនិងការគ្រប់គ្រងសេដ្ឋកិច្ច ហើយនិងការពារ ហើយនិងសន្តិសុខ ។ គណៈអចិន្ត្រៃយ៍ គឺសម្រេចថាខ្លួនមានអំណាចផ្តាច់មុខនៅក្នុងប្រទេស នៅក្នុងបក្ស នៅក្នុងជួររដ្ឋផងដែរ ។

ចំណុចទីពីរ ការអនុវត្តរបស់បក្ស គឺថាវិន័យក្តី គឺដើម្បីការបង្ក្រាបដោយការកម្ទេច គឺថាខ្មាំងផ្ទៃក្នុង និងផ្ទៃក្រៅ គឺមិនមែនដោយសារនយោបាយទេ គឺមិនមែនដោយសារនយោបាយទេ គឺៗការកម្ទេចនោះគឺ ការបំបាត់នោះ ដោយប្រើពាក្យកម្ទេចមានន័យថា ការពន្យល់របស់ជនជាប់ចោទ គឺចាប់មនុស្សដោយសម្ងាត់ សំណួរដោយប្រើទារុណកម្ម បន្ទាប់មក គឺសម្លាប់ ហ្នឹងពាក្យថា “កម្ទេច” មានន័យបែបនេះ ។

ហើយនៅក្នុងឯកសារស-២១ ឆ្នាំ១៩៧៦ ដែលគេហៅថា សៀវភៅទារុណកម្មជាវិធីសាស្ត្រដើម្បីទាញយកចម្លើយ និយាយថា គោលបំណងគឺយកចម្លើយឲ្យបានច្រើន ។ ដូចជានៅក្នុងៗការជំនុំជម្រះប្រាប់នោះ គឺថាហ្នឹងគឺដែលការបោះពុម្ពផ្សាយឆ្នាំ១៩៦៨ហ្នឹង គឺជាអ្វីដែលគាត់ថ្លែងពីទារុណកម្មរបស់គាត់នោះ គឺគេហៅថា ជាចម្លើយសារភាព ។

នៅការសម្ភាសន៍មួយជាមួយជនជាប់ចោទ ទាក់ទងទៅនឹងការបណ្តុះបណ្តាលដើម្បីឲ្យទទួលបន្ទុកមន្ទីរសន្តិបាលនោះ គាត់និយាយថា ប៉ុល ពត ហើយ សុន សេន អត់ចង់ឲ្យយើងប្រើការអនុវត្តរបស់សូវៀត ដូច ប៉ុយការ៉េស គឺថាមិនមាន-- ។

អ៊ីចឹងហើយនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមបំបាត់នូវឃោធាដែលល្អរបស់ខ្លួន ដូចជាអតីតសមាជិកសំខាន់ៗដូច ឈូក រិន ហើយពួកខ្មែរឥស្សរៈគឺថា អាចហ្នឹង គឺមានគណនាគឺជាអតីតខ្មែរឥស្សរៈ ។ អ៊ីចឹង គឺថាគេអាច ក្រោយមកគេចូលរួមនៅក្នុងរដ្ឋប្រហារនៅថ្ងៃ-- គឺថាអ្នកទាំងអស់នោះត្រូវបានគេសម្លាប់នៅចន្លោះឆ្នាំ១៩៧៥ដល់៧៦ ។

ហើយអ្នកផ្សេង ខៀវ ពិន គឺការ-- សៀង សាវយ៉ាន់... គឺថាគឺជាសមាជិក, ភោគ ឆាយ ជាបញ្ញវន្ត គឺត្រូវបានកាត់ទោសសម្លាប់ ។ ទាំងនេះហើយជាអតីតគ្រូខាងឆ្វេងនិយមស្តាំនិយមក៏ដោយ គឺថាអាចហ្នឹងត្រូវ ហ៊ូ យន់, ហ៊ូ នឹម ហើយស្ថិតនៅក្នុងសង្គមរាស្ត្រនិយម នៅសល់ប៉ុន្មានត្រូវបានសម្លាប់ទាំងអស់ហើយ ។

ទោះបីជាមិនមែនជាលើក-- ឃើញថាមានឃោរឃៅមានដូចជា ណាត ក្រោយមកក៏ត្រូវបានគេសម្លាប់ ក្រោយមក វន វ៉េត, គង់ សុផល ត្រូវសម្លាប់ឆ្នាំ១៩៧៨ ដើម្បីជាការអំណាចដឹកនាំនៅ ១៩៩៨ ជាកន្លែងសន្តិសុខហ្នឹង គឺថាមានខ្លះនៅរួចរានមានជីវិត ហើយប្រធាននៅកន្លែងនោះក៏មិនទាន់ត្រូវបានចោទប្រកាន់នោះដែរ ។

ហើយចំពោះកម្មាភិបាលទាំងអស់នៃបក្សកុម្មុយនីស្តកម្ពុជានោះ គឺថាគឺគេបញ្ជាក់ថា មិនមាននរណាម្នាក់មានសុវត្ថិភាពទេ គឺថាមានប៉ែតសិបភាគរយនៃជនរងគ្រោះស-២១ គឺត្រូវបានរងផលពីការអនុវត្តមាគ៌ានយោបាយបក្សកុម្មុយនីស្តកម្ពុជាគឺថាជនរងគ្រោះខ្លះអាចហ្នឹងរស់រាន ។ ហើយអ្នកផ្សេងទៀតនោះក៏ថាអាចនឹងរស់រានមានជីវិត ។ បក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ១៩៦៣មក គឺថាធ្វើដំណើរការរបស់ខ្លួនគឺជាសម្ងាត់ ហើយនិងវិធីរបស់គេហ្នឹងគឺក្លាយជាទម្រង់នៃការទទួលដឹកនាំចាប់ពីឆ្នាំ១៩៧៥មកអំណាចពេញដៃ ។ នៅពេលដែល-- ពីមុននៅពេលដែលរណសិរ្សរួបរួមជាតិបានបង្កើតឡើង គេចង់បានកម្លាំងនយោបាយនៅខាងក្នុង ហើយមេដឹកនាំគឺត្រូវរក្សាការសម្ងាត់ ។ ប៉ុន្តែ នៅក្នុងសម័យសង្គ្រាមរណសិរ្សរួបរួមនេះបុគ្គលមួយចំនួន គឺ ហ៊ូ យន់, ហ៊ូ នឹម និង ខៀវ សំផន គឺថាមានមនុស្សរាប់ម៉ឺននាក់បានរត់ចូលទៅក្នុងព្រៃទៅចូលរណសិរ្សរួបរួមជាតិកាលនោះ ។

[១២:០៤:៣៥]

មានតែគេចូលចិត្តកម្មវិធីរបស់គេ ប៉ុន្តែគេមិនដឹងថា ចំណុចសំខាន់របស់រណសិរ្សជាកុម្មុយនីស្តនោះទេ ប៉ុន្តែគេដឹងតែពីមេដឹកនាំរបស់-- ។ ប៉ុន្តែ រហូតមកដល់ឆ្នាំ១៩៧៥ នៅពេលដែលរណសិរ្សរួបរួមជាតិកម្ពុជាទទួលជោគជ័យ គឺថារហូតមកដល់ឆ្នាំ១៩៧៣ គឺមានតែពួកនោះហើយដែលជាចាប់ផ្តើម

ទាំងនោះហើយ ពួកគេជាអ្នកស្ថិតនៅក្រោមអំណាចរបស់-- ក្រោយមកដោយ ប៉ុល ពត ។

ហើយនៅឆ្នាំ១៩៧៥ ខែមេសា នោះ គេពិនិត្យខ្លួនឯងថា អាចហ្នឹងប្រើនៅក្នុងន័យដែលថា សម្ងាត់មួយ ជាពាក្យគេហៅថា “អង្គការ” នោះ ។ មានន័យថាសំខាន់ណាស់ ដើម្បីឲ្យគេរក្សាការសម្ងាត់ គឺ សុន សេន បានបញ្ជាក់អ៊ីចឹង គឺថា សេរីភាព និងធ្វើអ្វីដោយ-- អ៊ីចឹងហើយ គឺការសម្ងាត់ គឺស្នូលនៃការងាររបស់គេ ដើម្បី-- ។ បើសិនជារក្សាការសម្ងាត់ យើងរក្សាបាន ហើយអ្វីៗដែលអង្គការបញ្ជាត្រូវតែធ្វើ ហើយធ្វើទៅតាមតែអង្គការបញ្ជាគ្រប់ដំណាក់ជាន់ថ្នាក់របស់ប្រទេសត្រូវធ្វើតាមអង្គការទាំងអស់ ។

នេះគឺជាចំណុចឯកច្ឆន្ទដែលធ្វើឲ្យអំណាចរបស់គេនោះផ្តាច់មុខ ហើយគេរក្សានិរន្តភាព ហើយអារម្មណ៍នៃការតានតឹងហ្នឹងក៏មិនអាចហ្នឹងបះបាលបាន ដោយសារអង្គការហ្នឹងមានអំណាចរឹងមាំ ។ ដូចជាការជម្លៀសដោយបង្ខំនៅទីក្រុង ដូចជាការបង្កើតសហករណ៍ដោយបង្ខំ ការលុបចោលនូវរូបិយ-ប័ណ្ណ ហើយនិងការរៀបចំសង្គមជាថ្មីនោះ ត្រូវបានបង្កើតឡើងដោយអំណាចរបស់អង្គការ ។ ទិដ្ឋភាពគ្រប់យ៉ាងនៃជីវិតប្រចាំថ្ងៃ គឺស្ថិតនៅក្រោមអង្គការ ដែលមានការភ័យខ្លាចអង្គការនៅពេលដែលគេហៅទៅកន្លែងណាមួយ ហើយក៏មិនឃើញត្រឡប់មកវិញទេ ។ ហើយអ៊ីចឹងហើយវាមានការកាប់សម្លាប់កើត-- អង្គការតម្រូវឲ្យមានការស្មោះត្រង់មួយរយភាគរយចំពោះខ្លួន បើសិនជាមិនបានធ្វើទេ គឺអាចហ្នឹងត្រូវរាយការណ៍ ឬក៏ចាប់ ឬក៏បញ្ជូនទៅសម្លាប់នោះ ។ អ៊ីចឹងហើយត្រូវតែមានអាកប្បកិរិយាប្រុងប្រយ័ត្ន ហើយដោយមានគេតាមដានទូទាំង-- គ្រប់ទីកន្លែងនេះ ហើយធ្វើឲ្យម្នាក់ៗហ្នឹងក្លាយទៅជាអ្នកតាមដានអ្នកផ្សេងទៀត ។

អ៊ីចឹងហើយធ្វើយ៉ាងម៉េច ដើម្បីឲ្យគ្រឿងម៉ាស៊ីននៃសន្តិសុខនោះ គោរពទៅតាមអង្គការ ដែលតម្រូវដោយបក្សកុម្មុយនីស្តកម្ពុជា ដូចជានៅអាណាចក្ររុស្ស៊ីគឺថាវាហ្នឹងស្រដៀងគ្នាគឺថាគេអាចនឹងប្រើតាមគំរោង ដែលប្រើនៅក្នុងរបបស្តាលីន ហើយនៅក្នុងនោះគេនិយាយថា យើងត្រូវទុកចិត្តបក្ស ហើយនិងឲ្យបក្សជាអ្នកដឹកនាំអ្នក ។ ហើយគំនិតដែលយកមកប្រើតាមនេះ គឺអ្នកធ្វើទារុណកម្មនៅក្នុងស-២១ នោះ គេសរសេរនៅក្នុងសៀវភៅរបស់គេនោះ គឺថាចំណុចសំខាន់នោះគឺត្រូវជឿឲ្យដាច់ខាតលើបក្ស ឬក៏ត្រូវជឿបក្ស ដើម្បីគោរពការណែនាំរបស់បក្សឲ្យបានដាច់ខាត ដោយគ្មានលក្ខខណ្ឌ ។

[១២:០៨:២៤]

នៅចំណុចទីបី នៅចុងក្រោយនៃអំពើឃោរឃៅរបស់បក្សនោះ គឺថា ប៉ុល ពត របស់កុម្មុយនីស្ត

នេះ កម្ពុជាប្រជាធិបតេយ្យដែលខ្ញុំហៅថា ប៉ុល ពត និយមនេះ គឺថាវាមានលក្ខណៈពិសេសមួយចំនួននៅពេលដែលដាក់បញ្ចូលជាមួយ ។ គឺថាអាចហ្នឹងមានការបកស្រាយពិសេស គឺថានៅទ្រឹស្តីម៉ាក្សស៊ីសនោះ ។ ការបកស្រាយនោះក៏បានសង្កត់ធ្ងន់អំពីភេរវកម្មផ្លូវរដ្ឋដែលនិយាយពិសេស ដើម្បីឲ្យខ្លួនក្លាយទៅជារបបផ្តាច់ការនិយម ។

ប៉ុល ពត មិនមែនជាអ្នកអន្តរជាតិនិយម គឺគាត់ជាជាតិនិយម ហើយក៏អាចពង្រីកនៅទម្រង់ជាតិនិយមដែលកំណត់នូវដែនដី ហើយនឹងកំណត់នូវអត្តសញ្ញាណរបស់ខ្លួននៅក្នុងសេចក្តីថ្លែងការណ៍ គឺថានិយាយអំពីដែនដី ហើយដែលបាត់បង់ហើយត្រូវតែកាន់កាប់ដែនដីនោះវិញនៅពេលដែលយើងឲ្យថាកន្លែងណាដែលមានសរសេរអក្សរខ្មែរនោះជារបស់ខ្មែរ ។

ដូចជាៗ ការងប់ងុលទៅចង់បានដីដូចថានៅវៀតណាម ដូចជានៅក្នុងឆ្នាំ១៩៧៧ វាមានជម្លោះប្រដាប់អាវុធជាដើមរវាងប្រទេសទាំងពីរ គឺឈានទៅដល់ឲ្យមានការសម្លាប់មនុស្សរាប់ម៉ឺននាក់ដោយមិនមានហេតុផល ពីព្រោះថា គ្រាន់តែចោទថា ក្បាលយួនខ្លួនខ្មែរជាដើមអ៊ីចឹង ។ ហើយគឺត្រូវមានគំរូមួយសម្រាប់ប្រជាជនរបស់គេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

គេមិនដែលទទួលបានការគាំទ្រពីប្រជាជននោះទេ ហើយជាគំនិតមួយដែលពីដំបូងឡើងផ្តួចផ្តើមដោយសម្តេច សីហនុ ក៏ប៉ុន្តែក្រោយក្លាយទៅជារបបបែបនោះ ។ ប៉ុន្តែ នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាដែលក្រោមដៃដឹកនាំរបស់ ប៉ុល ពត ហើយប្រព័ន្ធនោះ គឺមិនដែលៗមានការគាំទ្រទៅលើបក្សនេះ គឺថានៅមុនឆ្នាំ១៩៧៥នោះ គឺរឿងបែបនេះ ។

ប៉ុន្តែក្រោយមកនៅក្នុងសម័យដែលខ្លួនកាន់កាប់ គឺថាគេអាច-- គេមិនអាចចៀសផុតអំពីចរិតលក្ខណៈរបស់ ប៉ុល ពត មានន័យថា ការដឹកនាំត្រូវតែធ្វើទៅតាមលំដាប់លំដោយ ត្រូវតែគោរពការណែនាំតាមដានដេញខ្លាំង គឺដែលហៅថា “ខ្មាំងស៊ីរូងផ្ទៃក្នុង” ។

[១២:១១:០៩]

ឆ្នាំ១៩៧៦ គឺថា ដោយសេចក្តីសម្រេចលើបញ្ហាមួយចំនួន គឺថាអំពីការសម្រិតសម្រាំងក្នុងជួរបក្សនិងក្រៅបក្សជាដើមហ្នឹង ។ អ៊ីចឹងហើយជាឆន្ទៈមួយដែលមានជាពាក្យស្លោក គឺថា ពិនិត្យមើលក្នុងកងកម្លាំងរបស់ខ្លួន ដើម្បីមើលស្មារតីសតិអារម្មណ៍ ដើម្បីពង្រឹង ថាតើមានអ្នកក្បត់ឬទេ ។ នេះហើយគឺជាគំនិតមួយ ដែលថា ប៉ុល ពត លើកឡើងត្រូវពិនិត្យភាពបរិសុទ្ធនៃសង្គមខ្មែរ ។ អ៊ីចឹងហើយពាក្យស្លោក គឺថាថ្នាក់ដឹកនាំខ្ពស់ចេះតែលើកអំពីគំនិតហ្នឹង អំពីការកំណត់ គឺថាការបំបាត់ក្រុមមួយចំនួន

ដែលថា មិនទុកឲ្យមានខ្មែរកាត់ចិន កាត់ចាមអ្វីទៀតនោះទេ ។ គឺថាដូចជាការបំផុតពូជសាសន៍មួយចំនួន ។

បន្ទាប់មក គឺថាវាមានការជម្លៀសដោយក្រុមជនជាតិភាគតិច ហើយនិងការចងក្រងនៅជាសមូហភាពនៃកសិកម្មជាដើម ដើម្បីធ្វើជាវិធានការផលិតកម្ម គឺថាមិនមានៗទំនិញ មិនមានដែនដីណាមួយ មិនមានទ្រព្យជារបស់ឯកជនណាម្នាក់ទៀតទេ ។ សេចក្តីសម្រេចនេះ គឺវាផ្តាច់ការ គឺបដិសេធទាំងអស់ ។ ជាពិសេសទៅទៀត គឺគេមិនឲ្យប្រើអត្តសញ្ញាណផ្ទាល់ខ្លួន គឺអ្វីៗធ្វើនៅក្នុងអង្គការ ហើយកម្មាភិបាលរបស់បក្ស គឺថាបុរសនិងស្ត្រីអាចជាប្តីប្រពន្ធ គឺក្នុងនាមជារបស់អង្គការ របស់សហករណ៍តែប៉ុណ្ណោះ ។

ដូច្នេះ គេមិន-- គេជាម្ចាស់ទៅលើឧបករណ៍តូចតាចដែលគេប្រើផ្ទាល់ខ្លួននោះទៅទៀត នេះហើយគឺជាប្រវត្តិនៃមនុស្សធម៌ដែលថា ប្រព័ន្ធសមូហភាពនោះវាទៅឆ្ងាយពេក ដូចដែលគេប្រើនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងប្រវត្តិជាតិមិនដែលមានការបំផុតកិត្តិសព្ទ ឬសេចក្តីថ្លៃថ្នូរមនុស្សបែបនេះទេ មិនដែលធ្លាប់មានរបបនយោបាយបានប្រើនូវការបំបាត់នូវអត្តសញ្ញាណផ្ទាល់ខ្លួន ឬកម្មសិទ្ធឯកជនបែបនេះទេ ។ ប៉ុន្តែប្រជាជនទាំងមូលដែលរាប់បញ្ចូលទាំងអ្នកដែលបម្រើឲ្យបក្សផងនោះ គឺ ប៉ុល ពត និយមនេះ គឺសម្តែងនូវមហិច្ឆតាចូលឲ្យដល់ការប្រើសង្គមថ្មី ឲ្យមានសង្គមថ្មី ដែលមិនចាំបាច់មានអន្តរកាល ។ គាត់ប្រកាសថា គាត់ធ្វើបានល្អជាងស្តាលីន លេនីន ជាងចិនទៅទៀត ដើម្បីថាគាត់បង្កើតសង្គមឲ្យបានបំផ្លែងលឿនបំផុតឲ្យមានភាពតឹងរ៉ឹង គឺថាត្រូវឲ្យមានស្មើភាពគ្នាទាំងអស់ហ្នឹង ។ នៅទីបំផុតនៅក្នុងលទ្ធិប៉ុលពតនិយម គាត់និយាយ មិនដែលធ្លាប់មាននៅក្នុងប្រវត្តិនៃមនុស្សលោកនេះទេ ។ គឺជាការអវិជ្ជមានចំពោះមនុស្សជាតិ ដូចជា-- គឺថានៅក្នុងចិត្តហ្នឹង គឺថាមិនមានស្មារតីនៃអំណត់ ហើយបើសិនថា ជាខ្មាំងហើយអ្នកណាដែលជំទាស់ គឺលទ្ធផលគឺជាការសម្លាប់ ។

[១២:១៤:៤៨]

លោកប្រធាន លោកស្រីចៅក្រម! ជនជាប់ចោទបាននិយាយថា គាត់ជាជួយប្រព័ន្ធហ្នឹង ហើយគាត់ជាអ្នកទោសរបស់របបនោះដែរ ។ ប៉ុន្តែនៅក្នុងកាលវិភាគនោះគឺអ្វីដែលជនជាប់ចោទនិយាយនោះទំនងជាការពិតក៏ដូចជានៅក្នុងសតវត្សរ៍នេះគឺ-- អ៊ីចឹងនៅក្នុងរបបណាហ្ស៊ី ឬក៏កុម្មុយនីស្តបារាំងនោះគេបាននិយាយថា យើងបដិសេធ ហើយបើយើងចង់ត្រលប់ទៅជាមនុស្សជាតិអ្វីដែលជាចំណុចសំខាន់

ហើយយើងពិនិត្យមើលថាយើងស្ថិតនៅក្នុងកម្រិតមួយខ្ពស់នៃការដឹកនាំកម្ពុជា បុរស និងស្ត្រីគឺថាអាច--ចំណុចដែលថាយើងមានសេរីភាពគឺថាយើងសម្តែងអ្វីបាន ។ យើងមិនត្រូវបើកទ្វារមានភាពឃោរឃៅនោះជាថ្មីម្តងទៀតទេ ។ បើសិនជាយើងបើកទ្វារ គឺថានឹងយើងអាចដើរជាន់ប្រវត្តិសាស្ត្រអាក្រក់របស់យើងវិញ ។ ចំពោះអ្នកដែលគោរពដោយយតិភាព ដោយពេញចិត្ត ពេញថ្លើមនោះ ត្រូវតែគោរពទៅតាមគោលការណ៍របស់គេ ។

ខ្ញុំអាចនឹងសន្និដ្ឋានជូនលោកប្រធានថា អ្នកណាអាចនឹងប្រឈមមុខនឹងស្ថានភាពទ្វេរគ្រោះដែលត្រូវសម្លាប់គេ ដើម្បីកុំឲ្យគេសម្លាប់ខ្លួន ។ តើជននោះអាចថាគាត់បានធ្វើពលិកម្មចុងក្រោយដូចម្តេចនឹងកើតនោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក វ៉ាអ៊ួល ម៉ាកចេនណា ដែលបានធ្វើបទបង្ហាញយ៉ាងក្បោះក្បាយពាក់ព័ន្ធជាមួយនឹងប្រធានបទដែលស្នើសុំជូនអ្នកជំនាញក្នុងការធ្វើបទបង្ហាញនេះ។ ប៉ុន្តែ ឥឡូវនេះដល់ពេលត្រូវសម្រាកពិសារអាហារថ្ងៃត្រង់ហើយ ។ ប៉ុន្តែដំណើរការប្រព្រឹត្តក្នុងការស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកជំនាញឃើញថាមិនទាន់ចប់នៅឡើងទេ ដោយត្រូវតាំងសំណួរជាក់លាក់ពីអង្គជំនុំជម្រះនិងភាគីឯទៀត ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញអ្នកជំនាញ វ៉ាអ៊ួល ម៉ាកចេនណា សូមអញ្ជើញលោកអញ្ជើញត្រលប់មកវិញ ដើម្បីបន្តការសវនាការនេះក្រោយពេលអាហារថ្ងៃត្រង់ ។ គឺចាប់ពីម៉ោងមួយនិងសាមសិបនាទី ។

ហើយឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកពិសារអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយនិងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការរបស់យើង ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោយឈរ!

*[អង្គសវនាការសម្រាកពីម៉ោង ១២:១៨ នាទីដល់ម៉ោង ១៣:៣៤ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាកិច្ចបន្តនេះ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីដែលត្រូវសួរដល់អ្នកជំនាញរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** អ្វីដែលខ្ញុំឮពីលោកព្រឹកមិញនេះ លោកមានឱកាសបានជួបសម្ភាសជាមួយជនជាប់ចោទ។ លោកបានប្រាប់យើងថា បានប្រភពអំពីមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាប្រភពនៃមនោគមវិជ្ជានោះផង ។ ខ្ញុំចង់ដឹងថា តើលោកបានដាក់នៅក្នុងរបាយការណ៍ក្រោយពីសម្ភាសន៍ជាមួយជនជាប់ចោទដែរឬទេ? ក្រោយមកលោកនិយាយអំពីវប្បធម៌នៃអំពើហិង្សាដែលញាំញីដល់ប្រទេសនេះ?

យើងបានសួរសំណួរមួយចំនួនដែលនឹងទាក់ទងទៅនឹងអំពើហិង្សានយោបាយ ដែលជនជាប់ចោទបានទទួលរង ។ នៅពេលដែលលោកបាននិយាយជាមួយជនជាប់ចោទ តើលោកអាចប្រាប់យើងបានដូចម្តេច ថាតើជនជាប់ចោទឆ្លើយលោកដូចម្តេចពេលនោះ?

**ឆ៖** សូមអរគុណលោកប្រធាន លោកចៅក្រម។ ខ្ញុំបានពិភាក្សាជាមួយជនជាប់ចោទវែងឆ្ងាយអំពីប្រភពផ្សេងៗអំពីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែខ្ញុំមិនបាននិយាយជាក់លាក់អំពីបញ្ហាអំពើហិង្សាអំពើហិង្សានយោបាយនោះទេ ។ អ្វីដែលខ្ញុំបានពិភាក្សាព្រឹកនេះ គឺផ្អែកលើការស្រាវជ្រាវប្រវត្តិសាស្ត្ររបស់ខ្ញុំ អំពីរយៈកាលដែលទាក់ទងទទួលឯករាជ្យរបស់ប្រទេសនេះឆ្នាំ១៩៥៣មក ខ្ញុំមិនបាននិយាយអំពើហិង្សានយោបាយជាមួយជនជាប់ចោទទេ ។

**ស៖** ដូច្នេះ គាត់មិនដែលប្រាប់លោកថា អំពើហិង្សានយោបាយជាអ្វីដែលគាត់ទទួលស្គាល់ក្នុងការតស៊ូរបស់គាត់ ។ ហើយថាអំពើនោះ គឺជាឫសគល់នៃរបបកម្ពុជាប្រជាធិតេយ្យ ។

[១៣:៣៧:២២]

**ឆ៖** សូមទោសខ្ញុំមិនអាចនិយាយពីអ្វីដែលគាត់មិនបានប្រាប់ខ្ញុំនោះទេ ប៉ុន្តែវាអាចជាលទ្ធភាពមួយដែលបុគ្គលអាចនឹងមានគំនិតអំពីបញ្ហាដែលកើតឡើងនៅក្នុងរបបកុម្មុយនីស្ត ។

**ស៖** ព្រឹកមិញនេះ គឺមានការពិភាក្សាអំពីប្រភពផ្សេងៗ លោកបាននិយាយអំពីប្រភព ដែលថានៅប្រទេសបារាំងនិងសូវៀត ។ ខ្ញុំចង់ឲ្យលោកពន្យល់បន្ថែមអំពីបញ្ហាដែលថា ប្រភពកុម្មុយនីស្តពី

ប្រទេសចិន ពីព្រោះថាយើងមិនទាន់មានការពិភាក្សាលម្អិតនៅឡើយទេពីបញ្ហានេះ ។ ចំពោះខ្ញុំៗយល់ឃើញថាផ្អែកតាមសំដីរបស់ជនជាប់ចោទ ហើយនិងប្រវត្តិសាស្ត្រ ដែលថា ចិន គឺជាអ្នកនាំមុខក្នុងលទ្ធិកុម្មុយនីស្ត ហើយអាចនឹងគាត់ជឿនៅក្នុងលទ្ធិនោះ អាចជួយឲ្យគាត់ស្តារឡើងវិញនូវកិត្តិយស កេរ្តិ៍ឈ្មោះជនជាតិភាគតិចចិននៅកម្ពុជា ។ ថាតើលោកដឹងទេថា តើសៀវភៅទាំងនោះជនជាប់ចោទបានអានចំគំនិតដូចដែលខ្ញុំលើកដែរឬទេ?

**ឆ៖** វាជាការពិត ដែលថាយើងបានពិភាក្សាអំពីតួនាទីរបស់ចិនក្នុងការបណ្តុះបណ្តាលមនោគមវិជ្ជារបស់ជនជាប់ចោទ ប៉ុន្តែខ្ញុំជឿថា អ្វីដែលជនជាប់ចោទទទួលបាននោះជាពិសេស គឺការស្តារឡើងវិញ។ ជាពិសេសមោទនភាពរបស់ចិនអំពីប្រទេសមួយដែលជាប្រទេសដកខ្លួនចេញ បានន័យថាឯករាជ្យដាច់ចេញពីពួកអឺរ៉ុបនោះ ។ ដោយជោគជ័យរបស់កុម្មុយនីស្តចិន ម៉ៅ សេទុង នោះហើយ គេបានទទួលនូវមោទនភាពជាតិរបស់គេ ។ គេបាននិយាយអំពីស្នាដៃមួយចំនួន គឺស្នាដៃរបស់ ម៉ៅ សេទុង ដោយខ្លួនឯងនោះ ហើយនិងអ្នកផ្សេងទៀតរបស់ចិន ។ ប៉ុន្តែខ្ញុំមិនដឹង ឬក៏ទទួលអារម្មណ៍ច្បាស់ថាអាចកត្តាដែលជំរុញដល់អាកប្បកិរិយារបស់គាត់នោះទេ ប៉ុន្តែខ្ញុំមិនបានដឹងច្បាស់ថាគាត់បានអានស្នាដៃ ឬក៏អត្ថបទស្នាដៃរបស់ចិនច្រើនមួយចំនួន ដែលថានាំឲ្យគំនិតដែលនិយាយអំពីលទ្ធិកុម្មុយនីស្តក្នុង ដែលក្នុងបរិបទទូលំទូលាយនោះទេ ដែលថាវាគាំទ្រដល់តួនាទីសំខាន់របស់គាត់ ដែលក្នុងការអនុវត្តតួនាទីផ្ទាល់ខ្លួននៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះទេ ។

**ស៖** ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលរៀបរាប់អំពីមហាបដិវត្តន៍វប្បធម៌ចិននោះ តើគាត់បាននិយាយជាមួយលោកទេ? ពីព្រោះនេះជាចំណុចសំខាន់មួយ ។ នេះជាពេលសមស្របក្នុងពេលថ្មីៗនេះ ហើយខ្ញុំគិតឃើញថា ចំណុចនេះក៏គប្បីមានការពិភាក្សា ហើយលើកឡើង ។ តើលោកបានពិភាក្សារឿងនោះដែរឬទេ?

[១៣:១៤:០២]

**ឆ៖** សូមអភ័យទោស គឺថាមានទម្លាប់មួយចំនួនដែលខ្ញុំត្រូវទទួលស្គាល់ គឺថាបដិវត្តន៍វប្បធម៌ចិននោះ គឺថាវាមានសាយភាយដល់កម្ពុជា ដែលថាយើងមានខ្មែរកាត់ចិន ហើយនិងសមាគមចិនមួយចំនួនច្រើន ដែលរាប់បញ្ចូលទាំង ហ៊ូ នឹម ដែលជាអ្នកកាន់អំណាចខ្ពស់នៅរបប ប៉ុល ពត ហើយក៏ត្រូវសម្លាប់នៅស-២១ ។ ហើយគាត់បានមានទោសពីការចែកចាយសៀវភៅម៉ៅក្នុងរបបសីហនុនិយម ។ ប៉ុន្តែនិយាយអំពីបដិវត្តន៍វប្បធម៌ចិននោះ គឺថាវាមានអ៊ីចឹង ប៉ុន្តែមានអង្គហេតុ ដែលគាំទ្ររឿងហ្នឹង ដែល

ជាកត្តាជំរុញឱ្យចូលជាសមាជិកនៃអង្គការកុម្មុយនីស្តចិននោះ អង្គការកុម្មុយនីស្តនោះ ។

នោះគឺថាការតស៊ូរបស់បដិវត្តន៍កុម្មុយនីស្តកម្ពុជានោះ ខ្ញុំមិនគិតថាវាជាកត្តាកំណត់តែមួយគត់ ដែលជំរុញឲ្យមានបក្សកុម្មុយនីស្តកម្ពុជាមកពីចិននោះ ។ ប៉ុន្តែមានទិដ្ឋភាពមួយចំនួនដែលថាសម្ងហភាព ខាងកសិករ ខាងមូលដ្ឋាន ប៉ុន្តែប្រទេសចិន គេមិនដែលចូលជ្រៅក្នុងចលនានោះឲ្យជ្រៅក្នុងគំនិតសម្ងហភាពទៅក្នុងកសិករ កសិកម្ម ខ្លាំងដូចកម្ពុជាប្រជាធិតេយ្យនោះទេ ។ ប៉ុន្តែ គេចង់បញ្ជាក់ថាគេចង់ឈានដល់មហាអស្ចារ្យ មហាលោតផ្លោះ ដែល ម៉ៅ មិនទាន់ទាំងធ្វើបានផងនោះ ។

**ស៖** ព្រឹកមិញនេះទាក់ទងទៅនឹងឥទ្ធិពលនៃសហភាពសូវៀត ដែលលោកបាននិយាយអំពីការជំនុំជម្រះ ។ នៅក្នុងគំនិតរបស់ខ្ញុំ គឺថាចរិតលក្ខណៈមួយរបស់កម្ពុជានោះ គឺមិនមានការសាកល្បង ហើយមិនមានការជំនុំជម្រះនៅក្នុងទោសរបស់គេ ប៉ុន្តែវាមានការរក្សាការសម្ងាត់នៅក្នុងនោះ ដែលថាដំណើរការអ្វីៗត្រូវធ្វើឡើងដោយសម្ងាត់បំផុតនៅក្នុងរបបនោះ ។ ហើយទំនាក់ទំនងរវាងប្រភពសូវៀត ហើយនិងកម្ពុជាប្រជាធិតេយ្យនោះអាចថា ជាចម្លើយសារភាព ។ ដែលជាចម្លើយនោះ នៅក្នុងភាសាបារាំងយើងនឹងហៅពាក្យថា *"កុងហ្វេស្យុង"* និង *"អាវ៉ឺ"* ដែលថានៅក្នុងនេះ នៅតុលាការនេះ គឺជាចម្លើយសារភាព ជាសេចក្តីសារភាព ។

នៅក្នុងការពិភាក្សាជាមួយជនជាប់ចោទ តើលោកបានពិភាក្សាជាមួយគាត់អំពីសារសំខាន់អំពីចម្លើយសារភាពទាំងនោះទេ?

[១៣:៤៤:០២]

**ឆ៖** ខ្ញុំឯកភាពជាមួយលោកចៅក្រម មិនមានការជំនុំជម្រះទេនៅកម្ពុជា ខ្ញុំបានសង្កត់ធ្ងន់អំពីៗការសិក្សានយោបាយរបស់យុវជនក្មេងៗនៅប៉ារីស ហើយនិងដំណើរការនីតិវិធី ដែលប្រើនៅក្នុងការជំនុំជម្រះនេះ ។ ហើយនិយាយអំពីបុគ្គលិកលក្ខណៈ ដែលបានកំណត់ ហើយដែលបានរៀបរាប់ឡើងដោយអ្នកសួរចម្លើយ ហើយដូចដែលខ្ញុំបានយល់ច្បាស់ដែរដូចជា នៅក្នុងសម័យ លន់ នល់ ដែលនិយាយអំពីសៀវភៅសារភាពនោះ គឺថានៅក្នុងខ្សែភាពយន្តនោះ គឺវាមានលក្ខណៈបែបនោះ ។ ប៉ុន្តែ ចំណុចសំខាន់ខ្ញុំគិតថា ស្វែងរក ឬក៏ទាញឲ្យបានសេចក្តីសារភាពនេះនៅក្នុងកម្ពុជា គឺអ្នកស្រាវជ្រាវដំបូង ដែលនៅក្នុងរបបអង់គ្លូសាក់សុងដែលគេហៅថា "ចម្លើយសារភាព" ។ ប៉ុន្តែមានពាក្យមួយទៀតថា "សន្តិភាព" ជាភាសាខ្មែរ ។ គឺថាការអានរបស់ខ្ញុំមិនត្រឹមត្រូវ តែប៉ុន្តែវាមានន័យខ្លឹមសារនោះ គឺគេយោងទៅរកចំណុចមួយ គឺជាវិធីសាស្ត្រ ជាតិចនិចដែលថា-- ដែលគេយកទៅប្រើនៅក្នុងមន្ទីរសន្តិសុខ១៩៦ កន្លែង

នៅកម្ពុជានោះ គឺគេប្រើវិធីហ្នឹង ដើម្បីទាញយកចម្លើយសារភាព ដែលមិនទាន់បានឃើញថា មានទោសអីទេ ។ គេអាចប្រើវិធីនោះ ដើម្បីបញ្ជាក់ថា អំពើរបស់គេនោះត្រឹមត្រូវ ហើយគេអាចប្រើចម្លើយសារភាពមួយចំនួនដើម្បីទៅចាប់មនុស្សផ្សេងទៀតដែលគេឆ្លើយដាក់ក្នុងចម្លើយសារភាពនោះ ។

ហើយតាមពិត ជនជាប់ចោទខ្លួនឯងបានទទួលស្គាល់ថា ការងាររបស់គាត់ជាមូលដ្ឋាននោះ គឺការអានចម្លើយសារភាពឡើងវិញ ឡើងសាចុះសាឡើង គឺមិនបានធ្វើសួរចម្លើយដោយខ្លួនឯងនោះទេនៅពេលដែលយើងមើលទំហំនៃឯកសារច្រើននោះ យើងនឹងពិនិត្យឃើញ-- យើងដឹងថាភាគច្រើន ដែលត្រូវការជាចាំបាច់នោះ ។ អ៊ីចឹងតួនាទីមួយផ្នែករបស់គាត់ គឺផ្ទុះបញ្ចាំងក្នុងការពិភាក្សារបស់យើង ។ ហើយតាមពិតខ្ញុំបានព្យាយាមរកឲ្យឃើញថែមទៀត ហើយខ្ញុំចង់ដឹងតើអ្នកណាជាអ្នកបង្រៀនគាត់អំពីតិចនិច អំពីវិធីសាស្ត្រដែលគាត់អាចបង្រៀនបន្តទៅអ្នកសួរចម្លើយរបស់គាត់ទៀតបាន ។

ពីព្រោះនេះ គឺជាប្រភពមួយនៃអំពើភ័យរន្ធត់ តក់ស្លុតមួយដែលថា យើងឃើញថាប្រភពមួយថា សុន សេន បានតួនាទីដ៏សំខាន់ក្នុងតួនាទីនេះដែរ ហើយ វន វើត ក៏ជាគ្រូរបស់ជនជាប់ចោទដែរ ។ ប៉ុន្តែពួកគាត់ទាំងនោះដើរតួនាទីដាច់ដោយឡែកពីចម្ងាយមួយ ឬក៏ទាក់ទងទៅនឹងការងារ ។ ហើយខ្ញុំអាចនិយាយអំពីអ្វីដែល សុន សេន គាត់បានរៀនសូត្រនៅប៉ារីស ហើយក្រោយមកគាត់ក្លាយទៅជាមេរបស់ជនជាប់ចោទ ។

**ស៖** ក្នុងពេលដែលលោកពិភាក្សា តើលោកដឹងឬទេថា ជនជាប់ចោទបានដឹងថា ចម្លើយសារភាពទាំងនោះត្រូវបានគេយកទៅប្រើ ដើម្បីបញ្ជាក់ពីការចោទប្រកាន់-- ដើម្បីកំណត់ពីនិយមន័យនៃខ្មាំងដែលកំណត់ឡើងដោយមជ្ឈិមបក្សរបស់គេនោះ? ហើយក្រៅពីនោះទៀត តើលោកដឹងដែរឬទេ ឬជនជាប់ចោទបានប្រាប់លោកដែរឬទេ ថាគាត់បានចូលទៅក្នុងការកំណត់និយមន័យនៃខ្មាំងរបស់បក្សនាកាលនោះ?

[១៣:៥៨:២២]

**ឆ៖** ដោយសង្ខេប គឺជនជាប់ចោទបានបង្អួលបង្ហាញថា គាត់មិនបានជឿសេចក្តីសារភាពទាំងនោះទេ ហើយវិធីសាស្ត្រទារុណកម្មទាំងអស់នោះ ដែលប្រើមិនអាចទទួលបានការពិតទេ នោះហើយជាការពិត ។

នៅក្នុងឱកាសមួយចំនួនគាត់បានបញ្ជាក់ថា គាត់ត្រូវធ្វើតាមបញ្ជារបស់គេ តើគាត់បានចូលរួមទៅក្នុងការកំណត់និយមន័យសម្រាប់មជ្ឈិមបក្សដែរឬទេ? ប៉ុន្តែ ជាទូទៅគាត់តែងតែគោរពតាមបញ្ជាពី

គណៈមជ្ឈិមរបស់កប្បនោះ ។ គាត់បានបញ្ជាក់យ៉ាងមុតមាំថា ហើយគាត់យោងទៅរកការសន្ទនាជាមួយ សុន សេន ថានេះ គឺជាការបញ្ជាពី សុន សេន ដោយការណែនាំហើយ នេះហើយគាត់ត្រូវតែធ្វើឱ្យដូចតាមអ្វីដែលគេបញ្ជា ។ ក្របខ័ណ្ឌនៃការពន្យល់ពីអំពើរបស់គាត់ គឺផ្អែកទៅលើហេតុការណ៍ ដែលថាតួនាទីរបស់គាត់ គឺអនុវត្តការណែនាំ ដើម្បីឱ្យបានសម្រេចតាមការណែនាំ ។ ចំពោះនិយាយការសម្រេចជោគវាសនាចុងក្រោយរបស់ជនរងគ្រោះវិញនោះ នៅក្នុងការសន្ទនាដែលខ្ញុំបាននិយាយជាមួយគាត់ គាត់បានយោងទៅរករាល់ពេលទាំងអស់ គឺគាត់ទទួលការបញ្ជា ហើយនិងអនុវត្តការបញ្ជា ។

**ស៖** ព្រឹកមិញនេះលោកក៏បាននិយាយអំពីអំពើភ័យរន្ធត់ ។ ខ្ញុំក៏ចង់ដឹង តើលោកបាននិយាយអំពីទំនាក់ទំនងដែលជនជាប់ចោទមានជាមួយស-២១ ជាមួយបុគ្គលិកស-២១ នៅក្រោមបង្គាប់ទេ?

**ឆ៖** មិនបានជជែកពីចំណុចនេះទេ ។

**ស៖** នៅក្នុងដំណើរការនីតិវិធី តុលាការបានស្តាប់សវនាការមនុស្សមួយចំនួន ដែលបានរាយប្រាប់តុលាការ ហើយវាជាទម្លាប់អនុវត្តទូលំទូលាយជាទូទៅ ហើយគេពិនិត្យឃើញថា ឌុច ខ្លួនឯងជាអ្នកនិយាយ គាត់បានរាយការណ៍ទៅថ្នាក់លើរបស់គាត់ ។ អំពើរបស់អ្នកក្រោមបង្គាប់ កាលណាអំពើអ្នកក្រោមបង្គាប់នោះផ្ទុយទៅនឹងអ្វីដែលគោលការណ៍ណែនាំ ជាគំរូជាវិន័យរបស់កម្មាភិបាលបក្សនោះ។ តើលោកបានពិភាក្សាពីចំណុចហ្នឹងទេ គេចាត់វិធានការដូចម្តេច?

**ឆ៖** ខ្ញុំនិយាយឡើងវិញ គឺថាយើងមិនបានពិភាក្សាភាពខុសគ្នារវាង ឌុច ហើយនិងបុគ្គលិក ស-២១ នោះទេ ។ ប៉ុន្តែ ធម្មតានៅក្នុងប្រព័ន្ធបែបនេះ កាលណាប្រព័ន្ធនៃការរាយការណ៍នេះជាវិធាន គឺវាជាផ្នែកនៃប្រព័ន្ធហ្នឹងហើយ ។ ខ្ញុំបានសិក្សាអំពីជំរំឃុំឃាំងនៅតំបន់មួយចំនួនដែលថាគេអនុវត្ត គឺថាគេតម្រូវឱ្យរាយការណ៍ទៅមន្ទីរ៨៧០ ហើយគេតម្រូវឱ្យធ្វើការរាយការណ៍អំពីអំពើ ឬក៏សកម្មភាព ឬក៏កាយវិការរបស់ជនណាម្នាក់ បុគ្គលិកណាម្នាក់ ហើយអំពីអ្នកទោសផងដែរ ។ នេះជាប្រព័ន្ធទូទៅដែលថាម្នាក់ៗត្រូវតែតាមដានម្នាក់ទៀត ហើយបើយើងមិនអាចធ្វើដូច្នោះទេ គឺអាចនឹងទទួលការគំរាមកំហែង ឬក៏មានទោស ។ នេះ គឺជាទម្លាប់ដែលថាជាកាតព្វកិច្ចបុគ្គល ដែលប្រព័ន្ធវាបង្គាប់ឱ្យជនម្នាក់ៗធ្វើ ។

**ស៖** ព្រឹកមិញនេះ លោកក៏បានពិភាក្សាអំពីពូជសាសន៍និយម នៅក្នុងបរិបទនៃការអនុវត្តនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហៅថា ប.ប.ប.ក.ក បក្សកុម្មុយនីស្តកម្ពុជា ។ តើលោកបាននិយាយបញ្ហានេះជាមួយជនជាប់ចោទដែរឬទេ? តើជនជាប់ចោទប្រាប់លោកដែរឬទេ ថាគាត់បានដឹងអំពីបញ្ហានេះ? តើគាត់ប្រាប់លោកដែរទេថា អ្នកជាប់ឃុំស-២១ ណាម្នាក់ ដែលត្រូវបានគេឃុំខ្លួនដោយពូជសាសន៍

រើសអើងពូជសាសន៍នោះ?

[១៣:៥៣:២៩]

**ឆ៖** មិនមានទេ មិនបានពិភាក្សាទេ យើងនិយាយអំពីតែវត្តមានអ្នកទោសវៀតណាមដែលផ្សារភ្ជាប់ទៅនឹងស្ថានភាពមួយចំនួន ដែលថាទំនាក់ទំនងរវាងប្រទេសទាំងពីរ ។ ប៉ុន្តែ យើងមិនបាននិយាយអំពីពូជសាសន៍និយមនោះទេ ។ ប្រសិនបើខ្ញុំអាចនិយាយឲ្យមានសេរីភាពជាងនេះ ពីព្រោះខ្ញុំបានទំនាក់ទំនងជាមួយកម្ពុជា និងជាងម្ភៃឆ្នាំមកហើយ មិនមានអ្នកណាម្នាក់បដិសេធទេថា កាលណាយើងនិយាយថា វៀតណាមនៅកម្ពុជានោះ គឺយើងឮតបមកវិញ គឺវាមានលក្ខណៈថា វាមិនដូចជាមានមិត្តភាពប៉ុន្មានទេ ពីរឿងពូជសាសន៍នៅកាលនោះ ។ ប៉ុន្តែ ដែលខ្ញុំឮពីជនជាប់ចោទ ឬក៏ឮពីជនកម្ពុជាផ្សេងទៀតមិនខុសគ្នាទេ ។ នេះហើយជាបទពិសោធន៍ចំណុចមួយដែលយើងមាននៅអឺរ៉ុប នៅពេលដែលបារាំងយល់ម៉េចចំពោះអាល្លឺម៉ង់? ហើយអាល្លឺម៉ង់យល់ម៉េចចំពោះបារាំង? គឺវាមានភាពខុសគ្នានៃអារម្មណ៍ដែលអាចជំរុញឲ្យមានភាពមហន្តរាយនៅក្នុងឱកាសមួយចំនួនបាន ។

**ស៖** ឥឡូវនេះ ខ្ញុំចង់ចូលទៅដល់បញ្ហាមួយទៀត ។ អ្វីដែលហៅថា បញ្ហាជំរុញអំពីតួនាទីរបស់ ស-២១ បើប្រៀបធៀបទៅនឹងមន្ទីរឃុំខ្លួនផ្សេងៗទៀតនៅក្នុងរបបនោះ។ យើងដឹងថា មានមន្ទីរសន្តិសុខជាច្រើននៅក្នុងកម្ពុជា អ្វីដែលខ្ញុំចង់ឲ្យលោកប្រាប់តុលាការនៅថ្ងៃនេះ គឺថាតើតាមទស្សនៈរបស់លោក ស-២១ហ្នឹង គឺជាមន្ទីរសន្តិសុខ ដែលវាមានលក្ខណៈពិសេសដែលខុសដោយឡែកពីកន្លែងផ្សេងៗទៀត? ឬក៏ថាតើខ្ញុំអាននៅក្នុងអត្ថបទរបស់លោកនេះ ។ គឺជាមន្ទីរសន្តិសុខមួយ ដែលថាដូចនៅក្នុងប្រព័ន្ធទូទៅនៃការធ្វើផែនការនៃការបំបាត់។ តើវាមានលក្ខណៈពិសេសសម្រាប់ស-២១ ទេ? តើវាមានលក្ខណៈអ្វី? តើលោកប្រាប់យើងបានទេ នៅក្នុងកំណត់ហេតុរបស់លោក លោកបានយោងទៅរកឯកសារ មិនបានភ្ជាប់ជាមួយឯកសារនេះទេ ហើយមិនមាននៅក្នុងសំណុំរឿងក្តីនេះទេ ដែលថាស-២១ គឺមិនមែនជាទីកន្លែងធំជាងបំផុត ដែលគេប្រើសម្រាប់សម្លាប់មនុស្សតែមួយប៉ុណ្ណោះទេ?

**ឆ៖** ខ្ញុំគិតថា វាមានគោលបំណងនិងលក្ខណៈអត្តនោម័តិ និងសត្យានុម័តចំពោះមន្ទីរស-២១។ ធាតុផ្សំសត្យានុម័តនោះ ដោយសារតែភ្នំពេញគឺជាទីក្រុង ដោយសារតែក្រោយពីឆ្នាំ៧៩ វាក្រោយទៅជាសារមន្ទីរប្រល័យពូជសាសន៍ ដោយសារកន្លែងនោះជាកន្លែងដែលអ្នកកាសែតគេបានទៅទស្សនា។

ដូច្នេះ ហើយធ្វើឲ្យមានការងាកចេញពីការចាប់អារម្មណ៍ទៅលើចំណុច និងមន្ទីរនេះ ។

[១៣:៥៧:២០]

នៅពេលដំបូង គឺមិនមានអ្វីច្រើនអំពីស-២១ នោះទេ គឺកេរ្តិ៍ឈ្មោះរបស់មន្ទីរនេះ គឺកើតចេញក្រោយពីការស្រាវជ្រាវរបស់មន្ទីរស-២១ ដែលបានគូសបញ្ជាក់ទៅលើចំណុចហ្នឹង ។

ដូច្នេះ វាមានលក្ខណៈពិសេសអំពីអត្តនោម័តិ ខុសពីមន្ទីរដទៃៗទៀត ។ មន្ទីរស-២១ គឺមានអ្នកទោសមកពីកន្លែងទាំងអស់នៅក្នុងប្រទេស ។ អ្នកទាំងអស់នោះហើយ នៅពេលដែលពួកគេមកដល់មន្ទីរស-២១-- អ៊ីចឹង គឺមានការលើកឡើងពីគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមអំពីលក្ខណៈពិសេសរបស់មន្ទីរនេះ ។ ខ្ញុំបានលើកឡើងពីមុនហើយស-២១ នេះហើយ វាមានលក្ខណៈសមាមាត្រ និងមានលក្ខណៈផ្សេងៗរបស់វា ហើយយើងឃើញនៅក្នុងមន្ទីរនេះ យើងឃើញមានកម្មាភិបាលគ្រប់ជាន់ថ្នាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្នកទាំងអស់នោះត្រូវបានគេចាប់មកពីតាមភូមិភាគនានា ដែលគេប្រើពាក្យនេះនៅសម័យនោះ ។

ដូច្នេះហើយវាមានលក្ខណៈពិបាកណាស់ក្នុងការពិភាក្សា ដែលវាពាក់ព័ន្ធទៅនឹងការឈឺ និងការស្លាប់យ៉ាងធំធេង ។ ដូច្នេះហើយវាហាក់ដូចជាការបែងចែកចំណាត់ថ្នាក់ទៅលើការភ័យខ្លាច ។ ដូច្នេះហើយខ្ញុំក៏គិតថា វាត្រឹមត្រូវដែរទៅលើចំណុចនេះ ។ យើងឃើញមានមន្ទីរសន្តិសុខផ្សេងៗដទៃទៀតនៅកម្ពុជាប្រជាធិបតេយ្យ ហើយវាហាក់ដូចជាយើងអាចរាប់ទៅលើគ្រោងឆ្អឹងដែលមាននៅក្នុងប្រទេសអ៊ីចឹង ។ យើងឃើញមានមន្ទីរជនរងគ្រោះជាច្រើននៅក្នុងមន្ទីរទាំងអស់នោះ ។

ខ្ញុំសូមជម្រាបដោយស្មោះត្រង់ប្រសិនបើអនុញ្ញាត ។ មិនមែនជនជាប់ចោទដែលត្រូវបានគេចោទប្រកាន់ថាជា ប្រធានមន្ទីរសន្តិសុខតែប៉ុណ្ណោះទេ អ្វីដែលយើងត្រូវធ្វើនោះ យើងត្រូវតែរកប្រធានមន្ទីរសន្តិសុខដទៃៗ ដែលគាត់នៅរស់នៅសព្វថ្ងៃ ។ យើងដឹងហើយអ្នកទាំងអស់នោះ គឺនៅរស់រានមានជីវិតហើយកំពុងតែរស់នៅដោយមានសន្តិភាពនិងសុខស្រួល ហើយនៅមន្ទីរសន្តិសុខមួយចំនួននោះ គឺមានជនរងគ្រោះអាចច្រើនជាងជនរងគ្រោះ ដែលជាប់នៅមន្ទីរស-២១ ទៅទៀត ។

**ស៖** នៅក្នុងចំណោមលក្ខណៈពិសេសរបស់មន្ទីរស-២១ ប្រហែលវាទាក់ទងទៅនឹងករណីដែលថាមន្ទីរស-២១ វាមានសាខាច្រើន គឺមានសាខាទួលស្លែង ហើយក៏មានសាខា ដែលយើងហៅថាស-២៤ផងដែរ ។ ហើយប្រសិនបើលោកឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ ថាតើមន្ទីរសន្តិសុខដទៃៗទៀត គឺបង្កើតឡើង ហើយមានសាខាច្រើនដូចអ៊ីចឹងដែរឬទេ? ហើយវាបានរៀបចំដូចមន្ទីរសន្តិសុខស-២១ ដែរឬទេ? ហើយថាតើវាមានស្ថិតិជាក់លាក់ទៅលើចំនួនប្រជាជនដែលស្លាប់ជាក់លាក់ដែរទេ? ហើយថាតើយើងដឹងបុគ្គលិកប៉ុន្មានដែរដែលគេបានប្រើប្រាស់? ហើយយកមកធ្វើជាបុគ្គលិកនៅស-២១ នោះ? តើ

លោកបានដឹងទៅលើករណីនេះដែរឬទេ?

[១៤:០១:២៨]

**ឆ៖** សមាសធាតុ ឬក៏ធាតុផ្សំ ដែលយើងនិយាយអំពីនេះ គឺយើងឃើញមានផ្នែក ឬក៏សាខាដូច ស-២៤ និងស-២១ ដែលខ្ញុំហៅថា នេះគឺជាការកំណត់លក្ខណៈអត្តនោម័តិ វាបង្ហាញយ៉ាងច្បាស់ ហើយបុគ្គលិកនោះក៏វាមានលក្ខណៈផ្សេងៗទៅតាមការយល់ដឹងរបស់យើងចំពោះចំនួនតួលេខនោះ ។ នៅពេលដែលយើងមានតួលេខស្ថិតិ ដែលវាត្រឹមត្រូវដូចដែលបានបញ្ជាក់នៅស-២១ នោះ យើងឃើញ ថាប្រធានមន្ទីរស-២១ មានលក្ខណៈហ្មត់ចត់ និងយកចិត្តទុកដាក់ ហើយធ្វើការគិតគូរទៅលើទៅចំណុច ហ្នឹង ហើយចំពោះមន្ទីរសន្តិសុខផ្សេងៗ គេមិនមានស្រាវជ្រាវជាក់លាក់ទៅលើវិសាលភាពនិងចំនួន ទាំងអស់នោះទេ ។ ដូច្នេះហើយយើងអាចគិតថា វាមានចំនួនច្រើនជនរងគ្រោះច្រើនជាងមន្ទីរស-២១ ។ ហើយយើងមើលឃើញយ៉ាងច្បាស់ថា នៅមន្ទីរសន្តិសុខផ្សេងៗ មានបុគ្គលិកតិចជាង មន្ទីរស-២១ ដោយសារតែនៅមន្ទីរផ្សេងៗ គេផ្តោតលើចម្លើយសារភាពតិចជាងមន្ទីរស-២១ ។ ប៉ុន្តែ យោងទៅតាម ចម្លើយរបស់ជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា “កុំព្រួយបារម្ភវៀតណាមលែងចូលភ្នំពេញ ទៀតហើយ” ។ ដូច្នេះហើយទើបកំណត់ហេតុនៅស-២១ មិនបានបំផ្លាញ ហើយវាមិនអាចធ្វើឲ្យបំផ្លាញ បណ្ណសារ ឬក៏ឯកសារទាំងអស់នោះ ។ ហើយប្រសិនបើមានការរក្សាទុកឯកសារទាំងអស់នោះ គឺមាន កន្លែងតិចតួចប៉ុណ្ណោះ ដែលរក្សារទុកឯកសារទាំងអស់នោះ ។

ដូច្នេះហើយយើងត្រូវតែមានការស្រាវជ្រាវទៅលើបាតុភាព ឬក៏បាតុភូតនៃការគ្រប់គ្រង និងការ រក្សានូវឯកសារទាំងអស់នោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើនលោកអ្នកជំនាញ ខ្ញុំពុំមានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដល់អ្នក ជំនាញរូបនេះ ហើយអង្គជំនុំជម្រះសូមជម្រាបថា តំណាងសហព្រះរាជអាជ្ញាមានពេលវេលាដប់ប្រាំនាទី ក្នុងការសួរនេះ ។ សូមអញ្ជើញ ។

[១៤:០៤:១៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍ ចេនណា ។

**ស៖** សំណួរទីមួយរបស់ខ្ញុំជូនចំពោះលោកដូចពីព្រឹកមិញ លោកបាន ហើយនិងអម្បាញ់មិញ លោកបានជម្រាបជូនលោកចៅក្រម នៃអង្គជំនុំជម្រះរួចមកហើយនូវវិធីសាស្ត្រខ្លះៗ ដែលបក្សកុម្មុយនីស្តកម្ពុជាហ្នឹង បានប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមការស្រាវជ្រាវរបស់លោក តើលោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះឡើងវិញបានទេថា វិធីសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យដែលមានបក្សកុម្មុយនីស្តកម្ពុជាបានដឹកនាំប្រទេសនោះ វាបានចម្លងយកមកពីបណ្តាប្រទេសសង្គមនិយមនានាដែលមានជាពិសេសពីអតីតសហភាពសូវៀត ក្នុងរបបលេនីន ស្តាលីន ប្រទេសចិន បដិវត្តន៍វប្បធម៌របស់ប្រទេសចិនក្តី និងប្រទេសវៀតណាមហ្នឹង ។

**ឆ៖** ការយល់របស់ខ្ញុំបើសិនជាខ្ញុំយល់នូវសំណួរនោះ នៅពេលដែលលោកនិយាយថាយុទ្ធសាស្ត្រ ថាតើបានន័យថាយ៉ាងម៉េច គឺអំពីគម្រោងដែលត្រូវបានគេអនុវត្តនៅពេលដែលលោកនិយាយពាក្យយុទ្ធសាស្ត្រ ថាតើលោក--

**ស៖** ខ្ញុំសូមទោសលោក ស្តាប់លោកអត់បាន សូមលោកបញ្ជាក់ឡើងវិញម្តងទៀតបានទេ?

**ឆ៖** នៅក្នុងការបកប្រែភាសាបារាំងនូវសំណួររបស់លោក លោកបានប្រើពាក្យ *ស្ត្រាថាជី* គឺបានប្រើពាក្យ *ស្ត្រាថាជី* គឺយុទ្ធសាស្ត្រថាតើអ្វីដែលលោកនិយាយនេះ គឺថាជាគម្រោងផ្នែកនយោបាយដែលគេអនុវត្ត ឬក៏យ៉ាងម៉េច?

**ស៖** បាទ, អរគុណលោក ដោយសារប្រដាប់ស្តាប់របស់ខ្ញុំអំមិញវាលោតទៅចូលលេខផ្សេង ។ ខ្ញុំនិយាយនេះ ដោយយោងទៅលើរបាយការណ៍របស់លោកដែរ ក្នុងរបាយការណ៍របស់លោកនៅក្នុងចំណុចទី៥ នោះគឺលោកមាននិយាយអំពីវិធីសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបក្សកុម្មុយនីស្តកម្ពុជានោះ បានសម្តោធឲ្យប្រើប្រាស់នៅក្នុងរបប-- ហើយដែលក្នុងរបបសង្គមនិយមដែលមានសហភាពសូវៀត ដែលមានលេនីន ស្តាលីន ជាដើមនុ៎ង ។ អ៊ីចឹងបានខ្ញុំ សំណួររបស់ខ្ញុំសួរថាតើ វិធីសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជានុ៎ង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ បានចម្លងយកមកពីបណ្តាប្រទេសសង្គមនិយមទាំងនោះដែរឬទេ?

**ឆ៖** ដូចដែលខ្ញុំបានលើកឡើងនៅក្នុងសេចក្តីផ្តើមសគ្គីកម្មរបស់ខ្ញុំ ចំណុចនេះក៏បានបញ្ជាក់នៅក្នុងសំណោរស្នាដៃនិពន្ធមួយចំនួនផងដែរ ។ កម្ពុជាប្រជាធិបតេយ្យ គឺចង់ឲ្យមានគោលគំនិតកុម្មុយនីស្ត

នៅក្នុងការដឹកនាំមួយតែមួយ មិនឲ្យមានការផ្លាស់ប្តូរ ហើយយើងឃើញមាននៅក្នុងឯកសារនៅក្នុងការប្តេជ្ញាដែលគេចង់ឲ្យធ្វើល្អជាងសហភាពសូវៀត លេនីន ឬក៏ស្តាលីន ។ ហើយអ្នកដែលយកតាមគំនិតលទ្ធិរបស់ពួកគេនោះ គឺវាហាក់ដូចជាជនក្បត់ ។ ដូច្នេះហើយ យើងឃើញថាកម្ពុជាប្រជាធិបតេយ្យ គឺគេប្តេជ្ញាធ្វើល្អជាងចិន ដូច្នេះហើយការប្តេជ្ញារបស់កម្ពុជាប្រជាធិបតេយ្យ គេចង់ធ្វើយ៉ាងណាឲ្យល្អជាងសង្គមកុម្មុយនីស្តដទៃៗទៀត មិនថាពួកគេមាននិន្នាការនយោបាយយ៉ាងម៉េចនោះទេ ។

[១៤:០៨:៤៤]

ដូច្នេះហើយវាហាក់ដូចជាពួកគេយកគំរូតាមមូស្គូ ឬក៏ខាងប្រទេសចិនជាដើម ។ ដូច្នេះហើយ ដូចដែលខ្ញុំបានបញ្ជាក់ ខ្ញុំបញ្ជាក់ទៅលើចំណុចនេះច្រើនហើយ គឺគេមិនគិតអំពីការចំណាយទៅលើធនធានមនុស្សទាំងអស់នោះទេ ។ ហើយមិនមានឃើញចំណុចអន្តរកាលដែលគេគិតពិចារណាទៅលើគម្រោង និងវិធីសាស្ត្ររបស់ពួកគេ ទាក់ទងទៅនឹងយន្តការសន្តិសុខ និងនយោបាយខ្ញុំបានព្យាយាមបានលើកឡើងហើយ អំពីវិធីសាស្ត្រនោះវាហាក់ដូចជាមានលក្ខណៈសូវៀតច្រើន ដែលគេមានគំនិតនៅចង់អនុវត្តទៅលើក្រឹត្យក្រមសមូហភាពកសិកម្ម ។ ដូច្នេះហើយបើសិនយើងមើលទៅលើន័យទៅវាស្រដៀងនឹងចិនដែរ ប៉ុន្តែយ៉ាងណាក៏ដោយនៅពេលដែលគេដើរហួសទៅលើលទ្ធិទាំងអស់នោះ ហើយយើងដឹងហើយនៅប្រទេសចិន គឺគេមិនអនុវត្តសមូហភាពខ្លាំងដូចនៅកម្ពុជានោះទេ ។ ដូច្នេះហើយទើបខ្ញុំហៅវាថាវាមានលក្ខណៈពិសេស ហៅថាប៉ុលពតនិយម វាមានការដើរលឿនជាងប្រទេសដទៃ ហើយមានការកែប្រែទៅលើលទ្ធិកុម្មុយនីស្តរបស់គេផ្សេង ដោយមិនបានពិចារណាទៅលើមូលហេតុនិងបច្ច័យដែលអាចកើតឡើង ។

**ស៖** អរគុណលោក ចេនណា ។ សំណួរទីពីររបស់ខ្ញុំជូនលោក តាមការស្រាវជ្រាវរបស់លោក តើលោកអាចបញ្ជាក់ដោយខ្លីៗ ជូនអង្គជំនុំជម្រះឡើងវិញបានទេថាតើលោកអាចគិតថា អំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះមានការសម្លាប់រង្គាល ការធ្វើទារុណកម្ម ប្រព័ន្ធគ្រប់គ្រងនៅមន្ទីរសន្តិសុខនានា ពិសេសក្នុងមន្ទីរស-២១ ហ្នឹង តើវាអាចមានលក្ខណៈដូចគ្នា ឬក៏អាចពិសេសជាងបណ្តាប្រទេសសង្គមនិយម ដូចលោកបានលើកអម្បាញ់មិញមានសហភាពសូវៀតនិងចិននោះបានទេបាទ?

**ឆ៖** ទាក់ទងទៅនឹងប្រតិបត្តិការមន្ទីរសន្តិសុខ ដូចស-២១ នេះ យើងឃើញថាការប្តេជ្ញានូវការទាញចម្លើយសារភាព ដែលគេប្រើ *អាវឺ* (aveux) នៅអឺរ៉ុប និងនៅសហភាពសូវៀតគេប្រើពាក្យថា

*អាវី* ។ ដូច្នេះហើយខ្ញុំមិនឃើញមានចំណុចប្លែកគ្នាទេ ទៅលើករណីនេះ លើកលែងនៅអ្វីដែលខ្ញុំនិយាយទៅកាន់លោកចៅក្រម ឡាវែន៍ ដែលគេមានការជំនុំជម្រះ នៅក្នុងរបបរបស់គេផ្សេង ។ ដូច្នេះហើយនៅក្នុងរបបការជំនុំជម្រះនោះ ទោះបីយ៉ាងណាក៏ដោយក៏មិនមានលក្ខណៈដូចការស្វែងរកយុត្តិធម៌នៅក្នុងលោកប្រជាធិបតេយ្យនោះទេ ។

នេះហើយជាអ្វីដែលវាកើតឡើងនៅប្លុកសូវៀតដែលមានការជំនុំជម្រះ ។ ហើយគោលបំណងរបស់គេនោះគឺ គេទាញយកចម្លើយសារភាព ដើម្បីចង់ដឹងទៅលើបុគ្គលនីមួយៗ និងការដាក់ភាពអមនុស្សធម៌ ។ ហើយវាមាន-- មិនសូវមានលក្ខណៈប្រព័ន្ធនៅក្នុងសង្គមសហភាពសូវៀត ដូចនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ យើងដឹងហើយថា ការប្រហារជីវិតនោះគឺមានកើតឡើងច្រើននៅក្នុងប្រទេសនានា រួមទាំង*ប៊ូតាផេស* ផងដែរ ។ ហើយគឺមានការសម្លាប់ កាប់សម្លាប់ផ្សេងៗ ការកាត់ទោសឲ្យប្រហារជីវិតផ្សេងៗ ដូច្នេះហើយយើងអាចធ្វើការប្រៀបធៀបគ្នាបាន ។ កម្ពុជាប្រជាធិបតេយ្យក៏មានការអនុវត្តទៅលើវិធានរបស់គេ ក្របខ័ណ្ឌរបស់គេមួយ ដូចស្រដៀងទៅនឹងចំណុចហ្នឹងដែរ ។

**ស៖** អរគុណលោក ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ សូមលោកឆ្លើយឲ្យខ្លីបំផុត ពីព្រោះដោយសារពេលវេលារបស់ខ្ញុំមានកំណត់ ។ សំណួរទីបី តើលោកអាចគិតថា ការផ្សះផ្សាជាតិ អាចទទួលបានទេប្រសិនបើពិរុទ្ធភាពហ្នឹង ត្រូវបានទទួលយកពីឧក្រិដ្ឋជន ហើយពុំមានការផ្តន្ទាទោសនូវអំពើឧក្រិដ្ឋនោះឲ្យបានសមល្មមនូវអំពើនោះ? សូមលោកខ្លីៗបានហើយបាទ ខ្លីបំផុត ។

**ឆ៖** លោកឲ្យខ្ញុំឆ្លើយឲ្យខ្លីៗបំផុតទៅនឹងសំណួរដែលមានការពិបាក ហើយមានលក្ខណៈរសើបហើយនិយាយដោយស្មោះទៅ ខ្ញុំមិនអាចថា អាចឆ្លើយខ្លី ឬក៏វែងនោះទេ ។ ប៉ុន្តែ ខ្ញុំនឹងផ្តល់នូវសេចក្តីសង្ខេបឆ្លើយតបទៅនឹងចំណុចហ្នឹង ។ មនុស្សជាច្រើនដែលជាអ្នករស់រានមានជីវិត ហើយជាអ្នកឈឺចាប់នោះគឺគាត់មានទុកសោកនូវជាប់ខ្លួន និងការឈឺចាប់ថាវាមិនអាចរសាយបាន ។ ដូច្នេះហើយវាមានភាពចាំបាច់ដែលប្រទេសនេះត្រូវការសន្តិភាព ដូច្នេះហើយយើងត្រូវការពិនិត្យទៅលើពេលអនាគតដែលយើងចង់បាននូវភាពដែលគេចង់បាន ។ ហើយនៅនិយាយនេះ គឺខ្ញុំមិនមែននិយាយក្នុងតួនាទីនៅក្នុងប្រទេសកម្ពុជាទេ ហើយវាក៏មិនមែនជាតួនាទីរបស់ខ្ញុំក្នុងការសម្តែងចេញនូវចំណុចនេះផងដែរ ។ ប៉ុន្តែនូវអ្វីដែលយើងបានឃើញប្រតិបត្តិការរបស់ខ្មែរក្រហម នៅក្នុងទស្សវត្សរ៍ទី៩០ យើងខ្ញុំអាចនិយាយថាការផ្សះផ្សាជាតិ គឺជាដំណើរការមួយដែលវាដំណើរការទៅមុខទៅលើចំណុចដែលគេចង់ស្វែងរកទៅលើការផ្សះផ្សានេះ ។

[១៤:១៥:១២]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ចេនណា ។ អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរតែមួយចំនួនតូចតែប៉ុណ្ណោះ ខ្ញុំសូមការអនុញ្ញាតសួរដែលខ្ញុំយល់ឃើញថាវាសំខាន់។ នៅក្នុងនេះគឺខ្ញុំអាចសួរហួសម៉ោងបន្តិច ហើយដោយសារតែយើងបានដំណើរការលឿននៅព្រឹកមិញ ដូច្នេះហើយគឺខ្ញុំសូមអនុញ្ញាតពីលោកប្រធានឲ្យខ្ញុំសួរឲ្យចប់ ជាពិសេសខ្ញុំចង់សួរអំពីតួនាទីរបស់ស-២១ ដែលយើងហៅថា សន្តិបាលនេះ ។

មុនពេលដែលខ្ញុំសួរខ្ញុំចង់សួរបញ្ជាក់ទៅលើចំណុចមួយចំនួន ខ្ញុំបានអានទៅលើស្នាដៃសំណេររបស់លោក សៀវភៅនិងអត្ថបទដែលលោកបានសរសេរអំពីប្រទេសកម្ពុជា ហើយលោកបាននិយាយនិងវិភាគទៅលើបញ្ហានយោបាយ ។

**ស៖** ទីមួយ ខ្ញុំចង់សួរលោកអំពីការស្រាវជ្រាវទៅលើប្រវត្តិសាស្ត្រ ដែលវាពាក់ព័ន្ធក្នុងទម្រង់ធំទៅលើកម្ពុជាប្រជាធិបតេយ្យ ។ ហើយលោកបានលើកឡើងយោងទៅលើស្នាដៃសៀវភៅ ដែលអ្នកប្រវត្តិសាស្ត្រមួយចំនួនបានសរសេរ ដូច្នេះហើយចំពោះខ្ញុំលោកហាក់ដូចជាផ្តោតទៅលើស្នាដៃនិពន្ធនាទសវត្សរ៍ចាប់ពីឆ្នាំ១៩-- ដែលលោកបានមកប្រទេសនេះ ។ ថាតើលោកអាចនិយាយអំពីស្នាដៃស្រាវជ្រាវទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យបានដែរឬទេ?

**ឆ៖** ខ្ញុំមិនធ្វើការតវ៉ាទេដែលខ្ញុំធ្វើការស្រាវជ្រាវក្រោយឆ្នាំ១៩៧៩ ។ ប៉ុន្តែ ដូចដែលខ្ញុំបានលើកឡើងពីមុនអ៊ីចឹង អ្នកប្រវត្តិដូច ប៊ែន ឃៀរនិន មកពីមហាវិទ្យាល័យយ៉េល ដែលជាសមាជិកខាងក្រុមប្រឹក្សាវិទ្យាសាស្ត្រដែលគាត់ជាអ្នកជំរុញឲ្យមានការបង្កើត *ឌីស៊ីខេម* ។ ហើយខ្ញុំក៏បានចូលរួមនៅក្នុងការងារស្រាវជ្រាវទាំងឡាយ ជាពិសេសនៅក្នុងវិស័យដែលបានពិភាក្សាជាមួយនឹងចៅក្រម ឡាវែន៍ទាក់ទងទៅនឹងការរើសអើងពូជសាសន៍នៅក្នុងវិស័យនយោបាយនៅក្នុងកម្ពុជាប្រជាធិបតេយ្យនាសម័យនោះ ។

**ស៖** សូមអរគុណ។ តើលោកបានធ្វើការសិក្សាស៊ើបអង្កេតទៅលើសន្តិបាល ឬក៏តួនាទីស-២១ នៅក្នុងយន្តការមន្ទីរសន្តិសុខនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ប្រសិនបើមាន ថាតើលោកមានបោះពុម្ពផ្សាយដែរឬទេ ដោយសារតែខ្ញុំមិនបានឃើញនូវឯកសារបោះពុម្ពផ្សាយស្នាដៃរបស់លោកទាក់

ទងទៅនឹងចំណុចហ្នឹង?

**ឆ៖** ខ្ញុំមិនបានបោះពុម្ពផ្សាយអត្ថបទទាំងឡាយទៅលើប្រធានបទនេះទេ ។ ប៉ុន្តែនៅក្នុងក្រុមការងារតែមួយនៅពេលដែលព័ត៌មានវាមិនសូវសម្បូរដូចសព្វថ្ងៃ ខ្ញុំនិយាយអំពីទសវត្សរ៍ទី៨០ និងទសវត្សរ៍ទី៩០ ។ ក្រុមការងាររបស់យើងមានទីតាំងប្រចាំការនៅសហរដ្ឋអាមេរិក យើងចាប់ផ្តើមកំណត់ទៅលើសមាសភាពមួយចំនួន និងធាតុផ្សំមួយចំនួនដែលយើងអាចយកមកបកប្រែនៅក្នុងការសម្រេចទៅលើខ្សែបញ្ជានៅក្នុងយន្តការមន្ទីរសន្តិសុខ ។ ខ្ញុំបានធ្វើការងារទៅលើចំណុចហ្នឹង ។

[១៤:១៩:០៩]

**ស៖** ខ្ញុំសូមអរគុណ ។ នៅក្នុងការចែករំលែករបស់លោក ដូចដែលលោកចៅក្រម ឡាវ៉ែន៍ បានលើកឡើងកាលពីមុន ។ យើងមិនឃើញមានចំណុចយោងនៅក្នុងរបាយការណ៍របស់លោក ដែលវាជាការគាំទ្រទៅលើសេចក្តីសន្និដ្ឋានរបស់លោក ។ ប៉ុន្តែ ការវិភាគរបស់លោកក្នុងនាមជាអ្នកស្រាវជ្រាវលក្ខណៈអាជីព ហេតុអ្វីបានជាលោកមិនប្រើប្រាស់ចំណុចយោងទាំងអស់នោះ? ហើយហេតុអ្វីបានជាលោកមិនដាក់ចំណុចយោង ហើយវារារាំងយើងមិនឲ្យយើងស្វែងយល់ និងរកឃើញនូវឯកសារដែលលោកបានសរសេរយោង?

**ឆ៖** ខ្ញុំយល់ទៅលើសំណួររបស់លោកយ៉ាងច្បាស់ ។ នៅពេលដែលខ្ញុំមើលទៅលើអត្ថបទដែលមិនមានចំណុចយោងនោះ គឺខ្ញុំមានការសោកស្តាយដែរ ប៉ុន្តែខ្ញុំបំពេញការងារទៅតាមអ្វីដែលខ្ញុំស្នើ គេស្នើខ្ញុំឲ្យសរសេររបាយការណ៍១៥០ទំព័រ ដូច្នេះហើយយើងពិបាកណាស់ ប្រសិនជាយើង បើឲ្យខ្ញុំសរសេរតែ៤០ទំព័រ ហើយមានជើងលេខទំព័រ ឬក៏លេខយោងអីផ្សេងៗនោះ គឺវាជាចំណុចមួយដោយឡែកទៅវិញ ។ ដូច្នេះហើយខ្ញុំបានលើកឡើងហើយជាមួយនឹងលោកចៅក្រម ឡាវ៉ែន៍ ។ ដូច្នេះ ហើយខ្ញុំយល់ថាឯកសារទាំងឡាយមានលក្ខណៈមិនរឹងមាំទេចំពោះអ្វីដែលយើងមើលទៅមិនឃើញមានចំណុចយោងលើកឡើងទៅលើអត្ថបទរបស់ខ្ញុំ ។

**ស៖** ប្រហែលលោកអាចផ្តល់លទ្ធភាព ឬក៏លោកអាចជួយផ្តល់នូវប្រភពឯកសារដែលលោកបានសរសេរថាតើលោកយកចំណុចយោងពីណាមកទាក់ទងទៅនឹងមន្ទីរសន្តិសុខ១៩៦កន្លែង ហើយដែលវាមានសរសេរបែងចែកជាបួន ហើយវាឆ្លើយតបទៅនឹងអង្គភាពរដ្ឋបាល និងអង្គភាពផ្សេងៗ ។ ហើយយើងឃើញថា វាមានការលើកឡើងអំពីឋានានុក្រមផ្សេងៗដែលមាននៅក្នុងឯកសារ D82 ទំព័រ ៧២ នៅក្នុងរបាយការណ៍របស់លោកជាភាសាបារាំង ។ ដូច្នេះហើយថាតើលោកសន្និដ្ឋានចេញពីប្រភពណា

ទាក់ទងទៅនឹងមន្ទីរសន្តិសុខដែលមានចំនួន១៩៦កន្លែងនោះ?

**ឆ៖** ប្រភពគឺខ្ញុំដកស្រង់ចេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ *ឌីស៊ីខេម* ។ ការស្រាវជ្រាវរបស់ខ្ញុំគឺខ្ញុំផ្អែកលើឯកសារ *ឌីស៊ីខេម* ។ ខ្ញុំអាចលើកឡើងឯកសារមួយចំនួនដែលខ្ញុំធ្វើការស្រាវជ្រាវ ។ ឯកសារទាំងអស់នោះ គឺស្ថិតនៅក្នុងបណ្ណសារ និងកន្លែងរក្សាទុកឯកសាររបស់ *ឌីស៊ីខេម* រួមជាមួយនឹងការស្រាវជ្រាវដែលបានធ្វើឡើងដោយអ្នកស្រាវជ្រាវដទៃៗទៀតដែលគេបង្ហាញអំពីខ្សែចង្វាក់នៃការភ័យខ្លាច គេបានវិភាគផ្សេងៗ ហើយគេបានលើកឡើងទៅលើចំណុចមួយ ។ ហើយទាក់ទងទៅនឹងការស្រាវជ្រាវដែលខ្ញុំធ្វើការសន្និដ្ឋាននៅក្នុងរបាយការណ៍របស់ខ្ញុំ ខ្ញុំមិនបានបញ្ជាក់អំពីទំនាក់ទំនងឋានានុ-ក្រមនៅក្នុងនោះទេ ។ ខ្ញុំនិយាយថាមានមន្ទីរ១៩៦ ឬច្រើនជាងនុំង ។ ប៉ុន្តែយើងមិនឃើញមានឋានានុ-ក្រមរវាងមន្ទីរសន្តិសុខទាំងនោះនោះទេ ។ ដូច្នេះហើយមន្ទីរសន្តិសុខទាំងអស់នោះមានតួនាទីដូចគ្នា និងមានមុខងារដូចគ្នាដូចដែលខ្ញុំបានបញ្ជាក់ជូនលោកចៅក្រម ឡាវែន៍ ពីមុន ។ លក្ខណៈរបស់មន្ទីរស-២១ជាឧទាហរណ៍ដូចដែលខ្ញុំបានលើកឡើង គឺមន្ទីរនេះអាចធ្វើការឃុំខ្លួនជនរងគ្រោះនិងសួរចម្លើយ ។

មន្ទីរស-២១ ចម្បងរបស់វាគឺថាវាមានយុត្តាធិការទូទាំងប្រទេស ដូច្នេះវាខុសពីគេ ។ ហើយខ្ញុំមិនមែនថា វាបង្កើតទៅជាទំនាក់ទំនងឋានានុក្រមស-២១ ធំជាងគេនោះទេ ។

[១៤:២៣:២៨]

នៅមន្ទីរស-២១ យើងនឹងឃើញមានបុគ្គលដែលគាត់ទទួលខុសត្រូវនៅក្នុងមន្ទីរសន្តិសុខនោះដែលគាត់មានតួនាទីខ្ពស់ជាងប្រធាន នៅមន្ទីរសន្តិសុខផ្សេងៗ ។ ប៉ុន្តែ នៅក្នុងវិស័យរដ្ឋបាលចំពោះមន្ទីរសន្តិសុខនេះ គឺមន្ទីរសន្តិសុខស-២១ វាមិនស្ថិតនៅក្នុងឋានានុក្រមដែលខ្ពស់ជាងគេនោះទេ ។

**ស៖** សូមអរគុណ ។ ប៉ុន្តែ នៅក្នុងការប្រឹក្សានិងការវិភាគរបស់លោកៗបាននិយាយទៅលើចំណុចហ្នឹង ។ នៅក្នុងកម្ពុជាប្រជាធិបតេយ្យឋានានុក្រមរដ្ឋបាលគឺវាហាក់ដូចជាមានកម្រិតខ្ពស់ ហើយលោកបានលើកចំណុចបួន ទាក់ទងទៅនឹងមន្ទីរសន្តិសុខគឺមន្ទីរដែលបានបង្កើតនៅក្នុងគណៈស្រុកគណៈតំបន់ គណៈភូមិភាគ ហើយចំណុចមួយដោយឡែកគឺវាបង្កើតដោយគណៈមជ្ឈិមដែលជាមន្ទីរស-២១ ។ ដូច្នេះ ថាតើវាមិនបញ្ជាក់ថាលោកបានលើកឡើងអំពីឋានានុក្រមរបស់វា ឬក៏យ៉ាងម៉េច ដោយសារតែវាមានឋានានុក្រមស្របទៅនឹងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ដើម្បីខ្ញុំអាចបញ្ជាក់ទៅលើចំណុចនេះបានឲ្យបានច្បាស់លាស់យើងត្រូវតែមាននូវឯកសារដែលជាការផ្លាស់ប្តូរគ្នារវាងមន្ទីរសន្តិសុខពីតំបន់ទៅតំបន់ ។ ប៉ុន្តែ យើងអត់មានទេ ។ អ្វីដែលយើងដឹង

នោះគឺយើងឃើញតាមរយៈឯកសារ ចុះថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ តែប៉ុណ្ណោះ ។ ហើយយើងមិនឃើញមានការបញ្ជាក់អំពីទំនាក់ទំនងទៅនឹងមន្ទីរសន្តិសុខនោះទេ ។ ដូច្នេះហើយយើងអាចដឹងច្បាស់ថា វាពិតជាពុំមាននូវឋានានុក្រមជាក់លាក់នោះទេ ។

**ស៖** គឺខ្ញុំសូមលើកនូវឧទាហរណ៍ដែលលោក វ៉ាន់ ណាត បានលើកឡើង គាត់ឆ្លើយនៅទីនេះ គាត់ត្រូវបានគេចាប់នៅសហករណ៍បាឡាត់ គាត់ត្រូវបានគេឃុំជាច្រើនដងដែរ ។ ប៉ុន្តែក្រោយមកគាត់ត្រូវបានគេបញ្ជូនទៅតំបន់៤ មួយយប់ បន្ទាប់មកបញ្ជូនទៅបាត់ដំបងដែលជាមន្ទីរសន្តិសុខ នៅគណៈស្រុក ។ ហើយក្រោយពីការឃុំខ្លួននៅតំបន់ស្រុកនោះរយៈពេលប៉ុន្មានថ្ងៃ គេបានបញ្ជូនគាត់បន្តមកមន្ទីរស-២១ ។ ថាតើចំណុចដែលគេបញ្ជូនអ៊ីចឹងនេះ វាមិនបានបញ្ជាក់ និងបង្ហាញយើងច្បាសប់លាស់ថា បុគ្គលទាំងឡាយដែលត្រូវបានគេចាប់ខ្លួន ត្រូវបានគេសួរចម្លើយនៅនឹងកន្លែង ឬក៏ត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខតែម្តង ប្រសិនបើបុគ្គលណាមួយត្រូវបានគេចាត់ទុកថាសំខាន់នោះ ។ ហើយលោកបានលើកឧទាហរណ៍ពីជនមួយចំនួនដែលត្រូវបានគេចាប់ខ្លួននៅក្នុងតំបន់ បន្ទាប់មកបញ្ជូនទៅតាមផ្នែកស្រុក ឬក៏ភូមភាគផ្សេងៗ?

[១៤:២៧:០៤]

**ឆ៖** សម្មតិកម្មនេះវាហាក់ដូចជាផ្ទុយ ហើយវាមិនមានអង្គហេតុបញ្ជាក់នោះទេ ។ ខ្ញុំមិនអាចនិយាយថា អ្វីដែលវាកើតឡើងទៅលើរូបលោក វ៉ាន់ ណាត នោះវាជាការអនុវត្តនោះទេ ។ អ្នកដែលចូលមកស-២១ គឺចូលគេបញ្ជូនដោយផ្ទាល់តែម្តង ។ យ៉ាងហោចណាស់អ្នកទាំងអស់នោះត្រឹមតែនៅមួយយប់តែប៉ុណ្ណោះនៅមន្ទីរសន្តិសុខតាមតំបន់ ប៉ុន្តែក្រោយមកពួកគេត្រូវបានបញ្ជូនទៅមន្ទីរស-២១តែម្តង។

**ស៖** តើលោកអាចពន្យល់យ៉ាងម៉េចទាក់ទងទៅនឹងមន្ទីរស-២១។ យើងឃើញថាមានសមាជិក ១៥៥រូបដែលជាសមាជិករបស់ស-២១ ប៉ុន្តែត្រូវបានគេចាប់ខ្លួន ហើយសម្លាប់ចោលនៅកន្លែងនោះតែម្តង ។ ប៉ុន្តែ មិនត្រឹមតែប៉ុណ្ណោះទេ យើងឃើញមានកម្មាភិបាលមកពីតំបន់និងកន្លែងផ្សេងៗ ។ ហើយជនជាប់ចោទបានលើកឡើងឈ្មោះ៤០រូប ដែលបានទទួលមកពីតំបន់និងភូមិភាគផ្សេងៗ ។

ថាតើលោកអាចពន្យល់យ៉ាងម៉េចថាតើអ្នកទាំងអស់នោះគឺបានមកបញ្ចប់ជីវិតនៅស-២១?

**ឆ៖** តាមអ្វីដែលយើងដឹងមិនដែលមានសមាជិកបុគ្គលិកនៅមន្ទីរសន្តិសុខស-២១ ត្រូវបានគេបញ្ជូនចេញទៅមន្ទីរសន្តិសុខផ្សេងនោះទេ ។ ខ្ញុំបានលើកឡើងពីព្រឹកមិញហើយចំណុចនេះវាសំខាន់ ។ សេចក្តីសម្រេចបញ្ជូនទៅស-២១ គឺវាដោយសារជាសេចក្តីសម្រេចចេញមកពីមជ្ឈិម ។ ដូច្នេះហើយ

ទើបគេបញ្ជូនមកមន្ទីរស-២១ ។ ដូច្នេះចំណុចនេះវាជាចំណុចមួយលក្ខណៈពិសេសនិងជាក់លាក់ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានខ្ញុំចង់ត្រឡប់ទៅរកសេចក្ដីសន្និដ្ឋានទៅសាក្សីអ្នកជំនាញព្រឹកមិញនេះ ។

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

បន្ទាប់ពីបានជជែកជាមួយយើងជាច្រើនអំពីឥទ្ធិពលនៃលទ្ធិកុម្មុយនីស្តស្តាលីនជាដើមហ្នឹងគឺគាត់បាននិយាយបន្តិចអំពីកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ នៅទីបញ្ចប់នៃសេចក្តីថ្លែងការណ៍នោះគាត់បានឯកភាពថា ឌុច អាចក្លាយទៅជាចារីផង ហើយនិងជនចំណាប់ខ្មាំងរបស់របបហ្នឹងផង ។ ថាតើសេចក្តីសន្និដ្ឋានហ្នឹងពឹងផ្អែកលើអ្វី វាផ្អែកលើសេចក្តីពន្យល់ដែលគាត់បានបញ្ជាក់ពីខាងដើម ឬក៏ផ្អែកទៅលើអ្វីដែលគាត់មិនបាននិយាយបញ្ជាក់ឱ្យបានជាក់លាក់នោះ ។ ប៉ុន្តែ ខ្ញុំអាចលើកទៅលើចំណុចបីនៅក្នុងចំណោមនោះ ។ នៅក្នុងនេះមានយោបល់មួយនិយាយអំពី លោកនិយាយថាមនុស្សមួយចំនួនបានឆ្លើយតបទៅតាមការអំពាវនាវរបស់សម្តេចសីហនុឱ្យចូលរួមជាមួយរណសិរ្សរួបរួមជាតិប៉ុន្តែ ឌុច មិនបានចូលទៅព្រៃទៅតាមការអំពាវនាវនោះទេ គាត់បានឯកភាពទៅនឹងមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជាហើយបានលះបង់ជីវិតដើម្បីបក្សនោះផង។ ប៉ុន្តែ យើងដឹងថាត្រូវតែដឹងអំពីគោលការណ៍មូលដ្ឋានដែលគាត់បានដឹងច្បាស់ហើយ គាត់ត្រូវដឹងអំពីមូលដ្ឋានគ្រឹះរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយគាត់ស្គាល់មេដឹកនាំខ្ពស់ៗនៅពេលនោះ ។ អ៊ីចឹងហើយគាត់មិនបានចូលទៅដោយភ្ញាក់ផ្អើលនោះទេ នៅក្នុងចលនានោះ ។ ហើយគាត់បានចូលរួមជាមួយមនោគមវិជ្ជាហើយអាចយល់ដឹងអំពីផលវិបាកនៃមនោគមវិជ្ជាហ្នឹងគឺការតស៊ូប្រដាប់អាវុធនោះផងដែរ ។ អ៊ីចឹងទាក់ទងទៅគំនិតទាំងហ្នឹងដែលនិយាយអំពីការចូលរួមរបស់គាត់ ។

ហើយចំណុចមួយទៀត លោកនិយាយអំពីអំពើភ័យរន្ធត់ដែលប៉ះពាល់ដល់កម្ពុជាទាំងអស់ដែលរាប់ទាំងអ្នកចូលរួមនៅក្នុងរបបនោះផងដែរ ។ ប៉ុន្តែ តើវាមិនពិតទេដែរឬទេចំពោះដែលថាជនជាប់ចោទបានចូលរួមយ៉ាងសំខាន់នៅក្នុងអំពើភ័យរន្ធត់នោះ ដូចជាការប្រឹងប្រែងធ្វើការងាររបស់គាត់ ការបង្កើតរៀបចំស-២១ ដោយការងារដ៏ម៉ឺងម៉ាត់របស់គាត់នោះ ការបង្រៀនរបស់គាត់ ។ ប្រសិនបើគាត់ជាចំណាប់ខ្មាំងនៅពេលដែលវៀតណាមចូលមកកាន់កាប់ក្រុងភ្នំពេញឆ្នាំ១៩៧៩ ហេតុអ្វីក៏គាត់បន្តទៅជាសមាជិកប្ដូរផ្ដាច់ឱ្យខ្មែរក្រហមគឺជាងដប់ឆ្នាំក្រោយមកទៀត ។ ហើយតើអ្វីជាកត្តាជំរុញ? ហើយគាត់ហេតុអ្វីក៏មិនឆ្លៀតយកឱកាសនៃការច្របូកច្របល់ហើយរត់ចេញពីចលនាហ្នឹង គឺរហូតគាត់នៅជាមួយ

ចលនានោះរហូតដល់ឆ្នាំ១៩៩៩ ។ ហើយទោះបីជា នួន ជា, ខៀវ សំផន, អៀង សារី ហ្នឹងបានចុះចូលមកភ្នំពេញនៅចុងឆ្នាំ១៩៩៨ ។ ដូច្នេះគឺរយៈកាលនៃការប្តូរផ្តាច់របស់គាត់នោះវែងណាស់ ។ តើនេះជាគំនិតដែលបញ្ជាក់ថាខ្លួនអះអាងថាជាចំណាប់ខ្មាំងនៃរបបនៃបក្សមួយបានឬទេ?

**ឆ៖** សូមអរគុណ ។ ខ្ញុំមិនបាននិយាយគាត់ជាចំណាប់ខ្មាំងទេ ឬគាត់ជាអ្នកបម្រើហើយនិងអ្នកគោរពតាមនូវការអនុវត្ត ។ ប៉ុន្តែចំណុចគឺថា មិនមែនថាមិនអាចជជែកមិនបាននោះទេ ប៉ុន្តែគឺថាគាត់ជាសមាជិកនៃបក្ស ម្ល៉ោះហើយគាត់ផ្នែកនៃប្រព័ន្ធដូចដែលខ្ញុំបាននិយាយ ។ ហើយគាត់នៅក្នុងជម្រកនៃបក្សនោះ គឺគាត់នៅក្នុងស្រមោលការគ្រប់គ្រងមួយដែលថារណសិរ្សរួបរួមជាតិរបស់ សីហនុ នៅកាលនោះ ។ ខ្ញុំមានការលំបាកក្នុងការទទួលស្គាល់ចំណុចមួយដែលថាជនជាប់ចោទថា គាត់ចូលរួមនៅក្នុងការបង្កើតនូវវិធីសាស្ត្រទារុណកម្មថ្មីដែលចំណុចទាំងនោះដែលត្រូវបានគេប្រើនៅស-២១ គឺគេស្គាល់យូរយារណាស់ហើយគឺថាពីមុននៅម-១៣ គេបានប្រើរបៀបនុំង ហើយក៏គេប្រើវិធីសាស្ត្រទារុណកម្មនៅក្នុងសង្គមនិយមរបបសម្តេចសីហនុពីមុននៅទសវត្សរ៍៦០, ៧០ មកផងដែរ នូវវិធីសាស្ត្រនេះក៏គេបានប្រើជា បន្តបន្ទាប់គឺដើម្បីបង្កើតភាពភ័យខ្លាចជាធម្មតា ។ ដូច្នេះ សំណួរទីបីរបស់លោក ខ្ញុំមិនមានលក្ខណៈ សាមញ្ញដូចលោកនិយាយទេ ។ យើងបានដឹងហើយថា នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មនុស្សរាប់ពាន់ ត្រូវបានកៀរដោយកងទ័ពខ្មែរក្រហមយកទៅភ្នំក្រវាញ ហើយនិងព្រំដែនថៃហើយនិងកន្លែងផ្សេងៗទៀត នោះគឺជាបណ្តាញនៃរណ្តៅរួមដែលថាបើសិនជានរណាមិនព្រមតាមការកៀររបស់គេទៀតគឺថាពួកគេនោះនឹងត្រូវសម្លាប់ ។ ហើយសំណួរសួរគឺចោទថា តើជននឹងត្រូវជាប្រធាននៃស-២១ ។

[១៤:៣៥:០០]

យើងគិតថា តើគាត់អាចផ្តាច់ខ្លួនចេញអំពីរបបចាស់របស់គាត់ តើឲ្យគាត់មានសុវត្ថិភាពដែរឬទេ? លោកបាននិយាយអំពីភាពចលាចលនៅក្នុងឆ្នាំ១៩៧៩ ប៉ុន្តែវាមានស្ថិរភាពនោះកើតឡើងបន្ទាប់ក្រោយហ្នឹង ប៉ុន្តែគេអាចគិតថាជនជាប់ចោទមិនឃើញមានអត្ថប្រយោជន៍អ្វីនឹងផ្តាច់ខ្លួន ដោយថាខ្លួនបានបម្រើការងារឲ្យគេជាងម្ភៃឆ្នាំមកហើយ គួរតែបន្ត ឬក៏គួរចេញពីគេ ។ អ៊ីចឹងហើយ ទោះបីជាគាត់ដឹងថាគាត់គឺជាចលនាដែលមិនមែនជារដ្ឋក៏ដោយ ដែរថានៅតែមានការលុបបំបាត់បុគ្គលម្នាក់ៗនោះចោលក្តី ប៉ុន្តែគាត់ជាជនរងគ្រោះនៃការប៉ុនប៉ងសម្លាប់ផងដែរ ដែរថាគេបានសម្លាប់ប្រពន្ធគាត់ ។ នេះជាចំណុចមួយ គឺថាមានហានិភ័យគ្រោះថ្នាក់សម្រាប់ជីវិតរបស់គាត់ដែលមិនអាចដកខ្លួនចេញបាន ។

ដូច្នេះចំណុច មួយទៀត គឺថាជាកត្តាមួយបំភ័យ ដែរថាខ្ញុំគិត បើប្រៀបធៀបទៅនឹងចំណុចហ្នឹង

គឺវាមានភាពគ្រោះថ្នាក់គឺមិនមានៗប្រធាននៃមន្ទីរសន្តិសុខដែលបានចូលទៅក្នុងក្រុមនោះទេ ។ ភាគច្រើននោះគេបានរត់ចេញ ហើយគេបានរត់ចេញអំពីរបបនោះចេញ ហើយទៅធ្វើជាជនភៀសខ្លួននៅអាមេរិកឡាទីន ។ និយាយពីការករណីប្រទេសផ្សេង ប៉ុន្តែក្នុងករណីដូចក្នុងឆ្នាំ១៩៧៩ ខ្ញុំមិនគិតថាគាត់មិនព្រមចូលនៅក្នុងអំណាចដែលជាអ្នកផ្តួលរបបគេនោះទេ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

ប្រសិនបើជាមានការអនុញ្ញាតពីអង្គជំនុំជម្រះ ខ្ញុំសូមអនុញ្ញាតសួរមួយសំណួរទៀត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែលោកត្រូវគិតគូរផងដែរ ពីព្រោះពេលវេលាដែលត្រូវបែងចែកនេះ យើងព្យាករណ៍ទៅប្រហែលជាអាចដំណើរការសវនាការសម្រាប់អ្នកជំនាញរូបនេះ មិនគ្រប់ទេមួយល្ងាចនេះ អាចបន្តទៅព្រឹកស្អែកទៀត ។ អ៊ីចឹង ពេលវេលាដែលបានគ្រោងប្រហែលជាមិនចប់តាមអ្វីដែលបានគ្រោងទុកនោះទេ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំមិនបានឮច្បាស់ពីអ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញទេលោកប្រធាន ហើយយើងមិនមានការបកប្រែ ។ ដូច្នេះ ខ្ញុំមិនដឹងថាត្រូវបានអនុញ្ញាត ឬក៏អត់ទេ? ខ្ញុំសូមអភ័យទោស ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អនុញ្ញាតជូនលោកដើម្បីឲ្យលោកបន្តសំណួរចុងក្រោយ ។ ប៉ុន្តែ អង្គជំនុំជម្រះរំឭកថាលោកបានប្រើពេលវេលា ដែលសុំលើសមិញគឺទ្វេដងនៃពេលវេលាដែលឲ្យហើយ ។ អ៊ីចឹងទេភាគីផ្សេងទៀត ក៏គេត្រូវការទ្វេដង ដូចខាងតំណាងសហព្រះរាជអាជ្ញាបានធ្វើដែរ ។ អ៊ីចឹង ពេលវេលាដែលបានគ្រោងទុកនោះ ប្រហែលជានៅរសៀលនេះមិនចប់តាមអ្វីដែលយើងបានប៉ាន់ស្មាននិងលៃពេលវេលាសម្រាប់ធ្វើសវនាការទេ ហើយវាមានឥទ្ធិពលដល់នូវដំណើរការសវនាការរបស់យើងសម្រាប់សប្តាហ៍នេះ ដែលគ្រោងថានឹងបញ្ចប់ការពិភាក្សាដេញដោលប្រហែលជាមិនអាចបញ្ចប់បានទេ យើងត្រូវធ្វើដំណើរការសវនាការដេញដោលតនៅក្រោយភ្ជុំទៀត ឯណោះ ។

នេះវាជារឿងហេតុដែលសូមរំឭកដល់សហព្រះរាជអាជ្ញាគួរតែប្រើប្រាស់នូវសំណួរឯណាដើម្បីឲ្យចំៗហើយនិងឲ្យបានលទ្ធផល ចៀសវាងអូសបន្លាយពេលវេលាឆ្ងាយហួសពីពេលវេលាដែលបានគណនា និងបានផ្តល់ជូនភាគីរួចហើយ ។

[១៤:៣៩:២៥]

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន ។ នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ។

**ស៖** លោក ចេនណា នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ចៅក្រម ខាតវ៉ាយថ៍ បានដកស្រង់សេចក្តីរបស់ ដេវីដ ឆេនដ៍ល័រ ហើយបានសួរទៅជនជាប់ចោទ គាត់បានឆ្លើយថា ខ្ញុំៗដកស្រង់ពីសៀវភៅរបស់លោក ឆេនដ៍ល័រ ។ ស-២១ ប្រហែលជាស្ថាប័នដែលមានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសនាកាលនោះ ហើយដោយហេតុថាស-២១ គឺជាម៉ាស៊ីនមួយសម្រាប់បំបាត់ខ្មាំងរបស់របបនោះ គឺថាស-២១ គឺជាអង្គភាពដ៏សំខាន់របស់បក្សបញ្ចប់ ហើយចៅក្រម ខាតវ៉ាយថ៍ បានសួរទៅទៀតថា តើវាស្របទៅនឹងរូបភាពដែលលេចធ្លោឡើងរបស់ស-២១ ទាក់ទងទៅនឹងស្ថាប័នមន្ទីរសន្តិសុខផ្សេងៗ សន្តិបាលផ្សេងទៀតដែរឬទេ? លោក ឆេនដ៍ល័រ បានឆ្លើយថា បាទ ពិតហើយ ។ ចៅក្រមបានធ្វើការវិភាគមួយចំនួន ហើយបាននិយាយថាបានវិភាគព័ត៌មានតែពីលើ ចំពោះមន្ទីរសន្តិសុខផ្សេងៗទៀតគឺថា ហើយលទ្ធផលគឺយើងមិនបានទទួលព័ត៌មាន ឬក៏ឯកសារដូចគ្នានៅមន្ទីរសន្តិបាលផ្សេងៗទៀត ពីព្រោះថាមន្ទីរទាំងនោះគឺមិនត្រូវបានដឹកនាំក្នុងកម្រិតបែបជាសន្តិបាល ដូចជាស-២១ ទេ ។ ដូច្នេះហើយ យើងគិតថាដូចវាមិនមានប្រសិទ្ធភាពដូចស-២១ ទេ គឺខុសពីស-២១ មន្ទីរសន្តិសុខផ្សេងៗទៀត គឺមិនធ្វើឲ្យមានការចាប់អារម្មណ៍ពីមេដឹកនាំប្រជាធិបតេយ្យកម្ពុជាក្នុងប្រទេសទេ ។ ប៉ុន្តែ ចម្លើយទៅនឹងសេចក្តីថ្លែងការណ៍របស់លោក ដេវីដ ឆេនដ៍ល័រ នោះ គឺថាស-២១ នោះ គឺជាស្ថាប័នដ៏សំខាន់របស់បក្សមជ្ឈិមហើយគាត់ឆ្លើយថា ស-២១ គឺជាមន្ទីរដែលដោះស្រាយ ហើយនិងចាត់ការចំពោះជនក្បត់ ឬក៏បណ្តាយក្បត់របស់បក្ស ហើយដែលមាន ឌុច ជាអ្នកដឹកនាំនៅកន្លែងនោះ ។ មនុស្សដែលត្រូវបានសម្លាប់នោះ ទៅតាមគោលការណ៍នោះ ក៏ប៉ុន្តែមិនមែនស-២១ ជាលក្ខណៈពិសេស ដែរថាប្រមូលយកចម្លើយសារភាពទាំងអស់ ហើយនិងកំណត់បណ្តាយជនក្បត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាតែមួយគត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ហើយការងារហ្នឹង មិនមែនធ្វើឲ្យស-២១ ពិសេសជាងកន្លែងដទៃនោះទេ ។

**ឆ៖** ខ្ញុំដូចមានការខកចិត្តបន្តិច ។ ខ្ញុំគោរពច្រើនទៅលើ ដេវីដ ឆេនដ៍ល័រ ហើយគាត់ជាអ្នកនាំមុខក្នុងការងារស្រាវជ្រាវនេះ ប៉ុន្តែយើងអាចនឹងមិនឯកភាពគ្នានូវចំណុចខ្លះ នៅពេលដែលលោកលើកថាបណ្តាយជាច្រើន ត្រូវបានគេរកឃើញខ្សែបណ្តាយនៅពេលនោះ ។ ខ្ញុំមិនដឹងច្បាស់ថា ស-២១ គឺជាស្ថាប័នដែលពូកែខាងស៊ើបអង្កេតខ្លាំងជាងគេនោះទេ មិនមានកំណត់ត្រា ប៉ុន្តែអ្នកដែលគេបញ្ជូនមក

ស-២១ ត្រូវបានគេសង្ស័យហើយគេអង្កេត ចួនកាលគេជាជនរងគ្រោះនៃការច្រណែន ឬក៏ការឈ្លោះប្រកែកគ្នានៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ឬក៏នៅក្នុងពេលនោះ ។ ប៉ុន្តែ នៅថ្នាក់លើវិញ មិនមែនជាអ្នកមើលការផ្ទាល់របស់ស-២១ គេមិនធ្វើការអង្កេតទេ គឺគេគ្រាន់តែជាអ្នកបញ្ជាក់ទៅលើថាសេចក្តីសម្រេចហ្នឹង វាត្រូវដែរឬអត់? គឺជាសេចក្តីសម្រេចរបស់អចិន្ត្រៃយ៍ចំពោះស-២១ ។ អ៊ីចឹង អាហ្នឹងជាការរកឃើញរបស់យើង ។

ចម្លើយសារភាពនោះ គឺជាឯកសារដែលគេដឹងជាទូទៅ ដែរថាជនរងគ្រោះនិយាយអ្វីដែលគេនិយាយ អាហ្នឹងតាមគោលការណ៍ ។ ប៉ុន្តែ នៅខាងថ្នាក់លើគឺមន្ទីរ៨៧០ ដែលទទួលពិនិត្យពីការផ្ញើទៅប៉ុន្តែជាសេចក្តីដកស្រង់របស់លោក ដេវីដ ឆេនដ៍ល័រ ខ្ញុំមិនឯកភាពចំណុចនេះទេ ពីព្រោះថាវាមានជនជាប់ចោទជាច្រើននៅក្នុងមន្ទីរសន្តិសុខ១៩៦ នោះ ។ ប្រសិនបើវាករណីបែបនោះ ហេតុអ្វីយើងមានមួយលាននាក់ជាង ដែលបានស្លាប់នោះ គឺថាអាចមានមួយម៉ឺនពីរពាន់ដែលបានស្លាប់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។ ទីមួយចំពោះស-២១ ។

ប៉ុន្តែ ប្រសិនបើមន្ទីសន្តិសុខផ្សេងៗទៀតវាមានប្រសិទ្ធភាពដូចគ្នាហ្នឹង វាគឺគប្បីតែវាមានឯកសារមានលក្ខណៈទារុណកម្ម ឬក៏អ្វីបែបហ្នឹង ។ មន្ទីរសន្តិសុខហ្នឹងគេបានកំណត់ហើយ ហើយយើង--អ្វីដែលយើងមាននៅជើងឯកនោះ គឺជាចំណុចមួយនៅកន្លែងវាលពិឃាតដែលជាបណ្តាយរបស់មន្ទីរសន្តិសុខស-២១ ប៉ុន្តែចំពោះកន្លែងផ្សេងៗទៀតកន្លែងទាំងនោះ ថ្វីត្បិតតែមានប៉ុន្តែមិនមែនជាកន្លែងចុងក្រោយ ដែរថាមេដឹកនាំថ្នាក់លើដែរថាបានទៅមើល ប៉ុន្តែវាមានថ្នាក់ដឹកនាំថ្នាក់កណ្តាល ថ្នាក់មធ្យមដែលត្រូវបានបញ្ចប់អាយុជីវិតនៅទីនោះដែរ ។

[១៤:៤៥:៤០]

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកជំនាញសាក្សី ហើយសូមអរគុណតុលាការដែលបានផ្តល់ពេលឲ្យខ្ញុំបន្ថែម ។

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន ។ លោកប្រធាន លោក លោកស្រីចៅក្រម ក្នុងនាមសហសេវិករបស់ខ្ញុំ ខ្ញុំចង់សួរសំណួរទៅលោក ចេនណា ។ យើងសង្ស័យ ហើយយើងឆ្ងល់ថាៗលោកបានជួបលោកឌុច នៅពេលដែលគាត់ជាប់ឃុំខ្លួន ហើយនៅក្នុងឯកសារសំណុំរឿង គឺមិនមានឯកសារណាមួយដែលបង្ហាញពីការធ្វើទស្សនកិច្ចនេះទេ ហើយមិនមានរបាយការណ៍នៃការសម្ភាសន៍នោះទេ ។ នេះជាបញ្ហា

មួយ តើក្នុងស្ថានសមត្ថភាពអ្វីដែលលោកបានចូលទៅជួបជនជាប់ចោទនោះ? តើជួបនៅពេលណា? ហើយអ្វីបានជាមិនមានរបាយការណ៍ដែលអនុញ្ញាតឲ្យភាគីនៃនីតិវិធីនេះឲ្យយល់ដឹងបាន ថាតើខ្លឹមសារនៃបទសម្ភាសន៍របស់លោកហ្នឹងដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីហើយរហូតដល់ម៉ោងបីអញ្ជើញចូលវិញ ។ បើភាគីណាមានសំណួរប៉ុនប៉ងសួរដល់អ្នកជំនាញរូបនេះ សូមចំណាយនៅក្នុងអំឡុងពេលដែលអង្គសវនាការចែកឲ្យ ។

មន្ត្រីតុលាការៗសូមរៀបចំផ្ដល់នូវកន្លែងសមរម្យសម្រាប់អ្នកជំនាញ នៅក្នុងអំឡុងពេលដំណើរការសម្រាកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[អង្គសវនាការសម្រាកពីម៉ោង ១៤:៤៧ នាទីដល់ម៉ោង១៥:០៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

សូមអញ្ជើញមេធាវីការពារក្ដីអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមសម្ដែងឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលសហសេរិកដើមបណ្ដឹងរដ្ឋប្បវេណីបានសួរទៅកាន់អ្នកជំនាញ ហើយគឺអ្នកជំនាញមិនត្រូវឆ្លើយទេ គឺមេធាវីការពារក្ដីជាអ្នកឆ្លើយវិញ ។ មេធាវីមានអំណាចក្នុងការស្នើសុំឲ្យមានការប្រឹក្សា ។ ដូច្នេះហើយវាហាក់ដូចជាការចោទអំពីការលើកឡើងរបស់មេធាវីការពារក្ដី ថាអ្វីៗដែលមាននៅក្នុងសំណុំរឿងគួរតែរៀបចំ ហើយចំណុចនេះហើយដែលអនុញ្ញាតឲ្យលោក ចេនណា ធ្វើការជួបជាមួយហ្នឹងលោកជនជាប់ចោទតាមដែលការចាំបាច់ ។ ដូច្នេះហើយគឺជាចំណុចដែលបានធ្វើឡើង។ ខ្ញុំមិនចាំបាច់ស្នើសុំពីលោកមេធាវី ឬក៏លោកស្រីមេធាវីនោះទេ ដូចជាការស្នើសុំពីខាងមេធាវីការពារក្ដី--

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានការជួបជាមួយនឹងកូនក្តីរបស់លោក លោកស្រីអ៊ីចឹង។ ដូច្នេះហើយ វាមិនជាការទាមទារពីខាងលោក ចេនណា ឲ្យដាក់ទៅលើរបាយការណ៍របស់គាត់ ដែលគាត់បានជួប ជាមួយជនជាប់ចោទនោះទេ ។

លោក ចេនណា បានរៀបចំរបាយការណ៍បានដាក់ហើយ ហើយវាមានលក្ខណៈតម្លាភាព ។ ដូច្នេះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើការតាំងសំណួរទៅកាន់អ្នកជំនាញទាក់ទងទៅនឹងខ្លឹមសារនៃ របាយការណ៍គាត់ដែលបានដាក់ជូននិងរួមទាំងសក្ខីកម្មទាំងឡាយដែលបានដេញដោលគ្នានៅចំពោះមុខ អង្គជំនុំជម្រះនេះផងដែរ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ។

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបានសូមគោរពលោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិ ហើយសូមជម្រាបសួរលោក ចេនណា ហើយខ្ញុំបាទឈ្មោះ គង់ ពិសី ហើយខ្ញុំបាទសូមតាំងសំណួរពីរ សំណួរទេ ហើយក្រោយពីនោះ ខ្ញុំជូនវេទិកានេះទៅឲ្យខាងក្រុមមួយនិងក្រុមបី ។ ហើយខ្ញុំឡើងមកនេះ ក្នុងតំណាងក្រុមពីរ ផង ហើយនិងក្រុមបួនផង ។

**ស៖** សំណួរទី១ ខ្ញុំសូមសួរទៅក្រោយបន្តិចទាក់ទងទៅនឹងការចាប់ខ្លួន ។ យើងយល់ហើយថា នៅក្នុងរបប លន់ នល់ ប្រហែលជំនាន់ឆ្នាំ៨៣-៨៤ ហើយឈានចូល៨៥ (ស៊ិក)ហ្នឹង គឺថាមិនទាន់បែក ភ្នំពេញហ្នឹង គឺថាមានខាងខ្មែរក្រហមហ្នឹង គេមានដាក់បណ្តាញចូលមកនៅក្នុងទីក្រុងភ្នំពេញហ្នឹងច្រើន ណាស់ មានថែមទាំងនៅទីវត្តអារាមក៏មាន នៅក្នុងកន្លែងផ្សេងៗទៀតក៏មានដែរ ។ ហើយដល់ពេលខ្មែរ ក្រហមវាយផ្តួលរំលំ លន់ នល់ ជំនាន់ហ្នឹងទៅ ខ្លួនបានកាន់កាប់ទីក្រុងភ្នំពេញ ។ នៅពេលដែលខ្លួន បានកាន់កាប់ទីក្រុងភ្នំពេញហ្នឹង គឺថាដោយសារតែខ្លួនឯងហ្នឹងធ្លាប់តែដាក់គិញ ដាក់អីចូលស៊ើបការណ៍ ស៊ើបអីអ៊ីចឹង កាលជំនាន់ លន់ នល់ ក្រោយមកទៀតឲ្យតែឃើញអ្នកដទៃផ្សេងទៀតយល់ឃើញថាខ្លួន គិតថាមិនសមហេតុសមផល ឬមួយក៏មិនមែនអ្នក១៧-- គឺអ្នក១៧ មេសា អ៊ីចឹងទៅក៏ចោទប្រកាន់អ្នក នោះ ថាជាខ្មាំង ហើយកម្ទេចចោល ហ្នឹងមួយទៅ ។

[១៥:០៩:០១]

មួយទៀតគឺថា នៅពេលដែលយកគេទៅសួរចម្លើយ។ ចម្លើយអស់ទាំងនោះបានមកគឺសុទ្ធតែជាចម្លើយប្រឆាំងទៅនឹងខ្លួនឯងទាំងអស់ ។ បានន័យថាពេលសួរចម្លើយហ្នឹង ជនដែលត្រូវបានសួរចម្លើយហ្នឹង ដែលចាប់ខ្លួនសួរចម្លើយហ្នឹងគឺឆ្លើយប្រឆាំងនឹងខ្លួនឯងទាំងអស់ គ្មានចម្លើយណាមួយដែលចៀសផុតពីការមិនប្រឆាំងខ្លួនឯងទេ ។ ហើយទាក់ទងទៅនឹងការដឹកនាំរបស់ជនត្រូវចោទនៅក្នុងមន្ទីរស-២១ទៀត គឺថាចម្លើយហ្នឹងគឺគាត់ធ្វើរបាយការណ៍ទៅឃើញថាមានទោសទាំងអស់ ជនរងគ្រោះនៅមន្ទីរស-២១ ។

អ៊ីចឹងខ្ញុំសូមសួរលោកបណ្ឌិតពីរសំណួរអ៊ីចេះ សួរថា តើលោកមានបានពិភាក្សាជាមួយហ្នឹងជនត្រូវចោទទេ ថាតើបញ្ហានេះគឺថាវាបណ្តាលមកពីមូលហេតុអ្វីបានជានាំឲ្យធ្វើអ៊ីចឹងបាទ? សូមអរគុណ។

**ឆ៖** សូមអរគុណ! ជាការពិត គឺខ្ញុំបានឆ្លើយហើយទាក់ទងទៅនឹងបញ្ហាចោទទៅលើចម្លើយសារភាពដែលវាជាចំណុចសំខាន់ក្នុងការស្វែងយល់មន្ទីរស-២១ និងប្រព័ន្ធភ័យខ្លាចនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ វាជាវិធីសាស្ត្រមួយចម្លែករហូតដល់គេ យើងយល់ស្របទៅលើចំណុចនេះ ។ គឺប្រព័ន្ធនេះរៀបចំដើម្បីទាញយកចម្លើយពីបុគ្គលដែលបានចាប់ខ្លួន ហើយក្រោយមកគឺបង្កើតទៅជាអំណាចរបស់គណកម្មាធិការអចិន្ត្រៃយ៍ដែលគេចង់ឲ្យជនទាំងអស់នោះនិយាយនូវអ្វីដែលគេចង់បាន ។

ដូច្នេះហើយយើងមិនត្រូវភ្លេចទេ ថាវាមានលក្ខណៈស្រដៀង និងដូចគ្នាទៅនឹងរបបសហភាពសូវៀត ។ ប៉ុន្តែនៅពេលនោះ ការចាប់ខ្លួនគឺមានន័យនឹងត្រូវបានគេកាត់ទោសប្រហារជីវិត ។ ដូច្នេះហើយគឺមិនមានការប៉ុនប៉ង និងព្យាយាមណាមួយក្នុងការកាត់ទោសផ្តាច់ជីវិតនៅក្នុងគោលបំណងណាមួយនោះទេ ។ គោលបំណងនៅក្នុងមន្ទីរសន្តិសុខនេះ គឺដើម្បីជំរុញឲ្យបុគ្គលដែលត្រូវបានគេចាប់ខ្លួននោះ គឺដើម្បីឲ្យពួកគេឆ្លើយ ហើយដើម្បីបន្តអំណាចនៃការគាបសង្កត់របស់របបនោះ ។

ដូច្នេះហើយយើងមិនត្រូវភ្លេចទេអំពីយន្តការនៃការគាបសង្កត់ដូចដែលខ្ញុំបានលើកឡើងខាងដើមគឺជាការប៉ុនប៉ង និងជាព្យាយាមស្វែងរកខ្មាំងរបស់គេ ហើយវាមិនមែនដូចដែលខ្ញុំលើកឡើងពីដើមនោះទេ ប៉ុន្តែវាក៏ដូចនឹងប្រព័ន្ធដែល *ផារ៉ាណូយ៉ា* (paranoia) គឺប្រព័ន្ធភ័យខ្លាច ប៉ុន្តែខ្ញុំមិនទាន់មានលក្ខណៈបញ្ជាក់ទៅលើចំណុចហ្នឹង ។ នៅពេលដែលយើងដឹងអំពីខ្មាំងស៊ីរ៉ូងផ្ទៃក្នុងនោះ គឺអ្នកដែលត្រូវគេចាប់ខ្លួននោះ ត្រូវបានគេបង្ខំឲ្យឆ្លើយទៅលើបុគ្គលដែលគេស្គាល់ថា អ្នកទាំងអស់ផ្សេងទៀត គឺជាខ្មាំងផ្ទៃក្នុងផងដែរ ។ ដូច្នេះហើយ វាមានការរៀបចំឡើងមិនត្រឹមតែរកអ្នកដែលត្រូវបានគេចាប់ខ្លួន និងមានកំហុសនោះទេ ហើយដើម្បីស្វែងរកបុគ្គលផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធផងដែរ ។

**ស៖** សូមអរគុណលោកជំនាញ។ សំណួរទីពីរទៀតទាក់ទងទៅនឹងរដ្ឋបាលសាធារណៈ យកទៅអនុវត្តនៅក្នុងមន្ទីរស-២១ ។ តើលោកមានបានពិភាក្សាជាមួយជនជាប់ចោទទេ ថារបៀបនៃការដឹកនាំហ្នឹងគឺគេប្រើរបៀបរដ្ឋបាលសាធារណៈហ្នឹងវាយ៉ាងម៉េចដែរ? ខ្ញុំជូនជាសញ្ញាណបន្តិច គឺថាការដឹកនាំរបៀបផ្នែកនយោបាយ ឬមួយក៏ផ្នែករបៀបនៃការចាត់ចែង ឬមួយក៏របៀបនៃការដឹកនាំទៅតាមផ្លូវច្បាប់? សូមអរគុណ ។

**ឆ៖** ខ្ញុំមិនបានសួរសំណួរពិភាក្សាបញ្ហាហ្នឹងជាមួយហ្នឹងជនជាប់ចោទនោះទេ ។ ខ្ញុំគ្រាន់តែធ្វើការកំណត់អំពីលទ្ធិ ឬក៏មនោគមវិជ្ជា ដែលវាកើតឡើង ហើយនៅក្នុងប្រព័ន្ធដែលជនជាប់ចោទគាត់បានបំពេញការងារ ហើយថាតើគេទាញ និងការយល់ឃើញយ៉ាងម៉េចទៅលើមនោគមវិជ្ជាទាំងអស់នោះ? ហើយខ្ញុំមិនបានផ្តោតការពិភាក្សារបស់ខ្ញុំ ពិភាក្សាទៅលើកិច្ចការរដ្ឋបាលសាធារណៈនៅមន្ទីរស-២១ នោះទេ ។ ការងារទាំងអស់នេះ គឺបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតរួចហើយ ។ ដូច្នេះហើយការងារនេះ គឺខ្ញុំមិនបានស្នើឲ្យធ្វើការពិនិត្យពិច័យទៅលើចំណុចនោះទេ ។ ហើយខ្ញុំក៏មិនបានសិក្សាទៅលើរចនាសម្ព័ន្ធផ្ទៃក្នុងដែលវាមាននៅក្នុងមន្ទីរហ្នឹងផងដែរ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកជំនាញ ។ ខ្ញុំក៏សូមអរគុណលោកប្រធានដែរ ហើយតទៅនេះគឺថាសូមឲ្យលោកមេធាវីក្រុមផ្សេងទៀត ក្រុមមួយ ឡើងតាំងសួរសំណួរបន្តបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយ ។

[១៥:១៥:៤២]

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន សូមគោរពលោក ចេនណា ។ ឈ្មោះរបស់ខ្ញុំ អាឡាំង វ៉ែនណឺ ខ្ញុំតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមជាមួយនឹងសហសេវិករបស់ខ្ញុំ ទី ស្រ៊ីនណា ។ ខ្ញុំមានសំណួរតែបន្តិចតែប៉ុណ្ណោះ ដោយសារតែយើងខ្ញុំមានពេលវេលាតិច ហើយខ្ញុំរីករាយ និងអរគុណលោកប្រសិនបើលោកឆ្លើយដោយខ្លីៗទៅនឹងសំណួររបស់ខ្ញុំ ។

**ស៖** ខ្ញុំចង់សួរបន្តទៅលើសំណួរដែលលោកបានឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។ យើងសួរអំពីប្រភព ហើយយើងដឹងហើយថា តើប្រភពណាដែលលោកបានផ្តោតទៅលើ? តើលោកអាចផ្តល់

ទៅលើប្រភពទាំងអស់នោះទេ ទាក់ទងទៅនឹងកម្មាភិបាលជាអន្តរការីផ្សេងៗដែលលោកបានលើកឡើងនៅក្នុងរបាយការណ៍របស់លោកផងដែរ?

**ឆ៖** ខ្ញុំបញ្ជាក់ថា អ្វីដែលខ្ញុំបញ្ជាក់ជូនសហព្រះរាជអាជ្ញានោះ គឺប្រភពដែលខ្ញុំពឹងផ្អែកទៅលើឯកសាររបាយការណ៍របស់ខ្ញុំ គឺមកពី *ឌីស៊ីខេម* (DC-Cam) ហើយខ្ញុំមិនអាចផ្តល់ឈ្មោះទៅលើឯកសារទាំងអស់នោះនៅពេលនេះទេ ។

**ស៖** តាមដែលខ្ញុំដឹងគឺថាបណ្ណសាររបស់ *ឌីស៊ីខេម* គឺអាចទទួលឯកសារពីនោះបាន ។ នៅក្នុងឯកសាររបស់លោក គឺមានការលើកឡើង គឺលេខ ERN 00188870 ។ គឺលោកបានឡើងអំពីកំណាត់និងសៀវភៅទាក់ទងទៅនឹងការងារនៅក្នុងមន្ទីរស-២១ ហើយក៏បានលើកឡើងអំពីវិធីសាស្ត្រនៃការធ្វើទារុណកម្មនៅក្នុងរបបនោះ រួមទាំងរបបមុនផងដែរ នៅក្នុងរបបឆ្នាំ៧០-៧៥ ។

តើលោកលើកអំពីឯកសារកំណត់ដែលលោកបានលើកឡើងនោះ ឯកសារកំណត់ដៃដែលលោកបានលើកឡើងពីអ្នកសួរចម្លើយមួយនោះ ថាតើលោកបានប្រភពមកពីណា? ហើយលោកបានកំណត់យ៉ាងម៉េចថាគេប្រើវិធីសាស្ត្រនោះនៅក្នុងរបបមុនៗនិងរបបកម្ពុជាប្រជាធិបតេយ្យ? តើលោកបានពឹងផ្អែកទៅលើឯកសារអ្វីដែលលើកឡើងអំពីកំណត់ហេតុដៃនោះ?

[១៥:១៨:២០]

**ឆ៖** នៅពេលដែលខ្ញុំសម្ភាសន៍ជាមួយជនជាប់ចោទ ខ្ញុំបានសួរសំណួរអំពីវគ្គបណ្តុះបណ្តាលហើយខ្ញុំមានការចាប់អារម្មណ៍ចង់ដឹងថា តើវិធីសាស្ត្រទាំងអស់នោះបានមកពីណា? អ្នកបានបង្រៀនហើយគេសិក្សាពីណាមក? ហើយនៅពេលនោះ គឺខ្ញុំបានលើកឡើងទៅលើចំណុចមួយចំនួនផងដែរ ។ ហើយខ្ញុំក៏បានលើកឡើងនៅក្នុងសក្ខីកម្មដើមរបស់ខ្ញុំ គឺការធ្វើទារុណកម្ម ឬក៏សៀវភៅទារុណកម្មនោះគឺជាសៀវភៅដែលបានរៀបចំឡើងនៅស-២១ គឺមានវគ្គបណ្តុះបណ្តាលរៀបចំឡើងដោយសន្តិបាលសម្រាប់បុគ្គលិកក្រៅពីបុគ្គលិកស-២១ ។ ហើយយើងឃើញហើយបុគ្គលដែលគាត់ទទួលខុសត្រូវនោះក៏មានបុគ្គលមកពីមន្ទីរសន្តិសុខផ្សេងៗផងដែរ ។

**ស៖** ចំណុចចុងក្រោយនេះ គឺផ្អែកទៅលើការរៀបរាប់របស់ជនជាប់ចោទ តើត្រឹមត្រូវដែរឬទេ? ខ្ញុំអត់ឮពីសាក្សីជំនាញដោយសារតែមីក្រូហ្វូននោះមិនបើកទេ សូមឲ្យលោកបញ្ជាក់សាជាថ្មី ។

**ឆ៖** បាទ, ខ្ញុំបញ្ជាក់មែន។ គឺអ្វីៗនិងព័ត៌មានចុងក្រោយអម្បាញ់មិញនេះ គឺខ្ញុំបានមកពីជនជាប់ចោទ ។

**ស៖** លោក បណ្ឌិត អេតឆេសាន់ គាត់បានលើកឡើងថា វិធីសាស្ត្រទារុណកម្មនៅមន្ទីរស-២១ វាប្លែកពីទារុណកម្មនៅមន្ទីរសន្តិសុខផ្សេងៗទៀត ដោយសារតែភាពសាហាវរបស់វា ហើយលោកក៏បាន លើកឡើងទៅលើចំណុចនេះផងដែរ ។ ខ្ញុំសូមសួរឲ្យជាក់ តើនៅក្នុងការស្រាវជ្រាវរបស់លោក តើមាន អ្វីដែលវានាំឲ្យលោកពិចារណាទៅលើចំណុចដែលលោក អេតឆេសាន់ បានលើកឡើង ហើយលោកបាន ផ្តល់មតិផ្ទុយទៅលើចំណុចហ្នឹង? តើលោកមានចំណុចអ្វីដែលជំរុញឲ្យលោកគិតដូច្នោះ?

**ឆ៖** យើងមិនមានការបញ្ជាក់ផ្ទុយពីនុ៎ងនោះទេ ដែលវាអាចជំរុញឲ្យយើងនឹងអាចធ្វើឲ្យយើង លើកឡើងថាវិធីនៃការសួរចម្លើយ និងការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខ គឺវាមានលក្ខណៈទន់ស្រាល ឬក៏វាមានធូរស្រាលជាងនៅស-២១ ។ ប៉ុន្តែ ដូចដែលខ្ញុំបានលើកឡើងនៅក្នុងការឆ្លើយតបរបស់ខ្ញុំ យើង ឃើញមានការវគ្គបណ្តុះបណ្តាលរបស់-- ទៅដល់សមាជិកមកពីមន្ទីរសន្តិសុខផ្សេងៗ ។ ដូច្នេះហើយ ហេតុអ្វីបានជាមានហេតុផលថា មន្ទីរសន្តិសុខផ្សេងមិនប្រើ ឬក៏ប្រើការធ្វើទារុណកម្មដូចដែលមន្ទីរ សន្តិសុខនៅស-២១ ។

**ស៖** លោកបានលើកឡើងពិភាក្សាទៅលើចម្លើយសារភាព ដើម្បីឲ្យយល់នៅអ្វីដែលលោកបាន លើកឡើង តើវាត្រឹមត្រូវដែរឬទេក្នុងការនិយាយថា នៅពេលដែលយើងនិយាយអំពីចម្លើយសារភាពនៅ មន្ទីរនៃប្រទេស យើងមិនអាចពិភាក្សាទៅលើចម្លើយសារភាពនៅមន្ទីរសន្តិសុខផ្សេងៗនោះទេ ដោយ សារតែមានការកម្ទេចទៅលើឯកសារទាំងអស់នោះ?

**ឆ៖** អ្វីដែលខ្ញុំបានលើកឡើងហើយនិងអ្វីដែលខ្ញុំនិយាយដដែលសាជាថ្មីទៀតនេះ គឺវាជាវិធី សាស្ត្រផ្នែកវិទ្យាសាស្ត្រដែលយើងត្រូវប្រុងប្រយ័ត្ន ដោយសារតែយើងមិនរកឃើញព័ត៌មានផ្សេងៗដែល វាមាន ។ ដូច្នេះហើយវាមានភាពងាយស្រួលនៅកន្លែងផ្សេងដែលគេអាចបំផ្លាញបាន ជាងនៅមន្ទីរ ស-២១ ។ ប្រធានមន្ទីរស-២១ ត្រូវបានមេរបស់គាត់ដែលស្ថិតនៅក្នុងឋានៈខ្ពស់ គឺគាត់បានប្រាប់អំពី លក្ខខណ្ឌមិនឲ្យធ្វើការកម្ទេច ។

**ស៖** ខ្ញុំហាក់ដូចជាមិនសូវយល់នូវចម្លើយរបស់លោក ជនជាប់ចោទបានលើកឡើងនៅក្នុងការ សម្ភាសន៍បញ្ជីអ្នកទោសខ្មាំង រៀបចំឡើងដោយអ្នកជាប់ឃុំ និងបុគ្គលិកតាមការស្នើ ។ ដូច្នេះហើយ បញ្ជីអ្នកទោសដែលត្រូវបានគេចោទប្រកាន់នោះ គឺត្រូវបានគេចែកជូនទៅតាមប្រទេស ទៅតាមតំបន់ ផ្សេងៗនៅក្នុងប្រទេស ។ ដូច្នេះហើយថា តើបុគ្គលិក ស-២១ គាត់ជាអ្នកប្រមូលបញ្ជីខ្មាំង ។ ហើយជា ការពិតទៅគឺថា បញ្ជីខ្មាំងទាំងអស់នោះត្រូវបានគេចែកចាយ ហើយនិងគេបានបញ្ជាក់ ។ នៅក្នុងការ

ស្រាវជ្រាវរបស់លោកថា តើវាមានប្រភពណាមួយជាក់លាក់ដែលអនុញ្ញាតឲ្យលោកនិយាយថា បញ្ជីខ្មាំងទាំងអស់នោះ គឺជាការដែលគេរៀបចំឡើងដើម្បីតាមចាប់ខ្មាំង ហើយក៏ដូចជានៅមន្ទីរសន្តិសុខផ្សេងៗដែលគេមានការរៀបចំទៅលើបញ្ជីខ្មាំងនេះដែរ?

[១៥:២៣:២១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំចង់ឲ្យលោក វ៉ែនណឺ និយាយយោងទៅលើ-- បញ្ជាក់ចំណុចយោងទៅលើពេលវេលាដែលលើកឡើងអំពីបញ្ជីខ្មាំងពីរពាន់បញ្ជីនោះ ។ ហើយខ្ញុំបានឮលោក អេតធេសាន់ បានលើកឡើងទៅលើចំណុចហ្នឹង ប៉ុន្តែមិនមែនជនជាប់ចោទទេ ជាអ្នកលើកឡើងទៅលើចំណុចហ្នឹង ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** ខ្ញុំនៅពេលនេះខ្ញុំសូមរៀបចំសំណួររបស់ខ្ញុំសាជាថ្មី ។ ជនជាប់ចោទបានសារភាពថា មានបញ្ជីខ្មាំងដែលរៀបចំនៅមន្ទីរស-២១ ដោយខ្មាំង ។ ជនជាប់ចោទក៏បានលើកឡើងផងដែរថា អ្នកយាមនៅមន្ទីរស-២១ បានរៀបចំបញ្ជីសង្ខេបទាំងនោះ ។ លោកបណ្ឌិត អេតធេសាន់ ដែលគាត់លើកឡើងអំពីបញ្ជីទាំងពីរប្រភេទនោះ គាត់បានបញ្ជាក់ថាមានបញ្ជីបែបហ្នឹងរាប់ពាន់បញ្ជី ។ ខ្ញុំចង់សួរទៅលើជំនាញថា តើមានធាតុផ្សំណាមួយនៅក្នុងរបាយការណ៍របស់លោកដែលអាចបញ្ជាក់ថាបញ្ជីខ្មាំងអាចកើតមាន និងរៀបចំឡើងនៅមន្ទីរសន្តិសុខផ្សេងៗទៀតដូចនៅមន្ទីរស-២១ ដែរ?

**ឆ៖** ជាបឋម ខ្ញុំមានបញ្ហានៃការលើកឡើងអំពីបញ្ជីខ្មាំង ហើយចំពោះចម្លើយសារភាពវិញ គឺយើងឃើញមានឈ្មោះ ប៉ុន្តែខ្ញុំមិនមានលើកឡើងអំពីបញ្ជីនោះទេ ។ ប៉ុន្តែ យើងឃើញមានឈ្មោះបញ្ជីដែលខ្ញុំដឹងនោះ គឺបញ្ជីទាំងឡាយដែលបានរៀបចំឡើងក្រោយពីអង្គហេតុ ។ សហព្រះរាជអាជ្ញាគាត់បានលើកឡើងអំពីបញ្ជីដែលវាកើតចេញពីមន្ទីរសន្តិសុខផ្សេងៗ ហើយយើងឃើញថាបញ្ជីនេះគឺរៀបចំនៅពេលក្រោយទេ ។ ក្រោយពេលដែលអ្នកចូលមកកាន់មន្ទីរស-២១ នេះតាមអ្វីដែលយើងបានដឹង ។ ចំពោះខ្ញុំផ្ទាល់ខ្ញុំមិនបានដឹងអំពីអត្ថិភាពនៃបញ្ជីទាំងឡាយដែលគេបានរៀបចំឡើងនោះទេ គឺបញ្ជីខ្មាំងដែលគេបានរៀបចំឡើងមុនពេលដែលមានការចាប់ខ្លួន គឺខ្ញុំមិនបានដឹងទៅលើចំណុចនេះទេ ។

[១៥:២៥:៥៤]

**ស៖** ប្រហែលខ្ញុំនិយាយខុសទៅលើចំណុចហ្នឹង ។ ខ្ញុំនិយាយអំពីបញ្ជីដែលបានរៀបចំឡើងក្រោយពីការឆ្លើយសារភាពចប់សព្វគ្រប់ គឺយើងឃើញថា មានការរៀបចំបញ្ជីទាំងនោះក្រោយពីការសារភាពរបស់សខ្មាំង គឺខ្ញុំចង់និយាយទៅលើចំណុចនេះ ។

**ឆ៖** នៅពេលដែលយើងនិយាយអំពីបញ្ជី ជាការពិតគឺបញ្ជីយើងឃើញមានឈ្មោះនៅទំព័រចុងក្រោយនៅក្នុងចម្លើយសារភាព ដូច្នេះហើយយើងឃើញមានបញ្ជីទាំងអស់នោះ ។

**ស៖** លោក ចេនណា លោកបានលើកឡើងអំពីបរិយាកាសនៃការភ័យខ្លាច និងការលាក់កំបាំងនៅក្នុងរបបនោះថា តើលោកពន្យល់យ៉ាងម៉េចថា ជនជាប់ចោទអាចរយៈពេល៩ឆ្នាំ ពីឆ្នាំ៧១ ដល់៧៩ ហេតុអ្វីបានជាគាត់អាចនៅតែរក្សាខ្លួនមិនមានការកាប់សម្លាប់ពីមេរបស់គាត់ក្នុងរយៈពេលប្រាំបីឆ្នាំ ហើយដឹកនាំជាមេនៅក្នុងមន្ទីរសន្តិសុខចំនួនពីរនោះ?

**ឆ៖** ដើម្បីឆ្លើយតបទៅនឹងសំណួររបស់លោក យើងឃើញថាការបោសសម្អាតមានការកើតឡើងថា តើលោកពន្យល់យ៉ាងម៉េចថា បុគ្គលមួយចំនួន ឬមេមួយចំនួនមកពីគណៈអចិន្ត្រៃយ៍មិនត្រូវបានគេសម្លាប់ អ៊ីចឹងវាដូចទៅអ្នកដទៃអ៊ីចឹងដែរ ។ វាស្ថិតទៅក្នុងការដែលគេពិចារណាសមហេតុផលដែលថាពួកគេមិនមែនជាខ្មាំង ដូច្នេះហើយវាជាសំណួរសាមញ្ញ ប៉ុន្តែវាមិនមែនជាការជំរុញជាក់ស្តែងទៅដល់អ្នកទាំងអស់នោះទេ ។ ប៉ុន្តែយ៉ាងណាក៏ដោយការដែលមានការតតាំងពីសត្រូវខ្មាំងនោះ វាជាកត្តា។ ប៉ុន្តែដោយសារតែមានការជឿជាក់ ហើយនិងមានការងប់ងុល យើងឃើញថា មានការចោទប្រកាន់អំពីកាហ្សេបេ, សេអ៊ីអា នៅពេលដែលមានការសង្ស័យនោះ គេត្រូវពិចារណាទៅលើមនោគមវិជ្ជារបស់លេនីន ។ ដូច្នេះហើយ យើងឃើញថា វាជាយុទ្ធសាស្ត្រ ឬក៏វិធីសាស្ត្រ ហើយយើងឃើញថាមេដឹកនាំមួយចំនួនរបស់កុម្មុជាប្រជាធិបតេយ្យ គឺគាត់អាចរស់រានមានជីវិតក្រោយពីរបបនោះទៀត ។ ប៉ុន្តែយើងឃើញថាវាមានហេតុផល ដែលថាគេអាចសង្ស័យទៅលើបុគ្គលមួយចំនួនដែលគាត់អាចជាខ្មាំង ។

**ស៖** យើងឃើញមានអ្នកសួរចម្លើយម្នាក់ឈ្មោះ ប្រាក់ ខន ដែលគាត់មកផ្តល់ចម្លើយនៅទីនេះ។ ប្រាក់ ខន ដែលជាអ្នកសួរចម្លើយនោះ គាត់បានធ្វើការស្បថនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ អ្នកនោះបានលើកឡើងថា មិនមានមនុស្សតិចជាងបីរយនាក់ទេ មកពីកងពល៧០៣ ដែលធ្វើនៅមន្ទីរស-២១ ត្រូវបានគេស្លាប់នៅក្នុងអំឡុង៧៥ ដល់៧៩ ហើយលោកម្នាក់នុ៎ងត្រូវបានគេសួរអំពីមូលហេតុដែលអ្នកទាំងអស់នោះ ត្រូវបានគេសម្លាប់នៅមន្ទីរស-២១ ។ ហើយគាត់បានឆ្លើយថា ហេតុផលដែលអ្នកទាំង

អស់នោះត្រូវបានគេសម្លាប់នោះ គឺដោយសារជនជាប់ចោទមិនចង់ឲ្យកងពល៧០៣ ទទួលបានអំណាចធំធេង ។ ហើយជនជាប់ចោទគាត់ភ័យខ្លាចថា គាត់មិនអាចនៅជាមេ ឬក៏ប្រធានស-២១ ។ សំណួររបស់ខ្ញុំ ខ្ញុំចង់សួរថា អ៊ីចឹងគឺយើងមិនអាចសង្ស័យគេទៀតទេចំពោះការលើកឡើងដែលថា គាត់មានការភ័យខ្លាចដែលគាត់ត្រូវសម្លាប់គេ ។ ប៉ុន្តែ នៅក្នុងនេះយើងឃើញថា គាត់ធ្វើសម្លាប់គេដើម្បីរក្សាតំណែង និងអំណាចរបស់ខ្លួន តើលោកអាចពន្យល់នៅលើចំណុចនេះយ៉ាងម៉េចដែរ?

[១៥:៣០:២៤]

**ឆ៖** ខ្ញុំគិតថាខ្ញុំជម្រាបលោកគឺជាការនិយាយដោយមិនទាន់ច្បាស់លាស់ គឺថាតើអ្វីជាកត្តាជំរុញពីព្រោះថាយើងមិនមានភស្តុតាងអ្វីមកបង្ហាញទេ ពីព្រោះថា ផ្អែកលើថាតើលោកចង់ចោទប្រកាន់បុគ្គលម្នាក់ឬក៏ផ្អែកលើព័ត៌មានហ្នឹង ។ អ៊ីចឹងគឺថាជាបញ្ហាទាក់ទងនឹងអំណាចគឺពិតហើយ ប៉ុន្តែលោកនិយាយផ្ទុយពីហ្នឹងទេ គឺថាអ្វីដែលលោកបញ្ជាក់នោះ ។ ខ្ញុំមិនអាចនិយាយពីអ្វីដែលថា ខុសពីការពិតនោះទេ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ ។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីបាទ ។ មានទេ?

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធាន! ខ្ញុំចង់ជម្រាបលោកប្រធានថា យើងផ្អែកតាមសំណួររបស់លោក អាឡាំងវ៉ែន៍ យើងមិនមានសំណួរអ្វីទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញរូបនេះ ប្រសិនបើមានសំណួរសូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។

សូមគោរពលោកបណ្ឌិត! ខ្ញុំបាទសូមអនុញ្ញាតអានពីរឃ្លាដែលនៅមាននៅក្នុងរបាយការណ៍ស្រាវជ្រាវរបស់លោកបណ្ឌិត ដោយលោកបណ្ឌិតបានបញ្ជាក់ថា "ក្នុងចំណោមមន្ទីរសន្តិសុខទាំង១៩៦

ប្រធានមន្ទីរសន្តិសុខទាំងដប់ អាចចូលទៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ជាតិ និងអន្តរជាតិ" ។

**ស៖** ខ្ញុំសូមសួរលោក ហើយសូមលោកបញ្ជាក់មើល៍ ព្រោះអីចេះ លោកបានដាក់ក្នុងរបាយ-ការណ៍ហ្នឹងគឺថា តាំងពីគុកចុងជ្រោយរហូតមកស-២១ នៅក្នុងលំដាប់ថ្នាក់ទី១០ ។ អ៊ីចឹងបានលោកសរសេរថា ប្រធានមន្ទីរសន្តិសុខទាំងដប់ អាចចូលទៅក្នុងប្រភេទជនទាំងឡាយទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ ប៉ុន្តែ ខ្ញុំមើលនៅក្នុងរបាយការណ៍ទាំងអស់របស់ *ឌីស៊ីខេម* ក៏ដូចជានៅក្នុងរបស់លោកឃើញថា មន្ទីរសន្តិសុខទាំង១៩៦ គឺមានតួលេខដែលស្លាប់មនុស្សមានតែ៦៤មន្ទីរសន្តិសុខទេ ។ អ៊ីចឹង! ប្រធានមន្ទីរសន្តិសុខទាំងដប់នេះ គឺជាប្រធានមន្ទីរសន្តិសុខក្នុងចំណោម៦៤ ដែលមានតួលេខ ។ សូមលោកបញ្ជាក់មើល! តើអ៊ីចឹងមែនឬទេ?

[១៥:៣៣:៥១]

**ឆ៖** សូមអរគុណមេធាវី ។ អ្វីដែលជាចំណុចសំខាន់ដែលខ្ញុំត្រូវធ្វើនៅកាលនោះ គឺមានប្រព័ន្ធដែលគេកំណត់ជាទូទៅមួយដែលគ្របដណ្តប់លើប្រទេសទាំងមូល ហើយផ្អែកតាមព័ត៌មានជាមូលដ្ឋានដែលយើងប្រមូលបាននោះ ។ ខ្ញុំសូមបញ្ជាក់ឡើងវិញនៅទីនេះ យើងត្រូវតែមានការប្រុងប្រយ័ត្នស្ថិតិអំពីអំពើភ័យរន្ធត់នោះ គឺជាស្ថិតិដែលថាវាមានភាពផុយស្រួយ ។ យើងមិនមានអ្វីក្រៅពីឆ្អឹង ឬក៏អដ្ឋិធាតុនៅតាមរណ្តៅនៅក្នុងមន្ទីរសន្តិសុខផ្សេងៗនោះទេ ប៉ុន្តែយើងមិនមានអ្វីនៅសល់ក្រៅពីហ្នឹងទេ ។ ប៉ុន្តែជាសំខាន់នៅទីនេះ គឺយើងពិនិត្យមើលអ្វីជាលក្ខណៈពិសេសនៃអត្តនោម័តិ កត្តាអត្តនោម័តិរបស់ស-២១ នោះគឺយើងអាចបញ្ជាក់ថា យើងមានជនរងគ្រោះជាច្រើនគឺជាងមួយម៉ឺននាក់ ដែលថាវាច្រើនជាងកត្តាមួយ ។ អ៊ីចឹងគឺថាមានមន្ទីរសន្តិសុខប្រាំបួនផ្សេងទៀតក៏មានមនុស្សស្លាប់ច្រើនជាងស-២១ ។ ប៉ុន្តែមិនមែននរណាម្នាក់ដែលទទួលខុសត្រូវនៅកន្លែងទាំងនោះបានមកប្រឈមមុខចំពោះតុលាការនេះទេ ។ អ៊ីចឹង ហើយដោយការគោរពចំពោះអង្គជំនុំជម្រះ តុលាការនេះ ទស្សនៈយុត្តិធម៌ក្នុងន័យរបស់ខ្ញុំនោះ គឺមិនត្រូវទម្លាក់កំហុសទៅលើនរណាម្នាក់ដែលត្រូវទទួលថ្នបាក់នោះទេ គឺបើសិនជាចង់បញ្ជាក់ឲ្យខ្ញុំប្រាប់ឈ្មោះនោះ ហើយកុំសួរខ្ញុំ ថាតើអ្នកនោះត្រូវធ្វើអ្វី មិនត្រូវធ្វើអ្វីនោះ ។ ប៉ុន្តែ យើងត្រូវកត់សម្គាល់ថាមន្ទីរសន្តិសុខប្រាំបួនផ្សេងទៀតដែលថាមានមនុស្សស្លាប់ច្រើនជាង មានទារុណកម្មច្រើនជាងស-២១ ហើយប្រធានមន្ទីរសន្តិសុខទាំងអស់នោះនៅរស់នៅឡើយ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ចំណុចនេះជូនអង្គជំនុំជម្រះ ។

**ស៖** អរគុណលោកបណ្ឌិត ។ សំណួរដែលខ្ញុំចង់ដឹង ខ្ញុំចង់សួរលោកបណ្ឌិតមិនមែនត្រង់ហ្នឹងទេ ។ ខ្ញុំចង់សួរថា មន្ទីរសន្តិសុខទាំង១៩៦ នៅក្នុងរបាយការណ៍របស់ *ឌីស៊ីខេម* ក្តី នៅក្នុងរបាយការណ៍របស់លោកបណ្ឌិតក្តី គឺមានតួលេខតែ៦៤ មន្ទីរសន្តិសុខទេ ដែលមានមនុស្សស្លាប់ ។ ឯ១៣២ មន្ទីរសន្តិសុខ គឺគ្មានតួលេខសោះ ។

អ៊ីចឹងដែលខ្ញុំចង់សួរលោកបណ្ឌិតថា តើដប់មន្ទីរសន្តិសុខនេះ វាជាតួលេខដែលថាច្រើន-- ដែលថាវាលើសគេហ្នឹងក្នុងចំណោម៦៤គុក ដែលមានតួលេខនេះឬទេ? ខ្ញុំចង់សួរត្រង់ហ្នឹង ។

**ឆ៖** ចម្លើយរបស់ខ្ញុំ "បាទ" ។ នៅក្នុងរបាយការណ៍សិក្សារបស់ខ្ញុំ ខ្ញុំនិយាយ មិននិយាយអ្វីឲ្យបានច្រើននូវមន្ទីរសន្តិសុខផ្សេងទៀត ពីព្រោះថា ខ្ញុំរកឃើញពីចំណុចមួយចំនួននៅក្នុងការស្រាវជ្រាវនោះ ឃើញថាវាមានបាតុភាពអាក្រក់ ក៏ប៉ុន្តែមិនមានភស្តុតាងអ្វីឲ្យគ្រប់គ្រាន់បញ្ជាក់ ។ ដូច្នេះ នៅក្នុងស្ថិតិ ចំពោះចំនួនមនុស្សស្លាប់ច្រើនជាងគេបំផុតនៅក្នុងមន្ទីរសន្តិសុខនីមួយៗ ។ ប៉ុន្តែ តាមទស្សនៈខ្ញុំនៅក្នុងកន្លែងខ្លះ គឺថា គឺយើងមិនទាន់បានពិនិត្យពិច្ច័យឲ្យបានច្បាស់លាស់ពីចំនួនស្ថិតិនោះទេ ។ ប៉ុន្តែ ខ្ញុំមិននិយាយអ្វីដែលជាអរូបិយនោះទេ ពីព្រោះខ្ញុំត្រូវតែគោរពវិញ្ញាណក្ខន្ធ ឬក៏ជនរងគ្រោះទាំងអស់ ។ ខ្ញុំមិនអាចនិយាយក្នុងលក្ខណៈស្រពិចស្រពិលអំពីចំនួនមន្ទីរសន្តិសុខ៦៤ ដែលលោកលើកឡើងនោះទេ ។

[១៥:៣៨:២២]

**ស៖** សូមអរគុណលោកបណ្ឌិត ។ ខ្ញុំបាទសូមសួរក្នុងរបាយការណ៍ដដែល ដែលខ្ញុំអានអំមិញហ្នឹង លោកបណ្ឌិតថា ប្រធានមន្ទីរសន្តិសុខទាំងដប់ដែលតួលេខមាន ដែលខ្ញុំជម្រាបអំមិញ មានតែ៦៤ហ្នឹង អាចចូលទៅក្នុងប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភច្បាប់ជាតិ និងអន្តរជាតិអ៊ីចឹងចុះ ។

ខ្ញុំសួរលោកបណ្ឌិតថា នៅក្នុងរបាយការណ៍លោកបណ្ឌិតក៏បាននិយាយដែរថាលិខិតចុះថ្ងៃទី៣០ ខែ៣ ១៩៧៦ ដែលគណៈអចិន្ត្រៃយ៍មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ប្រគល់សិទ្ធិឲ្យមនុស្សបួនក្រុមដែលមានសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ ។ អ៊ីចឹងទាំងអស់ហ្នឹង ទាំងពីរហ្នឹង ខ្ញុំសុំសួរលោកបណ្ឌិតថា តើមនុស្សបួនក្រុម ឧទាហរណ៍ដែលនៅក្នុងហ្នឹងគេថា នៅក្នុងភូមិភាគ គឺលេខាភូមិភាគ ជាអ្នកមានសិទ្ធិសម្រេចកម្ទេចអ្នកណាទុកអ្នកណា គឺស្រេចតែលេខាភូមិភាគ ។ ដល់មកក្នុងមន្ទីរជុំវិញមជ្ឈិម គឺលេខាមន្ទីរ៨៧០ ជាអ្នកមានសិទ្ធិសម្រេចសម្លាប់អ្នកណា ឬក៏មិនសម្លាប់អ្នកណា ។ ដល់មកតំបន់ឯករាជ្យ គឺប្រគល់ឲ្យ គឺលេខា គឺមជ្ឈិមបក្សខ្លួនឯងអ្នកសម្រេច ។ ដល់ទៅក្នុងជួរកងទ័ពមជ្ឈិម គឺអគ្គសេនាធិការ

គឺ សុន សេន ជាអ្នកសម្រេច ។ អ៊ីចឹង ខ្ញុំសូមសួរលោកបណ្ឌិតថា តើមនុស្សប្អូនក្រុមហ្នឹង តើជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភច្បាប់ជាតិ និងអន្តរជាតិឬទេ? ពីព្រោះមជ្ឈិមបក្សបានកំណត់ថា អ្នកឯងប្អូនក្រុមហ្នឹងមានសិទ្ធិសម្រេចទូទាំងប្រទេស កន្លែងណាគឺថាលេខាកន្លែងនោះ គឺមានថាអ្នកមានសិទ្ធិសម្រេច ។ អ៊ីចឹងដែលខ្ញុំសុំសួរហ្នឹងថា តើប្អូនក្រុមហ្នឹង វាជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះឬទេ? បាទសំណួរមានតែប៉ុណ្ណឹងទេ ។ សូមអរគុណ ។

**ឆ៖** លោកមេធាវី ខ្ញុំក៏ចង់សួរសំណួរទៅលោកវិញ។ តើមានការបន្ទាបនៃភាពធ្ងន់ធ្ងរនៃបទល្មើសដែលបានចោទដែលកើតឡើងទេ? ដែលថាប្រធានគុកនៅភ្នំពេញ កំពង់ចាម ឬក្រចេះនោះ ចម្លើយរបស់ខ្ញុំឆ្លើយថា "មែន" ។ ប្រធាននៃមន្ទីរសន្តិសុខទាំងអស់ហ្នឹង មិនដោយសារថា គេនៅតាមខេត្ត ថាការទទួលខុសត្រូវរបស់គេត្រូវរលត់នោះទេ ។ គេក៏ត្រូវតែរងការចោទប្រកាន់ស្រដៀងគ្នានេះដែរ ។

**ស៖** សូមអរគុណលោកបណ្ឌិត ។ ប៉ុន្តែ លោកបណ្ឌិតឆ្លើយវាហាក់ដូចជាមិនចំសំណួរដែលខ្ញុំចង់ដឹង ។ ខ្ញុំចង់ដឹងថា នៅក្នុងរបាយការណ៍របស់លោកបណ្ឌិត លោកបណ្ឌិតបានបញ្ជាក់ច្បាស់ថាប្រធាន គុកទាំងដប់នេះ អាចចូលជាជនដែលទទួលខុសត្រូវខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភផ្សេងៗអ៊ីចឹងទៅ ។ អ៊ីចឹង ខ្ញុំសូមសួរលោកវេជ្ជបណ្ឌិតថា អ៊ីចឹងមនុស្សប្អូនក្រុម ដែលអចិន្ត្រៃយ៍មជ្ឈិមបក្ស បានប្រគល់សិទ្ធិទៅឱ្យប្អូនក្រុមហ្នឹង អ្នកឯងមានសិទ្ធិសម្រេចកម្ទេចអ្នកណា ទុកអ្នកណាស្រេចតែអ្នកឯង ។ អ៊ីចឹង ខ្ញុំចង់សួរលោកបណ្ឌិតថា តើប្អូនក្រុមហ្នឹង ជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភទាំងអស់នោះឬទេ? សូមអរគុណ ។

**ឆ៖** ប្រសិនបើខ្ញុំយល់សំណួររបស់លោកត្រឹមត្រូវនោះ លោកមេធាវី ។ ប្រសិនជាខ្ញុំនឹកឃើញនិយាយពីច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនិងតាមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ហើយនិងកិច្ចព្រមព្រៀងរវាងសហប្រជាជាតិនិងកម្ពុជានោះ គឺមានមនុស្សពីរប្រភេទ គឺមេដឹកនាំជាន់ខ្ពស់ ហើយនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដែលបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយនិងច្បាប់មួយចំនួន ។ អ៊ីចឹងហើយអ្នកទាំងនោះ គឺស្ថិតនៅក្រុមទីពីរ ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលមានចែងដោយច្បាប់ ហើយនិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនោះ តើលោកជ្រាបឬទេ ។

**ស៖** បាទ, សូមអរគុណ ។ ខ្ញុំបានស្តាប់សំណួរ-- ចម្លើយរបស់លោកបណ្ឌិតចុងក្រោយនេះថាជន ប្អូនក្រុមនេះ ក៏ស្ថិតនៅក្នុងចំណោមពួកក្រុមទីពីរ គឺជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត

ចំពោះឧក្រិដ្ឋកម្មហ្នឹងហើយ ។ សូមអរគុណ ។ ហើយខ្ញុំបាទ សូមសួរលោកបណ្ឌិតមួយកូនសំណួរតូចមួយទៀតចុះ ។

សំណួរនេះ ដោយកាលពីឆ្នាំ ប្រហែលជាចុងឆ្នាំ២០០៧ ឬក៏ដើមឆ្នាំ២០០៨ ខ្ញុំបាទបានជួបលោកបណ្ឌិត ហើយបានខ្ញុំបានជម្រាបលោកបណ្ឌិតថា របាយការណ៍ទាំងអស់របស់ *ឌីស៊ីខេម* ក៏ជានៅក្នុងរបាយការណ៍របស់លោកបណ្ឌិត គឺស្រាវជ្រាវពីគុកនេះ គឺនៅខ្វះស្រុកបាភ្នំ ក្នុងខេត្តព្រៃវែង ស្រុកបាភ្នំ ខេត្តព្រៃវែង មានគុកច្រើនដែរ ប៉ុន្តែអត់ឃើញនិយាយក្នុងហ្នឹងសោះ ។ ក្នុងខេត្តព្រៃវែង លោកនិយាយតែពី ស្រុកកំចាយមា ស្រុកកំពង់ត្របែក ស្រុកកញ្ជ្រៀច ស្រុកមេសាង ស្រុកពាមជរ ស្រុកពារាំង ស្រុកព្រះស្តេច ស្រុកព្រៃវែង ស្រុកស៊ីធរកណ្តាល គឺបាត់ស្រុកបាភ្នំទាំងមូល ។ ហើយស្រុកបាភ្នំគ្រាន់តែខ្ញុំដឹង ដែលខ្ញុំធ្លាប់ជាប់គុកនៅកន្លែងនោះ គឺគុកជ្រួល នៅខាងកើតបាភ្នំ និងគុកដែលធំជាងគេតំបន់២៤ហ្នឹង គឺនៅលើកំពូលភ្នំឈើកាច់ ហើយលោកមេខ្មែរក្រហមធំៗជាច្រើនដែលចាប់មក ជួបខ្ញុំនៅតំបន់២៤ហ្នឹង គុកហ្នឹង គឺខ្ញុំឃើញឈ្មោះស្លាប់នៅស-២១ ទាំងអស់ ។

ដូច្នេះ តើលោកបណ្ឌិតបានស្រាវជ្រាវគុក នៅស្រុកបាភ្នំបញ្ចូលថែមហើយឬនៅ? ខ្ញុំចង់ប៉ុណ្ណឹងទេ ។ សូមអរគុណ ។

[១៥:៤៥:៣៥]

**ឆ៖** ខ្ញុំមិនបានធ្វើការសិក្សាស្រាវជ្រាវអ្វីបន្ថែមលើសពីហ្នឹងទៀតទេ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកបណ្ឌិត ហើយសូមអនុញ្ញាតពីតុលាការឲ្យលោកមេធាវីការពារក្តីអន្តរជាតិសួរម្តង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

**ស៖** សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក ចេនណា។ ខ្ញុំមានសំណួរមួយចំនួនតូចទៀតសម្រាប់លោក។ សូមអរគុណចំពោះការចូលរួម លះបង់ពេលវេលារបស់លោក ។ លោកប្រធានដំបូងខ្ញុំសូមអនុញ្ញាតលើកនូវការចាប់អារម្មណ៍ខាងសហព្រះរាជអាជ្ញា ដែលថាមេធាវីការពារ ដូចដែលលោកមិនបានដឹងទេ យើងបានរៀបចំបញ្ជីឯកសារនៅ D80 ដែលរាប់បញ្ចូលទាំងឯកសារបី ដែលមាន

D88 មួយ , D89 ហើយនិង D80.10 ដែលជាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

លោក ចេនណា, មេធាវីការពារបានដាក់ជូននូវឯកសារទាំងនេះ ។ សូមអភ័យទោស ដែលថា ខ្ញុំអានឈ្មោះ មិនត្រូវ គឺឯកសារបី ដែលមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ហើយខ្ញុំសូម ចង់ដឹងថា តើលោកបានមានឱកាសពិនិត្យនូវឯកសារទាំងនេះដែរឬទេ? ឯកសារទីមួយ D80/40 ហើយនៅក្នុង ភាសាបារាំង គឺ 1975 ដល់ 1979 នេះជាឯកសារមួយ ។ ឯកសារទីពីរ D80/9 (1972 ដល់ 1977) 1990 គឺអំពីរណ្តៅសាកសពរួម ឆ្នាំ១៩៧៩ គឺជាកម្មវិធីយ៉េល ដែលសិក្សាអំពីអំពើប្រល័យពូជសាសន៍ នៅកម្ពុជា ។ លោកអាចមើលឯកសាររបស់សាកលវិទ្យាល័យយ៉េល នៅក្នុងវេបសាយ ។

ឯកសារទីបី ការកំណត់ផែនទីវាលពិឃាដឆ្នាំ១៩៧៥ ដល់ ១៩៧៩ *ឌីស៊ីខេម* ឆ្នាំ២០០១ ក្នុង ភាសាអង់គ្លេសនិងខ្មែរ ។ លោកអ្នកជំនាញតាមដែលលោកចងចាំច្បាស់ តើឯកសារទាំងនេះស្ថិតនៅ ក្នុងចំណោមឯកសារ ដែលលោកបានឃើញនៅក្នុងការិយាល័យឯកសារកម្ពុជានោះដែរឬទេ?

**ឆ៖** សូមអរគុណលោកមេធាវី ។ ខ្ញុំមានចម្លើយខ្លីមួយ ។ ជាក់ស្តែងគឺលោកបានយោងយ៉ាង លម្អិតទៅលើឯកសារហ្នឹង ហើយលោកបានដឹងច្បាស់ហើយថា មុន-- ដែលថានៅកន្លែងមជ្ឈមណ្ឌល ឯកសារកម្ពុជា គឺមិនធ្លាប់ធ្វើការនៅកន្លែងផ្សេងទៀតនោះទេ គឺខ្ញុំបានដឹងពីមុនហ្នឹងច្រើនមក ហើយ អ៊ីចឹងខ្ញុំដឹងច្បាស់ ។

[១៥:៥០:00]

**សៈ** ខ្ញុំសូមចង្អុលជម្រាបអង្គជំនុំជម្រះថា ឯកសារនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ យើង បាន ដាក់ជូនឯកសារនេះនៅ D80 ជាមួយសហចៅក្រមស៊ើបអង្កេត ។ តាមពិតសហសេវិករបស់ខ្ញុំនៅខាង សហព្រះរាជអាជ្ញានោះ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបានដឹងច្បាស់ថាមានឯកសារនេះហើយ។ ខ្ញុំ សូមដាក់ជូនឯកសារនេះដើម្បីជាភស្តុតាងនៅក្នុងសំណុំរឿង ហើយនិងដាក់ដេញដោលចំពោះមុខតុលាការ ដើម្បីចាត់ទុកជាភស្តុតាង ។

លោក ចេនណា សាក្សីជាច្រើនបានមកផ្តល់សក្ខីកម្មមុនលោក ដោយរាប់បញ្ចូលទាំងអ្នកដែល លោកស្គាល់ច្បាស់ផងដែរ គាត់ជាអ្នកស្រាវជ្រាវដូចលោកដែរ គឺលោក ក្រេក អេតធេសាន់ ។ ខ្ញុំគិតថា លោកបានដឹងថាមាន ឬក៏បានឃើញរបាយការណ៍លាយលក្ខណ៍អក្សររបស់លោក ក្រេក អេតធេសាន់ នៅក្នុងសំណុំរឿង ឬក៏លោកមិនបានដឹងថា លោក អេតធេសាន់ គាត់បានផ្តល់ជារបាយការណ៍ហើយ ហើយគាត់បានបញ្ជាក់ពីសក្ខីកម្មខ្លះដែលផ្ទុយនៅក្នុងគំនិតរបាយការណ៍របស់ខ្លួន ។ នៅពេលដែលមាន

ចំណុចខ្វែងនោះ គឺថាយើងមានការតវ៉ាទៅនឹងសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ នៅពេលដែលជនជាប់ចោទនិយាយថា គាត់ទទួលការសម្ភាសន៍ប្រចាំថ្ងៃ ឬក៏ជួបជាមួយ សុន សេន ប្រចាំថ្ងៃ ឬក៏ការប្រាស្រ័យទាក់ទងរាល់ថ្ងៃជាមួយ សុន សេន ហើយ សុន សេន ប្រាប់មកគាត់ថា គាត់ត្រូវតែធ្វើតាម ។ ប៉ុន្តែ ជនជាប់ចោទបានប្រាប់តុលាការថា សុន សេន ជាអ្នកតាមដានការងារប្រចាំថ្ងៃ សកម្មភាពប្រចាំថ្ងៃរបស់ស-២១ ហើយតម្រូវឲ្យមានរបាយការណ៍ប្រចាំថ្ងៃពីអ្វីដែលបានកើតឡើងនៅស-២១ ហើយក្នុងករណីភាគច្រើនរបាយការណ៍នោះត្រូវតែបញ្ជូនតាមទូរស័ព្ទ ។

ប៉ុន្តែលោក គ្រេក អេតធេសាន់ និយាយថាលោក សុន សេន មានការរវល់ខ្លាំង ហើយខ្ញុំមានការសង្ស័យថា តើគាត់មានលទ្ធភាពផ្ដោតអារម្មណ៍ទៅលើស-២១ ជារៀងរាល់ថ្ងៃដែរឬអត់នោះទេ?

នៅព្រឹកមិញនេះ គឺពាក់ព័ន្ធទៅនឹងខ្សែបញ្ជាអំណាចនោះ គឺថាលោកបានប្រាប់អង្គជំនុំជម្រះថា សុន សេន នោះជានរណា? នៅពេលចំណុចនេះ តើជនជាប់ចោទ? សេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ អាចជាកត្តាជំទាស់តវ៉ាទៅនឹងជំនឿរបស់លោកគ្រេក អេតធេសាន់ ដែរឬទេ? ពីព្រោះថាយើងដឹងច្បាស់ពីខ្សែបញ្ជានៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែផ្ទុយទៅវិញជនជាប់ចោទ គាត់មានសេចក្ដីថ្លែងការណ៍បញ្ជាក់ពីចំណុចនេះថា ជាកត្តាសំខាន់ ។

[១៥:៥៣:១៣]

**ឆ៖** លោកមេធាវី លោក សុន សេន គឺគាត់មានការរវល់ច្រើនអំពីភារកិច្ចរបស់គាត់ ។ ប៉ុន្តែក្នុងចំណុចការងារនោះ គឺថា គាត់ជាមនុស្សម្នាក់ដែលទទួលខុសត្រូវមកនយោបាយសន្តិសុខ ហើយក៏គាត់អាចឆ្លើយទាក់ទងទៅនឹងសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ ប៉ុន្តែ ហើយយើងមិនអាចឃើញអំពី--រកឃើញរបាយការណ៍ណាដែលនិយាយអំពីទូរស័ព្ទទាក់ទងពី សុន សេន មកជនជាប់ចោទទេ ។ ប៉ុន្តែវានៅក្នុងការទទួលខុសត្រូវរបស់លោក សុន សេន ការងារនោះ ។ គឺក្នុងស្នូលនៃអំណាចរបស់កម្ពុជាប្រជាធិបតេយ្យក្នុងវិស័យសន្តិសុខ ។ អ៊ីចឹងគឺថាយើងអាចពិចារណាថា គាត់មានតួនាទីមួយរបស់គាត់ត្រូវទទួលបន្ទុកកិច្ចការសន្តិសុខ ដែលថាផ្ទាល់ពីគាត់ទៅខាងគណៈអចិន្ត្រៃយ៍ ។ អ៊ីចឹងហើយយើងត្រូវខ្ញុំចាត់ទុកថានៅក្នុងគំនិតនេះ ព័ត៌មានដែលជនជាប់ចោទផ្ដល់ទៅឲ្យនោះ គឺមានកម្រិតនៃការជឿជាក់នោះកម្រិតខ្ពស់ ។

**សៈ** លោកបាននិយាយអំពីការងារតាមដាន ពិនិត្យដែលធ្វើឡើងដោយ សុន សេន ដែលត្រូវធ្វើរបាយការណ៍ទៅឲ្យគណៈអចិន្ត្រៃយ៍របស់បក្ស តើលោកឯកភាពឬទេថា នេះជាចរិតលក្ខណៈពិសេស

របស់ស-២១ ដែលថាជនជាប់ចោទគាត់បាននិយាយថា គឺជាការងារប្រចាំថ្ងៃ ការតាមដានប្រចាំថ្ងៃ ដោយគណៈអចិន្ត្រៃយ៍ គឺនេះមិនមែនកើតឡើងចំពោះមន្ទីរសន្តិសុខផ្សេងៗទៀតទេ។ តើវាមិនមានជាការពាក់ព័ន្ធទៅនឹងការតាមដាន ឬត្រួតពិនិត្យជាអចិន្ត្រៃយ៍របស់គណៈអចិន្ត្រៃយ៍នោះ?

**ឆ៖** យើងត្រូវតែចាំពីការព្រួយបារម្ភរបស់មេដឹកនាំ អំពីក្រុមតូចដែលថាមានប្រាំពីរនាក់ដែលដឹកនាំបក្សកុម្មុយនីស្តកម្ពុជានោះ គឺគេមានការភ័យខ្លាចអំពីសត្រូវ ឬក៏ខ្មាំងផ្ទៃក្នុង ដែលថាជា-- គេបង្កើតជាស្ថាប័នស-២១ គឺថាលោកមេធាវី ខ្ញុំឯកភាពជាមួយលោក គឺថាជាការភ័យខ្លាច ការព្រួយបារម្ភជាប្រចាំរបស់ក្រុមអ្នកដឹកនាំនោះ ។ ដូចដែលបានបញ្ជាក់នៅក្នុងឱកាសមួយចំនួន ជាពិសេសចំពោះមនុស្សដែលគេបាននាំយកទៅស-២១ នោះ ។ ដូចដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះគឺថា មានទំនាក់ទំនងជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ គឺថា៨០ភាគរយអ្នកទាំងនោះ គឺមនុស្សទាំងអស់នោះគឺនៅក្នុងកម្រិតជាកម្មាភិបាល ឬក៏ជួរអ្នកបម្រើការឲ្យគេនោះ ។ ដូច្នេះហើយនៅមន្ទីរសន្តិសុខផ្សេងទៀត ហើយនិងគណៈអចិន្ត្រៃយ៍ ជាពិសេសគឺថាមានការយកចិត្តទុកដាក់ពាក់ព័ន្ធទៅនឹងការងាររបស់ស-២១ ។ ជាពិសេសគឺថា សមាជិកខ្លះនៃគណៈអចិន្ត្រៃយ៍ក៏បានបញ្ចប់ជីវិតនៅទីនោះដែរ ។

[១៥:៥៧:២៤]

**ស៖** តើលោកឯកភាពជាមួយខ្ញុំទេដែលនិយាយថា ភាពជិតស្និទ្ធបែបនេះ គឺភាពជិតស្និទ្ធទៅនឹងគណៈអចិន្ត្រៃយ៍អាចធ្វើឲ្យ ឌុច មិនមានលទ្ធភាពនឹងងាកឆ្ងាយចេញបាន? នេះគឺថាវាខុសពីមជ្ឈមណ្ឌលផ្សេងៗទៀតដែលវានៅឆ្ងាយប្រហែលជា ដូចថាប្រធានមន្ទីរនោះ គឺមានលទ្ធភាពអាចនឹងងាកចេញ ឬក៏កិច្ចការអ្វីតាមចិត្តរបស់គេបានខ្លះ ។ ដូច្នេះ អ្វីជាតំណាងទីតាំងមួយដែលថាបង្ហាញថា ខ្សែរយៈនៃការបញ្ជាហ្នឹង គឺដោយសារតែ ឌុច ហ្នឹងនៅជិតពេកទៅនឹងគណៈអចិន្ត្រៃយ៍ ដូច្នេះហើយ ឌុច មិនមានច្រកណាងាកចេញពីការបញ្ជាហ្នឹងបានទាល់តែសោះ តើអ៊ីចឹងឬទេ?

**ឆ៖** លោកមេធាវី ខ្ញុំដូចជាមិនចង់បញ្ជាក់លោកវិញទេ គឺថានៅក្នុងភ្នំពេញគឺថា មិនមាននរណាម្នាក់មិនអាចមានសិទ្ធិងាកចេញ ពីព្រោះកន្លែងខ្លះគឺថាមានការខ្វះអំណាច ប៉ុន្តែបើសិនជាគេនៅឆ្ងាយ-- ប៉ុន្តែ នៅក្នុងប្រព័ន្ធមួយដូចជារបបខ្មែរក្រហមហ្នឹង គឺជាការរុញមនុស្សឲ្យទៅដល់កម្រិតមួយដែលថាមានការសង្ស័យមិនចេះចប់មិនចេះហើយ គឺថាមិនមានពាក្យអីដែលថាសមស្របនឹងប្រើទេ គឺដែលយើងហៅថា ជាស្ថានភាពខ្លាចដូចជាសត្វត្រដេវិច ដូច្នោះគឺអ្វីក៏ខ្លាចដោយគ្មានមូលហេតុនោះឯង ។

**ស៖** លោក អេតធេសាន់ បានមកផ្ដល់សក្ខីកម្មនៅក្នុងតុលាការនេះ ហើយគាត់បានលើកឡើងថាគាត់ចាត់ទុក ឌុច គាត់ជាអ្នកមានសេចក្ដីសម្រេច ហើយគាត់មានស្វ័យភាពស្ថិតនៅក្នុងជំហរក្នុងការផ្ដួចគំនិតមួយចំនួន ថាតើលោកយល់យ៉ាងម៉េចចំពោះការលើកឡើងដូច្នេះ? ថាតើលោក ឌុច ហ្នឹងមានអំណាចស្វយ័តខ្លួនឯងក្នុងការសម្រេចដែរឬទេ?

**ឆ៖** ប្រសិនបើយើងមិនមានអំណាចគ្រប់គ្រាន់-- មានអំណាចគ្រប់គ្រាន់តិចតួចហើយនោះ ដូច្នេះហើយយើងមិនមានអំណាចស្វយ័តនោះទេ ។ ដូច្នេះហើយការដែលធ្វើចំណារនោះ ក៏គាត់បានស្នើទៅលើមេរបស់គាត់។ បានន័យថា ប្រសិនបើគាត់មានអំណាចស្វយ័តនោះ គឺគាត់មិនចាំបាច់ធ្វើការចារដើម្បីធ្វើការប្រឹក្សាជាមួយមេរបស់គាត់នោះទេ ។ ដូច្នេះហើយនៅក្នុងបរិបទនៃស-២១នេះ គឺជនរងគ្រោះ ឬក៏អ្នកទោសនោះគឺជីវិតរបស់គាត់ពឹងផ្អែកទៅលើគណៈអចិន្ត្រៃយ៍ ។ ដូច្នេះហើយគឺយើងអាចពិចារណាទៅលើអ្វីដែលយើងមាននៅទីនេះ គឺវាមានលទ្ធភាពដែលថា បុគ្គលគាត់អាចមានជំហរក្នុងការផ្ដួចផ្ដើមទៅលើកិច្ចការមួយចំនួន ហើយខ្ញុំដឹងអំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាដែលជំរុញឲ្យសមាជិកសមាជិកាមានគំនិតផ្ដួចផ្ដើមនិងមានលក្ខណៈសកម្ម ។ ដូច្នេះប្រសិនបើយើងមើលទៅលើលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យបានហ្មត់ចត់នោះ គឺយើងឃើញមានការលើកឡើងអំពីវណ្ណៈអធនអន្តរជាតិ ។

[១៦:០១:៤១]

ដូច្នេះហើយ យើងអាច នៅពេលដែលយើងសង្កេតទៅលើចំណុចហ្នឹង យើងអាចមើលឃើញអំពីការលើកឡើងអំពីវណ្ណៈអធនអន្តរជាតិ ។ ដូច្នេះហើយលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា គឺវាដូចទៅនឹងលក្ខន្តិកៈរបស់ខាងសហភាពសូវៀត ហើយយើងឃើញភាពជាក់ស្ដែងវាកើតចេញដូចមានចែងនៅក្នុងលក្ខន្តិកៈនោះដែរ ។

**ស៖** សូមលោកកែតម្រូវខ្ញុំប្រសិនបើខ្ញុំលើកឡើងខុស ។ ការបង្កើតកែឆ្នៃនេះ គឺត្រូវអនុវត្តឲ្យស្របទៅតាមបក្ស តើត្រឹមត្រូវដែរឬទេ? គឺឲ្យត្រូវទៅតាមមាគ៌ាបក្ស តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មាគ៌ាបក្ស គឺជាអ្វីដែលគេផ្អែកទៅលើ ហើយគេមិនត្រូវដើរងាកចេញឲ្យឆ្ងាយពីមាគ៌ាបក្សនោះទេ ហើយអ្នកដែលជាសមាជិកនោះ គឺគាត់ត្រូវដើរទៅតាមមាគ៌ាបក្សទាំងអស់នោះ ។

**ស៖** ខ្ញុំដឹងថា លោកយល់ហើយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានផ្ដោតនិងនិយាយ ហើយដាក់ភាពចាំបាច់ និងសារសំខាន់របស់មន្ទីរស-២១ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវចំពោះអង្គហេតុ ដែលដាក់បន្ទុកលើគាត់ ។ ដូច្នេះហើយវាជាចំណុចមួយសំខាន់ចំពោះមន្ទីរនោះ

ហើយលោកក៏បានយល់ស្របដែរ ឌុច មិនមែនជាមេបញ្ជាការយោធាទេ ហើយនៅក្នុងឋានានុក្រម គឺគាត់បានបញ្ជាក់ទៅលើចំណុចនេះផងដែរ ហើយយើងមិនមានរកឃើញដានណាមួយនៅក្នុងឯកសារដែលថាគាត់មានតួនាទីសំខាន់នៅក្នុងឋានានុក្រម ហើយគាត់ក៏បានកំណត់ខ្លួនឯង ហើយបានលើកឡើងថាគាត់គ្រាន់តែជាប៊ែកហ្សេរបស់បក្សតែប៉ុណ្ណោះ ដែលវាមានងារកៀកទៅនឹងមេបញ្ជាការ ។ ដូច្នេះហើយខ្ញុំអាចចាត់ទុកថាវាពិតជាដូច្នោះដែរឬទេ?

**ឆ៖** លោកមេធាវី, ប្រសិនបើខ្ញុំនិយាយថាមែន គឺខ្ញុំសូម ខ្ញុំនិយាយនេះដោយគោរព សូម្បីតែសត្វឆ្កែក៏ខ្ញុំគោរពដែរ ជាពិសេសគឺក្នុងតួនាទីរបស់ជនជាប់ចោទ ហើយគឺថា ប៊ែកហ្សេដ៏មានភក្ដីភាពគឺវាជាអ្វីដែលគាត់បានលើកឡើង ហើយមន្ទីរនោះគឺជាមន្ទីរដែលសំខាន់ ។ យើងមិនអាចបដិសេធទេថាមន្ទីរស-២១គឺជាមន្ទីរសំខាន់ ហើយវាមានតួនាទី ដែលថាបុគ្គលមួយចំនួនដែលគាត់ឆ្លងកាត់មន្ទីរនេះគាត់ស្លាប់យ៉ាងមានភាពតក់ស្លុត ។ ដូច្នេះ គឺបុគ្គលិកលក្ខណៈរបស់របបកម្ពុជាប្រជាធិបតេយ្យវាអាចឆ្លុះបញ្ចាំងទៅលើចំណុចនេះ ។

ហើយនៅព្រឹកមិញនេះ នៅពេលដែលខ្ញុំលើកឡើងអំពីការកើតឡើងនៅក្នុងប្រទេសសហភាពសូវៀត មិនមាននរណាម្នាក់ស្ថិតនៅក្នុងសុវត្ថិភាពនោះឡើយ ក្រៅពីអ្នកដែលធ្វើសេចក្ដីសម្រេចតែប៉ុណ្ណោះ។ អ្នកដែលគាត់អនុវត្តទៅតាមសេចក្ដីសម្រេច ទោះបីមានភាពខ្ទៀវក្លាក៏ដោយ ក៏គាត់ត្រូវមានការប្រុងប្រយ័ត្នដើម្បីចៀសឲ្យផុតពីការដាក់ខ្លួនឯងចូលទៅក្នុងក្រុមអ្នកដែលត្រូវបានគេទៅសម្លាប់ចោល ។

**ស៖** លោក វ៉ាអ៊ួល ម៉ាចេនណា, បុគ្គលជាច្រើននៅក្នុងអង្គជំនុំជម្រះនេះ គឺបានលើកឡើងអំពីករណី ឌុច ដែលគាត់មិនបានបោះបង់ការងាររបស់គាត់ចោល វាជាបញ្ហាមួយដែលលើកឡើងច្រើន ។ ហើយខ្ញុំគិតថា ចំណុចនេះនឹងលើកឡើងសាជាថ្មីនៅក្នុងការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងភាគីអំពីជំហររបស់គាត់តាមអ្វីដែលលោកដឹងនៅក្នុងរបបនុំង ។

តើលោកអាចជម្រាបយើងអំពីលទ្ធភាពយ៉ាងម៉េចដែលបុគ្គលម្នាក់គាត់អាចធ្វើការលាលែងតំណែងរបស់គាត់ ឬក៏រត់ចោលតំណែងរបស់គាត់? តើលោកអាចជម្រាបយើងយ៉ាងម៉េចទៅលើករណីនេះ?

**ឆ៖** សហព្រះរាជអាជ្ញា, មុននឹងបានរំឭកថា ការងាររបស់ខ្ញុំ គឺផ្ដោតទៅនឹងការងាររបស់ខ្ញុំ ។ ហើយខ្ញុំចាត់ដូចថា មានការលើកឡើងអំពីការចាត់ចែងដើម្បីរត់គេចពីការងារនឹងរបបផ្សេងៗនិងប្រទេស

វៀតណាម ។ ដូច្នេះ ហើយវាមានភាពងាយស្រួលដែលថា យើងអាចរត់ចេញពីប្រទេសកម្ពុជាពេលដែលយើងនៅកៀកហ្នឹងព្រំដែនវៀតណាម ។ ប៉ុន្តែចំណុចនេះ វាមានការពិបាកដោយសារតែវាមានការរារាំងចំពោះបុគ្គល ដែលគាត់ស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅក្នុងការធ្វើដំណើរនៅក្នុងប្រទេសរបស់ខ្លួន បុគ្គលទាំងឡាយ គឺគាត់មិនអាចដើរហើរហួសពីដែនកំណត់របស់ខ្លួននោះទេ ។ អ្នកដែលមានសិទ្ធរស់នៅៗក្នុងភ្នំពេញ គឺមានសិទ្ធនឹងរស់នៅដើរហើរនៅក្នុងក្រុងភ្នំពេញ ហើយអ្នកដែលនៅភូមិភាគគាត់មានសិទ្ធតែក្នុងភូមិភាគ ។

ដូច្នេះ ហើយយើងឃើញមានឯកសារដែលបានដាក់ជូន ហើយការប៉ុនប៉ង់ណាមួយក្នុងការរត់ចេញពីប្រទេសនោះ គឺវាអាចជាកម្មវត្ថុនៃការសម្លាប់ចោលនាសម័យនោះ ។ ដូច្នេះ ហើយវាអាស្រ័យទៅតាមពេលវេលាដែលយើងត្រូវពិចារណា ។

ការរត់ចេញទៅប្រទេសវៀតណាមនោះមិនមែនថាមិនមានគ្រោះថ្នាក់នោះទេ ដោយសារតែប្រទេសវាមានការកើតជម្លោះសង្គ្រាមរវាងប្រទេសកម្ពុជានិងវៀតណាម ។ ហើយប្រទេសវៀតណាមគឺរុញអ្នកទាំងឡាយ ដែលគាត់ចង់រត់ពីប្រទេសឲ្យចូលនៅក្នុងទឹកដីរបស់ខ្លួនវិញ ។ ដូច្នេះ យើងអាចឃើញទៅលើស្ថានភាពនឹងនៅក្នុងឆ្នាំ១៩៧៧ ដែលនៅពេលនោះមានការផ្តាច់ទំនាក់ទំនងការទូត ។

[១៦:០៩:១០]

នៅដើមឆ្នាំ១៩៧៧ យើងឃើញមានហេតុការណ៍លេចឡើងការរត់ចូលទៅក្នុងប្រទេសវៀតណាមគឺនឹងនាំឲ្យមានការដឹកចូលមកក្នុងប្រទេសកម្ពុជារបស់ខ្លួនវិញ។ ដូច្នេះហើយវាពិបាកនៅក្នុងចំណុចនេះ។

ដូចដែលយើងបានជ្រាបហើយ សូម្បីតែនៅតាមព្រំដែនប្រទេសថៃ ប្រជាជនកម្ពុជាមួយចំនួនគាត់មានសំណាងក្នុងការរត់ចូលក្នុងប្រទេសថៃរួមទាំងអ្នកដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងជនភាគតិចផងដែរ ។ ប៉ុន្តែ ចំណុចនោះក៏វាមិនអាចកើតឡើងនៅក្នុងគ្រប់ស្ថានភាពទាំងអស់នោះផងដែរ ដោយសារតែវាមានបញ្ហាប្រឈមទាំងឡាយដែលអាចកើតមាន ។

នៅពេលដែលកម្ពុជាប្រជាធិបតេយ្យត្រូវបានគេវាយប្រហារ គេមិនវាយប្រហារទៅលើបុគ្គលដែលទទួលរងនូវការចោទប្រកាន់ប៉ុណ្ណោះទេ គឺរួមទាំងក្រុមគ្រួសាររបស់គេផងដែរ ។ ដូច្នេះបុគ្គលដែលគាត់រត់គេចខ្លួននោះ គឺគាត់នឹងជួបគ្រោះថ្នាក់ ហើយវាអាចមានការខឹងសម្បានឹងសម្លាប់ទៅលើក្រុមគ្រួសាររបស់គាត់ ។

ដូច្នេះ ហើយយើងស្ថិតនៅក្នុងទឹកដីនៃប្រទេសមួយដែលពិបាក ដូច្នេះ ហើយវាជាចំណុចដែលវា

ជាចំណុចខ្ញុំបានលើកឡើងនៅក្នុងសេចក្តីផ្តើមរបស់ខ្ញុំ គឺយើងប្រឈមទៅនឹងជម្រើសមួយដែលភ័យខ្លាច ហើយយើងត្រូវគោរពបញ្ជាសម្លាប់អ្នកដទៃ មិនសម្លាប់ខ្លួនឯង ។ ដូច្នេះ ហើយថាតើនរណាម្នាក់អាចលើកឡើងថា ខ្លួនឯងហ៊ានលះបង់ខ្លួនឯង? ដូច្នេះហើយចំណុចនេះយើងឃើញមានលេចឡើងដែលយើងត្រូវពិចារណា ហើយមិនទាន់មានលេចចេញជាសំណួរណាមួយជាក់លាក់នោះទេ ។

[១៦:១១:៣០]

**ស៖** ខ្ញុំសូមសំណួរចុងក្រោយមួយ លោកបាននិយាយអំពីប្រយោគចុងក្រោយនៅក្នុងបទបង្ហាញរបស់លោកកាលពីព្រឹកមិញ ។ នៅពេលដែលលោកបានផ្តល់សក្ខីកម្ម លោកបានលើកឡើងអំពីមេត្តាធម៌ និងសេចក្តីអាណិតអាសូរចំពោះជនរងគ្រោះ ។ លោកបានបំពេញការងារនៅក្នុងប្រទេសកម្ពុជាទាក់ទងទៅបញ្ហាសន្តិភាព ហើយខ្ញុំចង់សួរសំណួរមួយទៅកាន់លោក ។

ជាបឋម តើលោកជឿដែរឬទេថា នេះជាលើកដំបូងដែលកម្មាភិបាលខ្មែរក្រហមបានទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់នៅក្នុងអង្គជំនុំជម្រះនេះ ។ តើលោកជឿដែរឬទេថា ការទទួលស្គាល់របស់គាត់នេះវាអាចជួយទៅដល់ដំណើរការផ្សះផ្សាជាតិ? នេះជាសំណួរដំបូង សំណួរមួយផ្នែករបស់ខ្ញុំ ។

សំណួរទីពីរ ដើមបណ្តឹងរដ្ឋប្បវេណីគឺមានការចង់ដឹងនិងចង់ស្វែងយល់នូវអ្វីដែលបានកើតឡើង។ ខ្ញុំបានជម្រាបដើមបណ្តឹងរដ្ឋប្បវេណីតាំងពីដំបូងថា អ្នកទាំងអស់នោះ គឺគាត់នឹងមិនអាចដឹងទៅលើគ្រប់រឿងរ៉ាវទាំងអស់នោះទេ ដោយសារតែជនជាប់ចោទគាត់ក៏មិនដឹងទៅលើរឿងរ៉ាវទាំងអស់នោះដែរ ។ ហើយតើយើងអាចរំពឹងឲ្យមនុស្សម្នាក់គាត់អាចពន្យល់ទៅលើអំពើដែលវាអមនុស្សធម៌ ដែលគាត់មិនដឹងយ៉ាងម៉េច? ដូច្នេះហើយគឺយើងអាចដឹងទៅលើការពិតមួយផ្នែកតែប៉ុណ្ណោះ ។ ដូច្នេះហើយនេះជាសំណួរទីពីររបស់ខ្ញុំ ។

តើលោកជឿឬទេថា ទោះបីជាអង្គជំនុំជម្រះតុលាការសាលាដំបូងនេះ គាត់មិនបានរកចម្លើយដែលចោទសួរពីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះក៏ដោយ គឺការជំនុំជម្រះនេះគឺវាអាចជួយទៅដល់ការផ្សះផ្សាជាតិ ។ ហើយនៅពេលនេះ គឺខ្ញុំមិនយោងអំពីការសុំឲ្យអត់ឱនទោសនោះទេពីជនរងគ្រោះ ខ្ញុំនិយាយអំពីការផ្សះផ្សានៅក្នុងសង្គម ។

**ឆ៖** ខ្ញុំជាបុគ្គលមួយរូបដែលបានធ្វើការនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩១ ដែលយើងមិនបានសុំឲ្យមានការរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជាទេ ដោយនៅអំឡុងពេលនោះ គឺមានការបដិសេធពីអន្តរជាតិ ។ ហើយនៅក្នុងកិច្ចព្រមព្រៀងសន្តិភាព គឺគេមិនឲ្យប្រើពាក្យការរំលោភបំពានអនុ

សញ្ញាទីក្រុងហ្សឺណែវ និងបទប្រល័យពូជសាសន៍ រួមទាំងច្បាប់ប្រឆាំងមនុស្សផងដែរ ។ ដូច្នេះហើយ វាជាអ្វីដែលកើតមាននៅក្នុងអតីតកាល ។ ដូច្នេះហើយខ្ញុំជាបុគ្គលមួយនៅក្នុងចំណោមបុគ្គលទាំងឡាយ ដែលនៅក្នុងឆ្នាំ១៩៩៧ គឺនៅពេលដែលសហនាយករដ្ឋមន្ត្រីគឺបានសរសេរលិខិតស្នើសុំអង្គការសហប្រជាជាតិដើម្បីធ្វើការកាត់សេចក្ដីទៅលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ហើយខ្ញុំមានការរីករាយចំពោះហេតុការណ៍នោះ ទោះបីជាដំណើរការនោះវាមានរយៈពេលយូរនៅក្នុងការបង្កើតតុលាការក៏ដោយ ដោយសារតែប្រទេសកម្ពុជាត្រូវការស្វែងយល់នូវគ្រប់វិស័យទាំងអស់នៅពេលដែលយុត្តិធម៌ត្រូវបានគេរក ។ ដូច្នេះហើយយើងត្រូវតែពន្យល់ ហើយពន្យល់ឲ្យបានយល់ លោកមេធាវីនិយាយត្រឹមត្រូវហើយ ។

ដូច្នេះ ដំណើរការក្ដីនេះហើយដែលវាធ្វើឲ្យជនរងគ្រោះនៃរបប គាត់បានស្វែងយល់។ ប៉ុន្តែយើងមិនដឹងរឿងរ៉ាវទាំងអស់នោះទេ ដែរវាជារឿងរ៉ាវកើតឡើងនៅក្នុងរបបនោះ ។ ប៉ុន្តែ វាជាទុនមួយដែលវាផ្ដល់នឹងជួយទៅដល់ការផ្សះផ្សាជាតិ ហើយប្រទេសនេះហើយដែលមានការជួយជ្រោមជ្រែងពីរដ្ឋាភិបាលកម្ពុជា ដែលមានលក្ខខណ្ឌមួយចំនួននៅពេលដែលស្នើសុំទៅលើព្រឹត្តិការណ៍និងហេតុការណ៍ឲ្យបង្កើតការងារទាំងអស់នេះ ។ ដូច្នេះហើយគឺរាជរដ្ឋាភិបាលកម្ពុជាដែលអាចជួយទៅដល់បញ្ហាផ្សះផ្សាជាតិ ហើយយើងដឹងហើយ គឺការផ្សះផ្សាជាតិនេះ មានលក្ខណៈផុយស្រួយដែលយើងត្រូវតែការពារ ។

[១៦:១៧:១០]

ដំណើរការក្ដីដែលកំពុងតែធ្វើឡើងនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនឹងអាចជួយចូលរួមចំណែកទៅដល់សាធារណជន ។ ហើយសាធារណជនដែលជាអ្នករួមរស់និងរស់រានមានជីវិតនឹងរបបនោះ ដែលគាត់យល់ថា វាមានភាពចាំបាច់ក្នុងការជួយទៅដល់ការផ្សះផ្សាជាតិ ។ យើងដឹងហើយថា ប្រជាពលរដ្ឋកម្ពុជាមានការឈឺចាប់ធ្ងន់ធ្ងរ ។

ដូច្នេះ វាមានភាពចាំបាច់នៅក្នុងពេលបច្ចុប្បន្ននៅក្នុងការដោះស្រាយអតីតកាលដែលវាបានកើតឡើងក្នុងវិធីមួយយុត្តិធម៌និងត្រឹមត្រូវ ហើយលោកមិនឡើងអំពីបញ្ហាខមាទោស និងការសុំអភ័យទោស ដោយសារតែវាពាក់ព័ន្ធនឹងជនរងគ្រោះដែលរស់មានជីវិតម្នាក់ៗ ។ ហើយប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំគិតថាវាជាដំណើរការមួយសំខាន់ ។ ខ្ញុំដឹងថា ហុកសិបភាគរយនៃប្រជាពលរដ្ឋកម្ពុជាគាត់កើតក្រោយឆ្នាំ១៩៧៩ ។ ដូច្នេះ នៅពេលដែលយើងដោះស្រាយទៅលើអតីតកាលរបស់គេ ពួកគេទាំងអស់គ្នានឹងអាច

ងាកទៅរកអនាគតដ៏ភ្លឺស្វាងវិញ ។

[១៦:១៨:៣២]

**ស៖** ហើយតាមលោក ជនជាប់ចោទជាកម្មាភិបាលខ្មែរក្រហមមួយដែលគាត់ទទួលស្គាល់ទៅលើការទទួលខុសត្រូវរបស់គាត់ ។ តាមលោក ថាតើការទទួលស្គាល់នេះវាអាចជួយទៅដល់ការកសាងការផ្សះផ្សាជាតិនៅពេលអនាគតដែរឬទេ?

**ឆ៖** ខ្ញុំចង់សុំឲ្យលោកមិនសួរសំណួរនេះមកកាន់ខ្ញុំ មានតែប្រជាជនកម្ពុជាទេដែលអាចឆ្លើយបាន ។ ខ្ញុំមានបំណងនឹងជូនពរឲ្យមានការស្វែងយល់គ្នាឲ្យមានការយល់គ្នាទៅលើបញ្ហានេះ ហើយចាប់ផ្ដើមបើកទំព័រថ្មី ។

នៅក្នុងតុលាការនូរ៉ឹមប៊ឺក យើងឃើញអ្នកដែលមិនមែនជាអ្នកដឹកនាំ គាត់បានបដិសេធទៅលើការទទួលខុសត្រូវ ។ ដូច្នេះ យើងឃើញមានចំនួនច្រើនណាស់ដែលគាត់មិនទទួលខុសត្រូវទៅលើការទទួលខុសត្រូវរបស់គាត់ ។ ដូច្នេះ ការទទួលស្គាល់ទៅលើការទទួលខុសត្រូវវាកំពុងតែដំណើរការទៅមុខ ហើយវាកំពុងតែចូលរួមចំណែកជាមួយនឹងការផ្សះផ្សាជាតិ ។ ហើយចំណុចនេះវាមិនមែនថា វាដកនូវការទទួលខុសត្រូវដែលវាបង្កប់អត្ថន័យនោះទេ ។ ប៉ុន្តែ វាជាយន្តការជួយសម្រួលទៅដល់ការផ្សះផ្សាជាតិ ។ ដូច្នេះត្រង់ចំណុចនេះ ខ្ញុំមានបំណងនឹង-- នឹងចង់លើកឡើងថា គំរូដែលជនជាប់ចោទរូបនេះបានធ្វើនិងអូសទាញទៅដល់មេដឹកនាំ ឬក៏អ្នកដឹកនាំខ្មែរក្រហម កម្មាភិបាលផ្សេងទៀតឲ្យយកគំរូតាម។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

លោកប្រធាន ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ ។ មេធាវីការពារក្ដីសូមថ្លែងអំណរគុណដល់រូបលោក ដែលមកផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះអង្គជំនុំជម្រះផ្ដល់ឱកាសចំពោះជនជាប់ចោទ ប្រសិនបើជនជាប់ចោទមានបំណងក្នុងការធ្វើការកត់សម្គាល់ចំពោះសក្ខីកម្មរបស់អ្នកជំនាញ វ៉ាអ៊ួល ម៉ាកចេនណា ដែលបានធ្វើការបទបង្ហាញ និងឆ្លើយតបនឹងសំណួរនានាពីអង្គជំនុំជម្រះ ក៏ដូចជាភាគីដែលពាក់ព័ន្ធ ហើយព្រមជាមួយនឹងផងដែរ ក៏ប្រសិនបើលោកមានបំណងក៏លោកធ្វើការកត់សម្គាល់ទៅលើសក្ខីកម្មរបស់អ្នកជំនាញ រីឆាតហ្គោលស្តូន ដែលលោកបានធ្វើសេចក្ដីថ្លែងការណ៍អំពីរបាយការណ៍ជំនាញរបស់លោកកាលពីព្រឹកមិញ។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន សូមគោរពលោកសាស្ត្រាចារ្យ វីឆាត ហ្គោលស្តូន ពីចម្ងាយ និងសូមគោរពលោក វ៉ាអ៊ូល ម៉ាកចេនណា ដែលនៅចំពោះមុខនេះ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកទាំងពីរ ដែលសក្ខីកម្មរបស់លោកទាំងពីរ ធ្វើឱ្យខ្ញុំយល់យល់ដល់ជម្រៅចិត្ត ជាជម្រៅចិត្តទៅដល់កិច្ចការដែលខ្ញុំត្រូវធ្វើចំពោះជាតិប្រជាជនកម្ពុជា ។ ខ្ញុំគ្មានអីជំទាស់ទេ មានតែថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ហើយនិងដោយស្មោះប៉ុណ្ណោះ ។ សូមបញ្ចប់ ។

[១៦:២២:៤២]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដំណើរការនីតិវិធីនៃការស្តាប់នូវសេចក្តីថ្លែងការណ៍អ្នកជំនាញ វ៉ាអ៊ូល ម៉ាកចេនណា--

សូមអញ្ជើញលោកមេធាវី ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

សូមអភ័យទោសលោកប្រធាន ។

ចំពោះខ្ញុំ សំណួរទាក់ទងទៅនឹងនីតិវិធីរបស់យើង ។ ខ្ញុំសូមដាក់ចូលទៅក្នុងសំណុំរឿងនូវឯកសារ D88/5 នៃសំណុំរឿងស៊ើបអង្កេត ហើយយើងខ្ញុំ (សូមអភ័យទោស) គឺ D82 ទេ គឺ D82 ខ្ញុំសូមដាក់ឯកសារនេះផងដែរ ហើយខ្ញុំចង់ឲ្យ គឺសៀវភៅរបស់លោក ម៉ាកចេនណា គឺឯកសារ D80/5 ក៏ដាក់ចូលឯកសារផងដែរ ហើយនិងឯកសារមួយចំនួន ដែលខ្ញុំលើកឡើងអម្បាញ់មិញមុននេះ ។ ដូច្នេះគឺខ្ញុំសុំស្នើ ដាក់ចូលឯកសារ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅខាងតំណាងសហព្រះរាជអាជ្ញា ការស្នើសុំដាក់ឯកសាររបស់មេធាវីការពារក្តីដែលបានលើកឡើងនូវឯកសារមួយចំនួនដែលមាននៅក្នុងសំណុំរឿង ហើយសុំដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។ តើលោកមានយោបល់អ្វីទេ?

**លោក តាន់ សេណារ៉ុង៖**

សូមគោរពលោកប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញាជាតិ មិនមានការយល់ទាស់អ្វីទេនូវសំណើរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ ។ អរគុណ ។

**ប្រធានអង្គជំនុំ៖**

ភាគីមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានមតិយោបល់យ៉ាងម៉េចដែរអំពីឯកសារដែលមេធាវីការពារក្ដីបានលើកឡើង? ហើយសុំដាក់ ដូចជាចាត់ទុកជាការដេញដោលនៅមុខអង្គជំនុំជម្រះនូវឯកសារដែលគាត់បានលើកឡើងនេះ ។

**លោក អាឡាំង វែនណើ៖**

យើងខ្ញុំពុំមានយោបល់ចង់លើកឡើងទៅលើចំណុចនេះទេ លោកប្រធាន ។

[១៦:២៥:៣០]

**ប្រធានអង្គជំនុំ៖**

សូមអរគុណ ។

លោកជំនាញ រ៉ាអ៊ូល ម៉ាកចេនណា ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកឃើញថាដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះសូមថ្លែងអំណរគុណចំពោះលោកដែលបានចំណាយពេលវេលាដ៏មានតម្លៃ ហើយអញ្ជើញចូលរួមធ្វើសក្ខីកម្មក្នុងនាមជាអ្នកជំនាញ តាមការកោះអញ្ជើញរបស់អង្គជំនុំជម្រះ ។

ឥឡូវនេះ ដំណើរការសវនាការសម្រាប់ថ្ងៃនេះឃើញថាដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះសូមប្រកាសផ្អាកដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការសូមលើកទៅបន្តនៅព្រឹកថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ។

អនុរក្សមន្ទីរឃុំឃាំងឲ្យជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[អង្គសវនាការផ្អាកនៅម៉ោង ១៦:២៦:៣៨ នាទី]*